ព្រះរាជាណាចក្រកម្ពុជា
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
នាយកដ្ឋានរុក្ខា-ប្រមាញ់

# គោលការណ៍ណែនាំសហគមន៍ព្រៃឈើ
# មិថុនា ២៩.២000
# គំរោងគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព
# ធនាគារអភិវឌ្ឍន៍អាស៊ី( ទា-៣១៥២-ជា)

**Fraser Thomas GFA-AGRAR ANZDFC**

គោលការណ៍ណែនាំសហគមន៍ព្រៃឈើ
ជំនួយសំរាប់ការអភិវឌ្ឍន៍គោលនយោបាយសហគមន៍ព្រៃឈើ

មាតិកា

១ សេចក្តីផ្តើម៨
១.១ កាលប្រវត្តិ

**២ បរិបទ**

២.១ វិស័យព្រៃឈើនៅកម្ពុជា

២.២ ព្រៃឈើ និង ប្រជាជនជនបទនៅកម្ពុជា

២.៣ សហគមន៍ព្រៃឈើជាអ្វី ?

២.៤ វិសាលភាពនៃសហគមន៍ព្រៃឈើនៅកម្ពុជា

**៣ ការអភិវឌ្ឍន៍គោលការណ៍ណែនាំសហគមន៍ព្រៃឈើនៅកម្ពុជា**

៣.១ ទិសដៅនៃគោលការណ៍ណែនាំ

៣.២ របៀបអភិវឌ្ឍន៍គោលការណ៍ណែនាំ

៣.៣ ការអធិវឌ្ឍន៍គោលការណ៍ណែនាំនៅពេលខាងមុខ

**៤ ការពិចារណាអំពីយុទ្ធសាស្ត្រសហគមន៍ព្រៃឈើ**

៤.១ ការអភិវឌ្ឍន៍ច្បាប់ និង គោលនយោបាយសហគមន៍ព្រៃឈើ

៤.២ បញ្ហាស្ថាប័ន

៤.៣ ការធ្វើផែនការដោយមានការចូលរួម

៤.៤ ការទ្រទ្រង់សហគមន៍ព្រៃឈើ

**៥ គោលលំនាំសំរាប់អនុវត្តន៍សហគមន៍ព្រៃឈើដល់ទីកន្លែង**

៥.១ សេចក្តីផ្តើម គោលបំណងនៃគោលលំនាំអនុវត្តន៍ដល់ទិកន្លែង

៥.២ ជំហានក្នុងការរៀបចំផែនការសហគមន៍ព្រៃឈើថ្នាក់ខេត្ត

៥.៣ ជំហានក្នុងការកសាងផែនការនៅថ្នាក់មូលដ្ឋាន

៥.៤ គោលលំនាំបច្ចេកទេស

**៦ ការណែនាំអំពីគោលលំនាំបច្ចេកទេស**

៦.១ ការកំណត់ព្រៃសហគមន៍

៦.២ សហគមន៍ព្រៃឈើក្នុងតំបន់ព្រៃសម្បទាន

៦.៣ សហគមន៍ព្រៃឈើក្នុងតំបន់ការពារ

៦.៤ ការដោះស្រាយជំលោះ

**៧ ឯកសារយោង**

**៨ ឧបសម្ពន្ធ័: សិទ្ធិ និង ការទទួលខុសត្រូវ**

## ១- សេចក្ដីផ្ដើម:

១/ ឯកសាររៀបចំឡើងជាពង្រាងគោលលំនាំសំរាប់អនុវត្តន៏សហគមន៏ព្រៃឈើដល់ទីកន្លែង និង ជាយុទ្ធវិធីសំរាប់វាស់ស្ទង់ ដែលត្រូវចាត់ការឡើងដោយថ្នាក់ជាតិក្នុងការទ្រទ្រង់សហគមន៏. ឯកសារនេះបានបង្ហាញនូវទស្សនៈ និង របៀបដោះស្រាយ សំរាប់អភិវឌ្ឍន៏គោលលំនាំសហគមន៏ព្រៃឈើ.

២/ ការងាររៀបចំធនធានព្រៃឈើកម្ពុជាឱ្យស្ថិតនៅក្រោមការគ្រប់គ្រងឱ្យនិរន្តន៏ភាពនៅតែជាការងារសំខាន់បំផុតមួយក្នុង ការអភិវឌ្ឍន៏ជាតិ. ចំណុចមូលដ្ឋានដើម្បីសំរេចបាននូវការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាពក្នុងការប្រឈមមុខទល់នឹងតំរូវ ការជាមូលដ្ឋាន និង ក្ដីប៉ងប្រាថ្នារបស់សហគមន៏ជនបទដែលពឹងផ្អែកលើព្រៃឈើដែលពួកគេទាំងអស់មានចំនួនច្រើនក្នុងចំណោម ប្រជាជនទូទាំងប្រទេស. រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជាក់យ៉ាងច្បាស់លាស់នូវកិច្ចសន្យាថានឹងធ្វើការកែលំអការងារគ្រប់គ្រង ព្រៃឈើ និង ការងារបង្កើនការអភិវឌ្ឍន៏សេដ្ឋកិច្ច-សង្គមជនបទ. រាជរដ្ឋាភិបាលកម្ពុជាជាមួយអង្គការអភិវឌ្ឍន៏ឯទៀត១បាន បង្កើនការទទួលស្គាល់នូវសារៈសំខាន់នៃវិភាគទានរបស់សហគមន៏ព្រៃឈើក្នុងការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព និង ការងារ អភិវឌ្ឍន៏ជនបទ. គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានផ្ដួចផ្ដើមកន្លងមករួចមានការចងក្រងគោលនយេបាយ សហគមន៏ព្រៃឈើសំរាប់តំបន់ព្រៃដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ហើយនឹង ក្រសួងបរិស្ថាននោះគឺ បញ្ជាក់អំពីការប៉ុនប៉ងរបស់រដ្ឋាភិបាលក្នុងការកសាងសហគមន៏ព្រៃឈើជាយុទ្ធសាស្ត្រចំបងមួយសំរាប់គ្រប់ គ្រងព្រៃឈើ. ទោះជាសហគមន៏ព្រៃឈើនៅកម្ពុជាមានវ័យក្មេងខ្ចីក៏ដោយក៏មានការពង្រីកវិស័យច្បាប់ និង គោលនយោបាយជា ច្រើនដែលជាគុណប្រយោជន៏សំរាប់ការអនុវត្តន៏សកម្មភាពសហគមន៏ព្រៃឈើអាចបង្កលក្ខណៈឱ្យការងារនេះអាចអនុវត្តបានយ៉ាងទូលំទូលាយ.

៣/ ក្នុងដំណើរការចាប់ផ្ដើមការងារសហគមន៏ព្រៃឈើ ក៏ដូចជាការកសាងគោលលំនាំសហគមន៏ព្រៃឈើនេះ ការគិតគូរ ដោយប្រុងប្រយ័ត្នត្រូវបានផ្ដោតលើការងាររៀបចំស្ថាប័នដើម្បីឱ្យមានភាពងាយស្រួលក្នុងការសំរបសំរួលសកម្មភាព, ការកំណត់ ធនធានធម្មជាតិសំរាប់សហគមន៏ព្រៃឈើ និង ការផ្លាស់ប្ដូរពតិមាន. គោលលំនាំសហគមន៏ព្រៃឈើនេះ បានរៀបចំឡើងនៅ ពេលដែលច្បាប់សំរាប់ស្ថាប័នទទួលខុសត្រូវកំពង់តែបានធ្វើពង្រាផងដែរ. ថ្វីបើបែបនេះក៏ដោយ ក៏នេះជាការងារសំខាន់មួយគួរ ត្រេកអរដែលបណ្ដាអង្គការនានា សមាគមទូទាំងប្រទេសបានបង្ហាញឱ្យឃើញនូវសមត្ថភាពរបស់ពួកគេក្នុងជំហានយ៉ាងរហ័សមួយ សំរាប់សេចក្ដីរីកចំរើននៅក្នុងកម្ពុជា .គោលលំនាំសហគមន៏ព្រៃឈើនេះគឺរៀបចំឡើងដើម្បីបញ្ជៀសឱ្យបាននូវពាក្យថាតើអង្គការ នេះធ្វើអ្វី

ហើយអង្គការនោះធ្វើអ្វីជាពិសេសនៅក៏រិតថ្នាក់ខេត្តដែលបច្ចុប្បន្ននេះទំនាក់ទំនងពីខេត្តមួយទៅខេត្តមួយពីអង្គភាពមួយទៅអង្គភាពមួយនៅតែមាន ភាពខុសប្លែកគ្នាយ៉ាងធំធេងនៅឡើយ. ដោយហេតុនេះហើយគោលលំនាំសហគម្មន៏ព្រៃឈើនេះផ្តោតលើការរៀបចំដំណើរការមួយដែលឆ្លើយតបទៅនឹងសហគមន៏ព្រៃឈើដែលអង្គភាពណាមួយក៏អាចអនុវត្តន៏បានដោយមាន តំលាភាព និងប្រកបដោយគណនីយភាព សំរាប់ក្រុមគោលដៅរបស់គេគឺប្រជាជនកម្ពុជានៅជនបទ.

## ១-១ កាលប្រវត្តិ

៤/ នៅឆ្នាំ ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជាបានសុំឱ្យធនាគារអភិវឌ្ឍន៏អាស៊ី(ADB)ឱ្យជួយផ្តល់នូវជំនួយការបច្ចេកទេសសំរាប់ការរៀបចំគ្រោងការវិស័យព្រៃឈើ. នៅក្នុងខែតុលា ឆ្នាំ ១៩៩៨ ក្រុមបេសកកម្មរបស់ ADB មួយក្រុមបានមកធ្វើទស្សនៈកិច្ចនៅកម្ពុជាហើយបានឯកភាពជាមួយរាជរដ្ឋាភិបាលកម្ពុជាលើកម្មវិធីអភិវឌ្ឍន៏មួយដែលខាង ADB យល់ព្រមជួយផ្តល់ហិរញ្ញវត្ថុសំរាប់ជំនួយការបច្ចេកទេសដើម្បីសិក្សាឡើងវិញនូវស្ថានការណ៏វិស័យព្រៃឈើ និង បង្ហាញព្រមទាំងចងក្រងជាគ្រោងការណ៏អភិវឌ្ឍន៏មួយ. ក្រុមហ៊ុនឯកជន Fraser Thomas ត្រូវបានជ្រើសរើសសំរាប់ផ្តល់នូវជំនួយការបច្ចេកទេសនេះ.

៥/គំរោងជំនួយការបច្ចេកទេសនេះមានទិសដៅជាគន្លឹះបីសំខាន់: I/ជួយដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការចងក្រងជាបរិស្ថាននយោបាយសមស្របមួយ និង គំរោងស្របច្បាប់សំរាប់ អភិវឌ្ឍន៏វិស័យព្រៃឈើ II/ ពិនត្យឡើងវិញនូវប្រពន្ធ័ព្រៃសម្បទាន ក្នុងកម្ពុជាតាមរយៈការត្រួតពិនិត្យឯកសាររួមជាមួយការចុះពិនិត្យដល់ទី កន្លែងដើម្បីក្តាប់បាននូវការប្រព្រឹត្តទៅរបស់ម្ចាស់ព្រៃ សម្បទាន និងបង្កើតឡើងនូវផែនការសកម្មភាពមួយសំរាប់កែទំរង់ប្រពន្ធ័ ព្រៃសម្បទានកន្លងមក និង III ធ្វើការរៀបចំយ៉ាងជាក់លាក់នូវកម្មវិធីសំរាប់ប្រើប្រាស់ប្រាក់កម្ចីដែលអាច វិនិយោគបានក្នុងការពង្រីកវិធីសាស្ត្រគ្រប់គ្រងធនធានព្រៃឈើនៅកម្ពុជាដោយនិរន្តរភាព( កម្មវិធីនេះគឺជាកម្មវិធីវិនិយោគទុន).

៦/ គំរោងជំនួយការបច្ចេកទេស (TA) បានចាប់ផ្តើមនៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៩ដែលក្នុងនោះជំហានដំបូងរួមមានការវិភាគទស្សនៈវិស័យព្រៃឈើនៅកម្ពុជា និង ការសិក្សាវិភាគស្ថានភាពច្បាស់ និង គោលនយោបាយដែលបានប្រើប្រាស់ និងប្រតត្តិបត័ក្នុងវិស័យព្រៃឈើ. គំរោងជំនួយការបច្ចេកទេសក៏បានទទួលរ៉ាប់រងផងដែរនូវការរៀបចំគោលលំនាំសហគមន៏ព្រៃឈើស្របគ្នានឹងការទទួលខុសត្រូវសំរាប់គោលនយោបាយទ្រទ្រង់ក្នុងទំនាក់ទំនងសហគមន៏ព្រៃឈើ. ការងារនេះបានកើតឡើងដំណាលគ្នាជាមួយមុខងារជាទីប្រឹក្សាគ្រោងការណ៏ដ៏ទៃទៀតដែលបានជួយទ្រទ្រង់ដល់ការរៀបចំច្បាប់ព្រៃឈើ និង កិច្ចព្រមព្រៀងព្រៃសម្បទាន និង ការងារសិក្សាឡើងវិញនូវប្រពន្ធ័ព្រៃសម្បទាននៅកម្ពុជា.

៧/ ក្នុងការរៀបចំគោលលំនាំសហគមន៏ព្រៃឈើដែលបានលើកឡើងខាងលើនេះ ការពិភាក្សា ពិគ្រោះយោបល់ត្រូវបានធ្វើឡើងជាមួយបណ្តាផ្នែកពាក់ពន្ធ័ជាមួយសហគមន៏ព្រៃឈើនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និង មូលដ្ឋានក្នុងអំឡុងខែកញ្ញា ដល់ ខែធ្នូ ១៩៩៩. កិច្ចពិគ្រោះយោបល់នេះរួមទាំងការធ្វើសិក្ខាសាលា ៣លើកដែលបានរៀបចំដោយអង្គការ ខុនស៊ីន វើុលវ៉ាយ [១] ជាមួយនឹងគ្រោងការណ៏គ្រប់គ្រងព្រៃឈើដោយនិរន្តរភាព. គោលលំនាំសហគមន៏ព្រៃឈើត្រូវបានកសាងឡើងដោយគ្រោងការណ៏ដែលទៅអនាគតទ្រទ្រង់ពីអង្គការខុនស៊ីន ដោយប្រើប្រាស់ផលិតផលដែលបានមកពីការពិភាក្សា ពិគ្រោះយោបល់ និង បណ្តាពតិមានពាក់ពន្ធ័ទៅនឹងសហគមន៏ព្រៃឈើពីតំបន់ផ្សេងទៀតក្នុងទ្វីបអាស៊ី.

៨/ ឯកសារនេះរួមមានពីរផ្នែកៈ - ផ្នែកទី១ បកស្រាយអំពីការកសាងគោលលំនាំដោយបញ្ជាក់នូវរបៀបដែលគោលលំនាំអាចបន្តភាពល្អិតល្អន់នៅពេលខាងមុខ និងព្រាងយុទ្ធសាស្ត្រមួយដែលមានសារៈសំខាន់សំរាប់ពង្រឹងការទ្រទ្រង់សហគមន៏ ព្រៃឈើ. ផ្នែកទីពីរនៃឯកសារនេះបង្ហាញអំពីគោលលំនាំថ្នាក់មូលដ្ឋានដែលមានបំណងក្នុងការអនុវត្តន៏ការងារនៅមូលដ្ឋាន ដោយផ្ទាល់. គោលលំនាំសំរាប់ថ្នាក់មូលដ្ឋាននេះក៏អាចពិនិត្យឡើងវិញ និង សំរបសំរួលនៅពេលខាងមុខដែលចាត់ទុកជាបទពិសោធន៏នៃការយល់ដឹងនូវប្រសិទ្ធភាពក្នុងការពង្រឹកសហគមន៏ព្រៃឈើ.

៩/ នៅមានកិច្ចការជាច្រើនដែលត្រូវធ្វើបន្តទៀតក្នុងវិស័យព្រៃឈើនៅកម្ពុជាដើម្បីសំរេចបាននូវការតំរង់ទិសស្ថាប័នឡើង វិញ និង ពង្រីកនូវប្រត្តិប័តការក្នុងចំណោមអ្នកពាក់ពន្ធ័ទាំងឡាយក៏ដូចជា ការអនុវត្តប្រកបដោយប្រសិទ្ធិភាពក្នុងកិច្ចគ្រប់គ្រងព្រៃឈើតាមរបៀបថ្មីមួយ.

# ២- បរិបទ

## ២-១ វិស័យព្រៃឈើនៅកម្ពុជា

១០/ កម្ពុជាជាប្រទេសមួយដែលសំបូរទៅដោយធនធានធម្មជាតិជាព្រៃឈើដែលបានរក្សាទុកក្នុងអំឡុងពេលដែលបណ្តា

---

(1) CONCERN World wide
គឺជាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិមួយដែលសកម្មក្នុងការគាំទ្រការអធិវឌ្ឍន៏ជមបទនៅក្នុងប្រទេសកម្ពុជារួមមានការ ទ្រទ្រង់ស្ថាប័ន និង ទ្រទ្រង់មូលដ្ឋានសំរាប់ការអភិវឌ្ឍន៏សហគមន៏ព្រៃឈើ.

ប្រទេសនានាក្នុងអាស៊ីអាគ្នេយ៏ បានបាត់បង់ព្រៃឈើរបស់គេក្នុងទសវត្ស កន្លងមកយ៉ាងណាក៏ដោយក៏ការសល់ធនធានព្រៃឈើដ៏ធំធេងនេះគឺជាលទ្ធផលនៃសង្គ្រាម និង ភាពឯកកោរបស់កម្ពុជាច្រើនជាង គោលនយោបាយសំរាប់ព្រៃឈើដែលបំរើឱ្យការគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាពដែលមានក្នុងប្រទេសកម្ពុជាកន្លងមកនេះ. នៅពាក់កណ្តាលឆ្នាំ១៩៩០ដោយសារបង្កើនស្ថិរភាពជាតិ និង ការពង្រីកពាណិជ្ជកម្មអន្តរជាតិគួបផ្សំជាមួយនឹងការខ្វះខាតគោល នយោបាយ និង សមត្ថភាពសំរាប់ការគ្រប់គ្រងព្រៃឈើ ធ្វើឱ្យការកាប់ព្រៃឈើមានការកើនឡើងយ៉ាងខ្លាំង. ជាលទ្ធផលគឺ ធនធានព្រៃឈើកម្ពុជាត្រូវបានបាត់បង់លឿនជាងព្រៃឈើនៃបណ្តាប្រទេសដ៏ទៃទៀតនៅអាស៊ី លទ្ធផលតាមការទាយទុកក្នុងឆ្នាំ ១៩៩៧-១៩៩៨ គឺគ្រប់ពាណិជ្ជកម្មព្រៃឈើទាំងអស់នឹងត្រូវចុះទន់ខ្សោយក្នុងអំឡុងពេល៥ឆ្នាំខាងមុខ. ការបាត់បង់ធនធានព្រៃ ឈើយ៉ាងខ្លាំងក្លានេះបង្កឱ្យមានភាពរេចរិលនៃបរិស្ថាន បន្ថយចុះនូវធនធានព្រៃឈើសំរាប់ឧស្សាហកម្ម និង ពានិជ្ជកម្មបង្កឱ្យមាន ភាពក្រីក្រ និង ធ្វើឱ្យអស្ថេរភាពសេដ្ឋកិច្ចដល់ប្រជាជនកម្ពុជានៅជនបទកាន់តែខ្លាំងឡើងៗ.

## ២-២ ព្រៃឈើ និង ប្រជាជននៅជនបទក្នុងប្រទេសកម្ពុជា

១១/ ការបាត់បង់ព្រៃឈើយ៉ាងច្រើននេះបានទំលាក់បន្ទុកទៅលើការបរាជ័យនៃប្រពន្ធ័ព្រៃសម្បទានដែលបានកសាងឡើង ក្នុងអំឡុងឆ្នាំ ១៩៩០ តាមរយៈការរួមគ្នានៃរាជរដ្ឋាភិបាលកម្ពុជា និង បណ្តាប្រទេសមួយចំនួនក្នុងតំបន់ដោយហេតុថាប្រពន្ធ័គ្រប់គ្រងព្រៃសម្បទានកន្លងមកនេះមានការខ្វះខាតជាច្រើនដូចជាខ្វះខាតលើការវាយតំលៃធនធាន, ខ្វះខាតលើការកសាងផែនការ និង ត្រួតពិនិត្យកិច្ចប្រតិបត្តការ និង មិនបានត្រួតពិនិត្យលើការកាប់ព្រៃឈើដោយអនាធិបតេយ្យដែលមានសន្ទុះខ្លាំងក្លាគ្មានអីទប់ទល់ បានដែលទាំងអស់នេះសុទ្ធតែជាគន្លឹះនៃនិរន្តរភាពព្រៃឈើ. បន្ថែមលើនេះទៀតប្រពន្ធ័គ្រប់គ្រងព្រៃសម្បទានកន្លងមកនេះក៏នៅមានភាពចន្លោះប្រហោងក្នុងការការពារធនធានព្រៃឈើសំរាប់សហគមន៏ជនបទកម្ពុជាពឹងពាក់អាស្រ័យផងដែរ[២].

១២/ ព្រៃឈើមានសារៈសំខាន់បំផុតសំរាប់ជីវភាពរស់នៅ និង សុខមាលភាពរបស់ប្រជាជនកម្ពុជា. តាមការប៉ាន់ប្រមាណបានឱ្យដឹងថាមានប្រជាជានកម្ពុជា ៨៥%រស់នៅតាមជនបទ ហើយពួកគេភាគច្រើនមានជីវភាពក្រដែលការរស់នៅរបស់ពួកគេពឹងផ្អែកទៅលើរបរកសិកម្ម, នេសាទ, និង ការប្រើប្រាស់ធនធានធម្មជាតិផ្សេងៗទៀតដោយផ្ទាល់. ជាទូទៅសហគមន៏មានការប្រែប្រួលទៅតាមវិសាលភាពតំបន់ព្រៃដែលពួកគេពឹងពាក់ភាគច្រើននៃសហគមន៏ប្រើប្រាស់ព្រៃឈើសំរាប់គោលបំណងទាំងពីរយ៉ាងគឺ សំរាប់ភាពគ្រប់គ្រាន់ក្នុងតំរូវការ( មិនលក់ដូរ) និង ផលិតផលសំរាប់លក់ដូរ. ព្រៃឈើបានផ្តល់នូវទំនិញសំខាន់ៗច្រើនប្រភេទ ដូចជា : អុសសំរាប់ចំអិនអាហារ, សំភារៈសំណង់, ឧបករណ៏សំរាប់ធ្វើផ្ទះ, ចំណីអាហារ, ឱសថបូរាណ, ចំណីសត្វ និង ការងារដឹក ជញ្ជូន (ដូចជាឈើសំរាប់ធ្វើរទេះ).

១៣/ ផលិតផលមួយចំនួនអាចរកបានយ៉ាងងាយពីព្រៃឈើ ដែលផលិតផលទាំងនោះអាចមានតំលៃខ្ពស់, មានភាពរឹងមាំ និង ប្រកបដោយគុណភាព. ដោយហេតុនេះហើយវាជាការចាំបាច់ក្នុងការគ្រប់គ្រងព្រៃឈើដែលត្រូវមើលឱ្យឃើញនូវភាពពិសិទ្ធ របស់ព្រៃឈើ និង ត្រូវទទួលស្គាល់នូវតំរូវការ និង តំលៃផ្សេងៗគ្នារបស់ព្រៃឈើចំពោះក្រុមអ្នកប្រើប្រាស់ព្រៃឈើដោយឡែក ពីគ្នា.

---

១៤/ បន្ថែមលើការផ្តល់ធនធានសំរាប់សេចក្តីត្រូវការប្រចាំថ្ងៃព្រៃឈើនូវបានផ្តល់សារៈសំខាន់ផ្នែកវប្បធម និង បរិស្ថាន ថែមទៀត. ព្រៃឈើមួយចំនួននៅកម្ពុជាត្រូវបានចាត់ទុកជាកន្លែងគោរពបូជាសំរាប់ជីវិតរស់នៅរបស់ប្រជាជនដែលរស់នៅក្នុង ឬតំបន់ក្បែរព្រៃ. ដូច្នេះប្រជាជនបានមើលឃើញព្រៃឈើក្នុន័យទូលំទូលាយមួយ : ជាមជ្ឍដ្ឋានរស់នៅ, ជាតំបន់វប្បធម និង តួនាទីបរិស្ថាន.

(២ ) របាយការណ៏ស្តីពីការត្រួតពិនិត្យព្រៃសម្បទានឡើងវិញនៅកម្ពុជារបស់ Fraser Thomas P.P. April 2000.

១៥/ រាប់រយគ្រួសារនៃប្រជាជនជនបទរស់នៅក្នុង ឬជាប់នឹង តំបន់ព្រៃឈើ. សហគមន៏ជនបទជាច្រើនមានព្រៃធម្មជាតិតូចៗ( ភាគច្រើនជាព្រៃរេចរិល) ព្រៃសំរាប់ធ្វើកសិកម្ម និង ធនធានព្រៃឈើធម្មជាតិផ្សេងទៀតនៅក្នុងព្រំប្រទល់ភូមិរបស់គេដែលព្រៃទាំងនេះសុទ្ធតែមានសារៈសំខាន់ និង ជាប្រភពធនធានសំរាប់ប្រជាជនមូលដ្ឋាន. លក្ខណៈពិសេសសំរាប់សហគមន៏មូលដ្ឋាន និង ធនធានព្រៃឈើមានការប្រែប្រួលយ៉ាងទូលំទូលាយក្នុងប្រទេសកម្ពុជាទាំងមូល. ជាទូទៅ យ៉ាងណាក៏ដោយគេអាចធ្វើការបែងចែកព្រៃឈើជា៥រូបភាពផ្សេងគ្នាដោយយោងតាមការរួមផ្សំនៃសរីរៈជីវសាស្រ្តសេដ្ឋកិច្ចសង្គម និង តួនាទីស្ថាប័នៈ

- *ព្រៃឈើមិនសម្បទាន* : គឺតំបន់ព្រៃដែលអាចចេញចូលបានដោយប្រជាជនមូលដ្ឋានពោលគឺតំបន់ព្រៃដែលមិនបាន ចាត់ចូលជាព្រៃសម្បទាន ឬតំបន់ការពារ. ភាគច្រើននៃតំបន់ព្រៃទាំងនេះមិនមានលក្ខណៈជាដុំកំភួនសំរាប់ពាណិជ្ជកម្មឈើ, គ្មាន សក្តានុពលសំរាប់ផលិតកម្មឈើ ឬ តំលៃខាងផ្នែកអភិរក្ស. ភាគច្រើននៃតំបន់ទាំងនេះខ្វះការគ្រប់គ្រងរៀបចំគឺជាព្រៃសំរាប់ ប្រើប្រាស់ធនធានរួមដែលអាចបណ្តាលឱ្យមានការប្រើប្រាស់ហួសកំរិត និង រេចរិល. ទោះជាយ៉ាងណាក៏ដោយនៅក្នុងតំបន់ព្រៃ នេះមួយចំនួនប្រជាជនមានប្រពៃណីអនុវត្ត ឬ សហគមន៏គ្រប់គ្រងដោយដាក់លក្ខណ្ឌ័ក្នុងការប្រើប្រាស់ធនធានព្រៃឈើ និង ធានា នូវនិរន្តរភាពនៃធនធានធម្មជាតិ. ព្រៃឈើមិនសម្បទានមានទំហំពីបីទៅប្រាំលានហិកតានៅក្នុងប្រទេសកម្ពុជា និង រួមបញ្ចូល ព្រៃមួយចំនួនទៀតដែលបានដកចេញពីព្រៃសម្បទាននាពេលកន្លងមកថ្មីៗនេះ.

- *ព្រៃសម្បទាន* : ព្រៃឈើអាចចេញចូលដោយប្រជាជនមូលដ្ឋាន,ព្រៃសម្បទានគឺជាព្រៃដែលបានប្រគល់ឱ្យក្រុមហ៊ុនពាណិជ្ជ កម្មឈើណាមួយដោយរាជរដ្ឋាភិបាលកម្ពុជា. តំបន់ព្រៃទាំងនេះសំបូរទៅដោយព្រៃពានិជ្ជកម្មហើយមានសក្តានុពលសំរាប់អាជីវ កម្មឈើ. សិទ្ធិក្នុងការលក់ដូរឈើដែលបានប្រគល់ឱ្យទៅម្ចាស់ព្រៃសម្បទាននេះអនុលោមទៅតាមកិច្ចព្រមព្រៀងពាណិជ្ជកម្ម. កន្លែងខ្លះនៅក្នុងព្រៃនេះប្រជាជនមូលដ្ឋានមានប្រពៃណីអនុវត្តគ្រប់គ្រងក្នុងការថែរក្សាឱ្យមាននិរន្តរភាពនៃធនធានធម្មជាតិប៉ុន្តែ មកទល់នឹងពេលនេះក្នុងកិច្ចសន្យារបស់ម្ចាស់ព្រៃសម្បទាន់មិនមានចែងអំពីការ ទទួលស្គាល់, គោរព ឬក៏ធានាដល់សិទ្ធគ្រប់គ្រង តាម ប្រពៃណី ឬ តំរូវការរបស់សហគមន៏មូលដ្ឋានទេ. ម្ចាស់ព្រៃសម្បទានអាចដាក់ព្រំដែនរាល់ការចេញចូល និង ប្រើប្រាស់ព្រៃឈើ ដោយប្រជាជនមូលដ្ឋានដែលជាហេតុបង្ករឱ្យមាននូវជំលោះផ្នែកផលប្រយោជន៏រវាងសហគមន៏មូលដ្ឋាន និង ម្ចាស់ព្រៃសម្បទាន. រហូតមកទល់នឹងពេលនេះមិនទាន់មានវិធានការគ្រប់គ្រាន់សំរាប់ដោះស្រាយជំលោះទាំងនេះឡើយ. កន្លងមកថ្មីៗនេះព្រៃឈើនៅ កម្ពុជាប្រហែល៤,៧ លានហិកតា ត្រូវបានកំណត់ជាព្រៃសម្បទាន.

- *តំបន់ព្រៃការពារ* : កន្លងមករាជរដ្ឋាភិបាលកម្ពុជាបានរៀបចំព្រៃឈើ ២៣កន្លែងជាតំបន់ការពារដែលក្នុងកន្លែងទាំងអស់ នោះមានសហគមន៏មូលដ្ឋាស្នាក់នៅ និង ចេញចូលរកធនធានព្រៃឈើ. ការកំណត់តំបន់ការពារទាំងអស់នេះក្នុងគោលដៅ អភិរក្សជីវសាស្រ្តចំរុះ, ការពារតំបន់ទីជំរាល និង ផលប្រយោជន៏បរិស្ថានផ្សេងទៀត. ការគ្រប់គ្រងព្រៃការពារដោយរដ្ឋនេះ សំដៅថែរក្សាផលប្រយោជន៏បរិស្ថានក្នុងតំបន់ព្រៃការពារបណ្តាលឱ្យមានការហាមឃាត់ ឬ កាត់បន្ថយការចេញចូល និង ប្រើ ប្រាស់ធនធានព្រៃឈើដោយសហគមន៏មូលដ្ឋាន. បើសិនជាផលប្រយោជន៏សំរាប់សហគមន៏មូលដ្ឋានត្រូវបានកាត់បន្ថយដោយ សារការកំណត់តំបន់ព្រៃការពារនោះ ទំនាស់អាចនឹងកើតមានរវាងសហគមន៏មូលដ្ឋានជាមួយនឹងរដ្ឋដែលជាអ្នកការពារតំបន់ព្រៃ ការពារ. ការកំណត់តំបន់ព្រៃការពារនៅកម្ពុជាបានធ្វើឡើងដោយគ្មានការចូលរួមរបស់ប្រជាជនមូលដ្ឋាន, ហេតុដូច្នេះហើយទើប ក្រោយមកអាជ្ញាធរគ្រប់គ្រងតំបន់ព្រៃការពារបានទទួលស្គាល់នូវសិទ្ធិ និង តំរូវការប្រើប្រាស់ព្រៃឈើតាមលក្ខណៈប្រពៃណីរបស់ សហគមន៏មូលដ្ឋានហើយបានព្យាយាមបញ្ចូលសិទ្ធិជាប្រពៃណី និង តំរូវការរបស់សហគមន៏មូលដ្ឋានក្នុងការគ្រប់គ្រងតំបន់ព្រៃ ការពារ. ប្រពន្ឋ័ព្រៃការពារនៅកម្ពុជាគ្របដណ្តប់លើដីប្រហែល៣,៣ ហិកតា. នៅពេលព្រៃដែលបានចាត់ចូលជាតំបន់ព្រៃការ ពារបានរេចរិលនោះតំលៃនៃការអភិរក្សមិនប្រាកដជាអាចធានាបានទេ.
- *ព្រៃលិចទឹក និង ព្រៃកោងកាង* : ជាតំបន់ព្រៃដែលចេញចូលដោយសហគមន៏មូលដ្ឋាន គឺជាកន្លែងសំខាន់សំរាប់រក្សាប្រពន្ឋ័ បរិស្ថានដើម្បីការរស់នៅរបស់ត្រីទឹកសាប និង ត្រីសមុទ្រ .ដើម្បីរក្សាបាននូវផលិតភាពត្រីទឹកសាប និង ត្រីសមុទ្រដែលជាប្រភព អាហារ និង សេដ្ឋកិច្ចដ៏ចំបងរបស់កម្ពុជានោះព្រៃលិចទឹក និង ព្រៃកោងកាងនេះ ត្រូវបានការពារស្របច្បាប់ និង ក្រោមការគ្រប់

គ្រងរបស់នាយកដ្ឋានជលផលនៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ. នៅក្នុងការអនុវត្តជាទូទៅព្រៃលិចទឹក និង ព្រៃកោង កាង ត្រូវបានប្រើប្រាស់ជាប្រភពអុស ប៉ុន្តែតំបន់ព្រៃកោងកាងខ្លះត្រូវបានកែប្រែទៅជាស្រែបង្គាររបស់ឯកជន. ទោះបីយ៉ាងណាក៏ដោយនៅក្នុងព្រៃលិចទឹក និងព្រៃកោងកាងខ្លះត្រូវបានប្រជាជនមូលដ្ឋានប្រើប្រាស់ដោយមិនបានគិតអំពីការរក្សាតុលល្យភាព និង និរន្តរភាព នៃធនធានធម្មជាតិទេ. ព្រៃលិចទឹក និង ព្រៃកោងកាង កន្លងមកមានប្រហែលជា ៨៥.១០០ហិកតាប៉ុន្តែត្រូវបានរួញចុះជាបន្តបន្ទាប់ដោយសារការកាប់លើសកំរិត និង ការបំប្លែងទៅជារូបភាពផ្សេង ដូចជាស្រែបង្គារ ឬចំការដំណាំកសិកម្មជាដើម.

- *តំបន់គ្មានព្រៃ* : តំបនដែលសំបូរទៅដោយកសិកម្ម និង ការបង្កើតភូមិដ្ឋានបាត់បង់សញ្ញាណ ឬ លក្ខណៈសំគាល់ថាជាព្រៃ (មិនថាព្រៃស្ដុកឬក្រ) មិនអាចរកធនធានព្រៃឈើសំរាប់ផ្គត់ផ្គង់តំរូវការនូវមូលដ្ឋានបាន. បែបផែនព្រៃរបៀបនេះមិនអាចចាត់ទុកថាជាព្រៃបានទេ. ប្រជាជនដែលរស់នៅក្នុងមូលដ្ឋាននេះទទួលផលជាធនធានព្រៃឈើពីដើមឈើ និង ព្រៃគុម្ពោតដែលមាននៅក្នុង និង ជុំវិញចំការ និង តំបន់កសិកម្ម (ក្បាលស្រែ ភ្លឺស្រែ )ជុំវិញផ្ទះ ជុំវិញវត្ត តាមសាលារៀន តាមថ្នល់ តាមផ្លូវទឹក និង តាមព្រៃគុម្ពោតរេចរិលតូចៗ. វាមិនមានន័យអ្វីទាល់តែសោះចំពោះការគិតគូរ ឬ ប៉ាន់ប្រមាណប្រភេទព្រៃនេះ ប៉ុន្តែក៏គួរទទួលស្គាល់ដែរថាមានច្រើនពាន់សហគមន៏ ពឹងផ្អែកលើធនធានព្រៃឈើពីតំបន់របៀបនេះហើយក៏ទទួលស្គាល់ដែរថាតំបន់របៀបនេះមានសក្ដានុពលសំរាប់ បង្កើនផលិតភាពតាមរយៈការបង្កើនកិច្ចគ្រប់គ្រងដែលផ្ដួចផ្ដើមឡើង តាមរយៈសហគមន៏មូលដ្ឋាន.

**២-៣ អ្វីទៅជាសហគមន៏ព្រៃឈើ?**

១៦/ សហគមន៏ព្រៃឈើគឺជាយុទ្ធសាស្ត្រគ្រប់គ្រងព្រៃឈើដោយនិរន្តរភាពតាមរយៈការចូលរួមរបស់ប្រជាជននៅជនបទដោយការរៀបចំទិសដៅឱ្យប្រជាជននៅជនបទជាចំណុចសំខាន់បំផុតក្នុងការគ្រប់គ្រងព្រៃឈើ និងការធានាឱ្យបានថាប្រជាជននៅជនបទទទួលបានផលប្រយោជន៏សមស្របពីការគ្រប់គ្រងព្រៃឈើ. និយាយជារួមទស្សនៈទានអំពីសហគមន៏ព្រៃឈើគឺស្វែងរកគោលការណ៏ដែលសហគមន៏មូលដ្ឋានអាចនឹងធ្វើការគ្រប់គ្រងធនធានឱ្យមានផលប្រយោជន៏ក្នុងរយៈពេលយូរអង្វែង ហើយក្នុងរយៈពេលនៃផលប្រយោជន៏យូរអង្វែងនេះ ត្រូវមានស្មើរគ្នាជាមួយនិរន្តរភាពនៃធនធាន. ដូច្នេះមានន័យថាសហគមន៏ព្រៃឈើ បំពេញបន្ថែម និង បង្កើនយុទ្ធវិធីគ្រប់គ្រងព្រៃឈើ និង រួមចំណែកក្នុងការគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាព. សហគមន៏ព្រៃ ឈើមានន័យថាបុរស និង ស្ត្រីនៅមូលដ្ឋានៈ

- ជាអ្នកប្រើប្រាស់ព្រៃឈើដោយផ្ទាល់ជាដំបូងនឹងពឹងផ្អែកលើផល និង អនុផលព្រៃឈើសំរាប់ទ្រទ្រង់តំរូវការជាមូលដ្ឋានសំរាប់ការរស់នៅរបស់ពួកគេ.
- ជាអ្នកមានតំរេះវិជ្ជាដ៏មានតំលៃ, មានជំនាញ និង បទពិសោធន៏ដើម្បីរួមចំណែកក្នុងការគ្រប់គ្រងធនធានពៃឈើឱ្យមាន និរន្តរភាព.
- ជាតំណាងធនធានដ៏សំខាន់សំរាប់ដើរតួនាទីក្នុងការគ្រប់គ្រងធនធានព្រៃឈើឱ្យមាននិរន្តរភាពដែលអាចធ្វើឱ្យសកម្មថែមទៀតដោយការបង្កើតឱ្យមានសិទ្ធិធ្វើការបានរហូតនិង ប្រពន្ធ័គ្រប់គ្រងសមស្រប.
- កំណត់ទិសដៅក្នុងការគ្រប់គ្រងព្រៃឈើដោយយោងតាមតំរូវការរបស់សហគមន៏, គូសព្រាងតំបន់ព្រៃសំរាប់សហគមន៏ ប្រើប្រាស់, គ្រប់គ្រង និង ការពារតំបន់ព្រៃឈើ, ត្រួតពិនិត្យការប្រើប្រាស់ និង សកម្មភាពគ្រប់គ្រងព្រៃឈើ, ដោះស្រាយទំនាស់

ដែលទាក់ទងជាមួយតំបន់ និង ធនធានព្រៃឈើ, ប្រើប្រាស់តំបន់ព្រៃឈើ និង បែងចែកផលប្រយោជន៍ព្រៃឈើ និង ទៅតាមសមធម៌ និង និរន្តរភាព.

- ទទួលផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច និង សង្គមអំពីប្រសិទ្ធិភាពនៃការគ្រប់គ្រងព្រៃឈើ.

១៧/ ជាធម្មតាសហគមន៍ព្រៃឈើរួមបញ្ចូលតំបន់ដែលបានចាត់ទុកជាព្រៃឈើរួចហើយប៉ុន្តែក៏អាចរួមបញ្ចូលតំបន់គ្មានព្រៃ ដូចជាវាលស្មៅ, ដងផ្លូវ, ព្រំប្រទល់ស្រែចំការ, និង ដើមឈើជុំវិញលំនៅដ្ឋាន, ចំការ និង កន្លែងធ្វើកសិកម្មពនេចរដែលសហគមន៍បានរួមចំណែកធ្វើសកម្មភាពក្នុងការគ្រប់គ្រងតំបន់ទាំងអស់នេះក្នុងគោលបំណងឱ្យមានធនធានព្រៃឈើផងដែរ. ជាទូទៅសហគមន៍ព្រៃឈើទាក់ទងទៅនឹងសហគមន៍ជនបទ ប៉ុន្តែវាក៏អាចអនុវត្តនៅក្នុងតំបន់ប្រជុំជនដែលសហគមន៍បានរួមចំណែកធ្វើសកម្មភាពក្នុងការគ្រប់គ្រង( ព្រៃតំបន់ប្រជុំជន) ដូចជា : ឈើនៅតាមដងផ្លូវផងដែរ. សហគមន៍ជនបទនៅកម្ពុជាខ្លះមានប្រពន្ធ័ប្រពៃណីកាន់កាប់ និង មានទំលាប់គ្រប់គ្រងព្រៃឈើ, ខ្លះទៀតមានការចាប់ផ្តើមចូលរួម និង មានយុទ្ធវិធីគ្រប់គ្រងព្រៃឈើដោយឡែករបស់ខ្លួនក្នុងទសវត្សកន្លងមក.

១៨/ គោលបំណងជារួមនៃគោលលំនាំនេះគឺធ្វើឱ្យមានការគ្រប់គ្រងដោយមូលដ្ឋាន ដែលនេះគឺជាសារៈសំខាន់នៃដំណើរការ សហគមន៍ព្រៃឈើដែលបានធ្វើឡើងក្នុងករណីនីមួយៗ. ត្រូវសំរបសំរួលទៅតាមស្ថានភាពនៃធនធានព្រៃឈើធម្មជាតិ, តំរូវការ និង ការប្រើប្រាស់របស់ប្រជាជនជនបទទៅតាមប្រសិទ្ធិភាព ផលប្រយោជន៍នយោបាយ និង សមត្ថភាពគ្រប់គ្រងរបស់សហគមន៍ មូលដ្ឋាន និង ស្ថាប័នពាក់ព័ន្ធ ដើម្បីឱ្យកិច្ចដំណើរការសហគមន៍ព្រៃឈើមានប្រសិទ្ធិភាព. ការធ្វើឱ្យមានការគ្រប់គ្រងដោយ មូលដ្ឋាន គឺធានាថាទិសដៅមូលដ្ឋានមានគ្រប់គ្រាន់សំរាប់រួមបញ្ចូលគ្នានូវរាល់ការគ្រប់គ្រងព្រៃឈើ មានន័យថាប្រជាជននៅសហគមន៍មូលដ្ឋានត្រូវបានផ្តល់សិទ្ធិស្របច្បាប់សំរាប់គ្រប់គ្រងព្រៃឈើ និងទទួលបានចំណែកពីផលប្រយោជន៍ព្រៃឈើសំរាប់ការអភិវឌ្ឍន៍សហគមន៍. ការចូលរួមដោយឥតក្លែងបន្លំទាមទារកិច្ចសហការប្រកបដោយប្រសិទ្ធិភាពក្នុងចំណោមអ្នកប្រើប្រាស់ផ្សេងៗគ្នាដ៏ច្រើនដែលជាតំណាងផលប្រយោជន៍ខុសៗគ្នាក្នុងព្រៃឈើ ហើយដែលម្នាក់ៗមានទិសដៅ ការទទួលខុសត្រូវ និង សមត្ថភាពប្លែកៗគ្នា. កិច្ចដំណើរការ និង បច្ចេទេសដែលសំរួលដល់ទំនាក់ទំនង និង ដំណើរការយកគិតទុកជាមុនក្នុងចំណោមអ្នកប្រើប្រាស់ព្រៃឈើ និង បណ្តាអ្នកប្រាស្រ័យផល( រួមទាំងអាជ្ញាធររដ្ឋាភិបាលសុទ្ធតែមានសារៈសំខាន់សំរាប់ទាញយកការចូលរួមរបស់មូលដ្ឋានក្នុងការគ្រប់គ្រងព្រៃឈើ.

១៩/ សហគមន៍ទាំងឡាយសុទ្ធតែមានហេតុផលក្នុងការធានាខុសត្រូវ និង គ្រប់គ្រងធនធានព្រៃឈើបើសិនជាគេអាចទាញយកផលប្រយោជន៍ពីព្រៃឈើ. ផលប្រយោជន៍របស់សហគមន៍ព្រៃឈើអាចរួមបញ្ចូលៈ

- ការផ្គត់ផ្គង់ឈើហ៊ុប និង អនុផលព្រៃឈើសំរាប់ការប្រើប្រាស់តាមគ្រួសារ និង សំរាប់ការលក់ដូរនៅទីផ្សារ
- ធ្វើឱ្យមានការកើនឡើងច្រើនមុខផ្សេងៗគ្នានូវរបរកសិកម្ម និងសេដ្ឋកិច្ច
- ដោះស្រាយបាននូវតំរូវការខាងវប្បធម៌ និង ជំនឿ
- ទប់មិនឱ្យមានការទាញយកផលប្រយោជន៍ពីព្រៃឈើហួសកំរិតពីបណ្តាសហគមន៍ជនបទ
- បង្កើនការអភិរក្សធនធានធម្មជាតិ និង ស្ថេរភាពប្រពន្ធ័បរិស្ថាន
- ធ្វើឱ្យប្រសើរឡើងថែមទៀតនូវសមត្ថភាពសំរាប់ការចូលរួមគ្រប់គ្រងធនធានធម្មជាតិដ៏ទៃទៀត

២០/ បន្ថែមពីលើផលប្រយោជន៍ទាំងអស់នេះសំរាប់សហគមន៍មូលដ្ឋាន សហគមន៍ព្រៃឈើ អាចមានផលប្រយោជន៍ (បន្ទាប់បន្សំ) មួយបែបទៀតដែលមានសក្តានុពលសំខាន់បំផុតនៅកម្ពុជា. ប្រយោជន៍នោះរួមបញ្ចូលការអភិវឌ្ឍន៍នូវយន្តការ សំរាប់ធ្វើសេចក្តីសំរេចចិត្តសំរាប់សហគមន៍ និង ការដោះស្រាយជំលោះដែលការងារនេះអាចបង្កើនកំលាំងស្អិតជាប់នឹងកិច្ច សហប្រតិបត្តិការរបស់ សង្គម និង បង្កលក្ខណៈងាយស្រួលដល់តំរូវការផ្សេងៗទៀតសំរាប់អភិវឌ្ឍន៍សហគមន៍ព្រៃឈើ. កំលាំងស្អិតជាប់របស់សង្គមអាចក្លាយទៅជាការធ្វើឱ្យប្រសើរឡើងនូវដំណើរការអភិវឌ្ឍន៍ថ្នាក់មូលដ្ឋាន និង ខេត្ត និង បណ្តារចនាសម្ពន្ធ័ដែលបង្កើតការធ្វើ សេចក្តីសំរេចចិត្តតាមបែបវិមជ្ឈការ ហើយការងារទាំងអស់នេះអាចពង្រីកឡើងក្រោមកិច្ចផ្តួចផ្តើមរបស់សហគមន៍ព្រៃឈើ. នៅក្នុងបណ្តាព្រៃសម្បទានការកសាងរចនាសម្ពន្ធ័បែបនេះអាចជួយទ្រទ្រង់ដល់ការដោះស្រាយជំលោះ រវាងសហគមន៍ និង ម្ចាស់ ព្រៃសម្បទាន. រចនាសម្ពន្ធ័ទាំងអស់នេះក៏អាចបង្កើនការកសាងស្ថាប័នកំរិតមូលដ្ឋានដែលបំរើការ ដូចជា យានសំរាប់ត្រួតពិនិត្យដោយឯករាជ្យលើការគ្រប់គ្រងព្រៃសម្បទាន និង តំបន់ការពារ, ធានាថា ទិសដៅ និង តំរូវការរបស់ប្រជាជនមូលដ្ឋានត្រូវបានបង្ហាញឱ្យឃើញនៅក្នុងការគ្រប់គ្រងធនធានរបស់ជាតិ.

២១/ សហគមន៍ព្រៃឈើក៏អាចធ្វើឱ្យធូស្រាលភាពគ្មានដីធ្លី នៅជនបទកម្ពុជាតាមរូបភាពផ្សេងៗជាច្រើនផងដែរ. ជាដំបូង សហគមន៍ព្រៃឈើផ្តល់សុវត្ថភាពដល់សិទ្ធិកាន់កាប់ដីស្របច្បាប់ ចំពោះប្រជាជនកម្ពុជានៅជនបទ និង ជួយពង្រឹងឡើងវិញដល់សិទ្ធិប្រពៃណីនៃដីរបស់សហគមន៍ដែលសិទ្ធិប្រពៃណីនេះ អាចប្រើប្រាស់ប្រឆាំងទល់មុខចំពោះការដណ្តើមកាន់កាប់ដីខុសច្បាប់ ហើយធ្វើឱ្យបាត់សិទ្ធិជាម្ចាស់ដីរបស់ប្រជាជនជនបទ. បន្ថែមលើនេះទៀតដំណើរការកំណត់តំបន់សហគមន៍ព្រៃឈើទាមទារការកំណត់ធនធានតាមរយៈដំណើរការចូលរួមដោយតំលាភាពហើយដែលការងារនេះមិនមែនជាការងាយស្រួលសំរបសំរួលជាលក្ខណៈបុគ្គលឡើយ. ដូច្នេះសហគមន៍ព្រៃឈើផ្តល់នូវមធ្យោបាយសំរាប់កំណត់ធនធានដោយស្មោះត្រង់ហើយអាចទប់ការចាប់យកដីដោយគ្មានយុត្តិធម៌នៅកម្ពុជាបាន. ចុងក្រោយបំផុតសហគមន៍ព្រៃឈើជួយបង្កើនជីវភាពរស់នៅឱ្យមានច្រើនមុខផ្សេងពីគ្នា ហើយសុវត្ថិភាពតាមរយៈសហគមន៍ព្រៃឈើ អាចកាត់បន្ថយភាពគ្មានដីធ្លីដែលកើតមាននៅពេលអាសន្នដែលបណ្តាគ្រួសារឈានដល់ដំណាក់កាលមួយគ្មានជំរើសក្រៅពីលក់ដីសំរាប់ដោះស្រាយតំរូវការក្នុងការចិញ្ចឹមជីវិត.

២២/ គួរកត់សំគាល់ថាដំណើរការចូលរួម និង បច្ចេកទេសគឺជាទំនាក់ទំនងថ្មីមួយបែបក្នុងការគ្រប់គ្រងព្រៃឈើ. តំរូវការ ផ្នែកបណ្តុះបណ្តាល, តំរង់ទិសឡើងវិញ, អនុវត្ត និងការផ្លាស់ប្តូរបទពិសោធន៍ដោយបុគ្គលិកអនុវត្តការងារដល់ទីកន្លែងប្រាកដជាទាមទារឱ្យមានយ៉ាងច្រើនសន្ធឹកសន្ធាប់ដើម្បីសំរេចបានជោគជ័យក្នុងការអនុវត្តដំណើរការ និង បច្ចេកទេសទាំងនេះនៅកម្ពុជា. ដោយសារដំណើរការនេះដូចជាថ្មី វាមាននៅសល់ការសាកល្បងយ៉ាងទូលំទូលាយហើយអ្នកអនុវត្តសុទ្ធតែត្រូវលើកទឹកចិត្តដើម្បីសាកល្បងនូវដំណើរការចូលរួម និង បច្ចេកទេសផ្សេងៗដែលពួកគេចាត់ទុកថាចាំបាច់ក្នុងការពង្រឹងវិធីសាស្ត្រសមស្របសំរាប់សហគមន៍ព្រៃឈើ.

## ២-៤ វិសាលភាពសំរាប់សហគមន៍ព្រៃឈើនៅកម្ពុជា

២៣/ ទំហំសក្តានុពលសំរាប់សហគមន៍ព្រៃឈើនៅកម្ពុជាគឺទូលំទូលាយ. ជាក់ស្តែងប្រជាជនកម្ពុជានៅជនបទទាំងអស់សុទ្ធតែសកម្មក្នុងការប្រើប្រាស់ធនធានព្រៃឈើទាំងនៅជិតភូមិដ្ឋានទាំងនៅឆ្ងាយភូមិ. ការប្រើប្រាស់របៀបនេះ និង បន្តហើយ ពង្រីកក្នុងទសវត្សខាងមុខព្រមជាមួយការកើនឡើងនូវចំនួនប្រជាជន និង ការកើនឡើនូវការប្រកួតប្រជែងធនធាននាំឱ្យ ប្រជាជនមានការ

ផ្លាស់ទីលំនៅទៅរកកន្លែងដែលមានដង់ស៊ីតេប្រជាជនតិច និង ការបើកផ្លូវព្រៃសម្បទានថ្មីៗនេះធ្វើឱ្យចូល ដល់តំបន់ព្រៃដែលមិនធ្លាប់ចូលដល់ពីមុនមក.

២៤/ នៅក្នុងប្រទេសកម្ពុជាសហគមន៍ព្រៃឈើក៏អាចមានសក្តានុពលធំធេងក្នុងការគ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាពផង ដែរ. រដ្ឋភិបាលកម្ពុជាមិនមានហើយក៏ប្រហែលជាមិនទំនងជាមាន.ការអាចយល់ឃើញអនាគតធនធានជាមុនសំរាប់ត្រួតពិនិត្យ និង គ្រប់គ្រងដោយផ្ទាល់លើព្រៃឈើទាំងអស់. នៅពេលដែលបណ្តាម្ចាស់ព្រៃសម្បទានអាចមានលុយ និង បច្ចេកទេស គ្រប់គ្រងដ៏ឆ្នើមនោះការចាប់អារម្មណ៏របស់ពួកគេចំពោះការគ្រប់គ្រងព្រៃឈើ និង ការធ្វើផលិតកម្មឈើនៅមានកំរិតទាបដែល ការនេះបានបន្សល់ឱ្យមានតំបន់ទូលំទូលាយជាច្រើន និង ទិសដៅផ្សេងៗទៀតស្ថិតនៅក្រៅការយកចិត្តទុកដាក់របស់ពួកគេ. ជាមួយនឹងការលើកទឹកចិត្តសមស្របប្រជាជនកម្ពុជានៅជនបទគឺជា ធនធានមនុស្សដ៏ធំបងមួយអាចតំកល់ទុកការគ្រប់គ្រងធនធានព្រៃឈើទាំងអស់ផ្តល់មកនូវការធ្វើឱ្យមានតំលៃយ៉ាងទូលំទូលាយក្នុងការគ្រប់គ្រងព្រៃឈើក្នុងប្រទេស.

២៥/ វិសាលភាពសំរាប់ការអភិវឌ្ឍន៏សហគមន៏ព្រៃឈើនៅក្នុងប្រភេទព្រៃផ្សេងៗគ្នាក្នុងប្រទេសកម្ពុជាគឺ មានទំនាក់ទំនង ខុសគ្នាតាមបញ្ហាស្ថាប័ន, ភាពស្របច្បាប់ និង ការអនុវត្ត

- *តំបន់គ្មានព្រៃ និង តំបន់មិនមែនជាព្រៃសម្បទាន* : នៅក្នុងព្រៃរបៀបនេះទំហំនៃការពង្រីកសហគមន៏ព្រៃឈើមានភាពទូលំទូលាយណាស់ហើយរួមបញ្ចូលសហគមន៏ទាំងអស់ដែលរស់នៅក្នុងម្តុំជិតៗទៅនឹងតំបន់ដែលមិនបានលៃទុកសំរាប់គ្រប់គ្រងជាព្រៃសម្បទានឬតំបន់ការពារ.
- *តំបន់ព្រៃសម្បទាន*: កាលដែលការប្រើប្រស់ព្រៃឈើជាប្រពៃណីត្រូវបានគោរពនោះទំហំសក្តានុពលសំរាប់អភិវឌ្ឍន៏សហគមន៏ព្រៃឈើនៅក្នុងព្រៃសម្បទានគឺស្រដៀងទៅនឹងព្រៃមិនសម្បទានដែរលើកលែងតែសិទ្ធិដែលបានផ្តល់ឱ្យម្ចាស់ព្រៃសម្បទានត្រូវការធ្វើឱ្យស៊ីគ្នាឡើងវិញជាមួយនឹងសិទ្ធិរបស់សហគមន៏. ដើម្បីសំរុះសំរួលសិទ្ធិរបស់ភាគីទាំងពីរគឺសហគមន៏ និង ម្ចាស់ព្រៃសម្បទានសកម្មភាពសហគមន៏ព្រៃឈើចាំបាច់ក្នុងការកំណត់ប្រពៃណីសកម្មភាពព្រៃឈើដែលទទួលស្គាល់ដោយម្ចាស់ព្រៃសម្បទាន និង រដ្ឋាភិបាលក៏ដូចជាសហគមន៏ដែរ. សារៈសំខាន់នៃការសំរុះសំរួលនេះ គឺវាអាចកាត់បន្ថយការពង្រីកទំហំព្រៃឈើដែលប្រើប្រាស់ដោយសហគមន៏សំរាប់កំណើនប្រជាជន និង ការធ្វើឱ្យមានរបរក្នុងព្រៃឈើច្រើនមុខផ្សេងៗគ្នាសំរាប់ការរស់នៅ.
- *តំបន់ការពារ*: មានការខុសគ្នាពីរ យ៉ាងសំខាន់រវាងការអភិវឌ្ឍន៏សហគមន៏ព្រៃឈើ ក្នុង និង ក្រៅតំបន់ការពារ. ទីមួយទិសដៅជាបឋមរបស់តំបន់ការពារគឺអភិរក្សធនធានធម្មជាតិជាជាងការធានារ៉ាប់រងមូលដ្ឋានជីវភាពរស់នៅរបស់សហគមន៏ដែលជា ទ្រឹស្តីគឺកំណត់សិទ្ធិ និង ទំហំសកម្មភាពរបស់សហគមន៏មូលដ្ឋានក្នុងតំបន់ការពារ. ទីពីរ តំបន់ការពារនៅក្នុងប្រទេសកម្ពុជាច្រើន មិនសូវសកម្មក្នុងការគ្រប់គ្រងដូច្នេះ សហគមន៏អាចចេញចូលដោយសេរីក្នុងការរុករកធនធានព្រៃឈើដ៏ច្រើនក្រាស់ក្រែក្នុងតំបន់ ការពារ. ជាលទ្ធផលគឺមានការលើកទឹកចិត្តតិចតួចសំរាប់សហគមន៏ដើម្បីវិនិយោគក្នុងការគ្រប់គ្រង និង ការពារធនធានទាំងអស់នោះ. ផ្ទុយមកវិញការថយចុះនូវការផ្គត់ផ្គង់ឈើក្នុងផ្នែកផ្សេងទៀតនៃប្រទេសបានផ្តល់នូវការលើកទឹកចិត្តមួយសំរាប់ សហគមន៏ដើម្បីវិនិយោគធនធានក្នុងការគ្រប់គ្រងព្រៃឈើ. បន្ថែមលើនេះទៀតរួមផ្សំជាមួយតំរូវការផលិតផលព្រៃឈើក្នុង តំបន់ការពារឡើងខ្ពស់ និង ការងាយយកចេញនូវផលិតផលព្រៃឈើពីតំបន់ព្រៃការពារពីសំណាក់ប្រជាជនដែលក្រៅពីសហគមន៏ មូលដ្ឋានបាន បង្កើត ជាឧបសគ្គក្នុងការគ្រប់គ្រងដោយប្រសិទ្ធិភាពពីសំណាក់សហគមន៏មូលដ្ឋាន.

ការកសាងសហគមន៍ ព្រៃឈើក្នុងតំបន់ការពារនឹង អាចធ្វើបានច្រើនថែមទៀតកាលណាការគ្រប់គ្រងតំបន់ទាំងអស់នេះបាន កំណត់ និង កំរិតបាន នូវការប្រើប្រាស់ធនធានធម្មជាតិព្រម ទាំងជួយកសាង និង ការពារសហគមន៍ព្រៃឈើ.

២៦/ ទំហំនៃការអភិវឌ្ឍន៍សហគមន៍ព្រៃឈើមានឥទ្ធិពលដោយសារកត្តាមួចំនួនបន្ថែមលើកត្តាដែលបានលើកឡើងខាងលើ ចំពោះស្ថាប័នដែលជ្រើសរើសតំបន់ព្រៃទុកជាមុននូវតំបន់ព្រៃ. កត្តាទាំងអស់នេះរួមបញ្ចូលស្ថានការណ៍សេដ្ឋកិច្ច-សង្គមរបស់ សហគមន៍ ដែលបង្កឡើងនូវ សេចក្តីសង្ឃឹមលើធនធានព្រៃឈើសំរាប់ការផ្តល់សេចក្តីត្រូវការជាមូលដ្ឋានក្នុងជីវភាពរស់នៅទាក់ ទងការអាចយកធនធានផ្សេងៗទៀតមកប្រើប្រាស់បានដើម្បីដោះស្រាយតំរូវការទាំងនោះ និង ប្រពៃណី ឬ វប្បធម៌ ក្នុងការ ប្រើប្រាស់ធនធានទាំងនោះ. មានសក្តានុពលដ៏ធំធេងសំរាប់អភិវឌ្ឍន៍សហគមន៍ព្រៃឈើក្នុងតំបន់ព្រៃដែលៈ

- គ្មានទំនាស់កើតមានឡើងអំពីការប្រើប្រាស់ដី.
- សហគមន៍មូលដ្ឋាន និង អាជ្ញាធរមូលដ្ឋានយល់ដឹងអំពីទស្សនៈសហគមន៍ព្រៃឈើ និង ជួយគាំទ្រដល់ការអភិវឌ្ឍន៍ សហគមន៍ព្រៃឈើ.
- មានប្រពៃណីគ្រប់គ្រងធនធានព្រៃឈើរួចមកហើយ
- មានសំពាធលើធនធានធម្មជាតិពេលដែលសហគមន៍ពឹងផ្អែកសំរាប់ដោះស្រាយតំរូវការក្នុងជីវភាពរស់នៅ
- មានជំនាញ និង ធនធានមនុស្សសំរាប់អនុវត្តសហគមន៍ព្រៃឈើគ្រប់គ្រាន់
- មានកំលាំងស្អិតរមួតក្នុងសង្គមសំរាប់អនុវត្តយុទ្ធវិធីមូលដ្ឋានសហគមន៍

២៧/ កន្លងមកថ្មីៗនេះវិសាលភាពនៃសហគមន៍ព្រៃឈើនៅមានកំរិតដោយសារការខ្វះខាតច្បាប់, នយោបាយ និង គំរោង ការរបស់ស្ថាប័ននានាដើម្បីកសាង និង ជួយគាំទ្រសិទ្ធិសំរាប់ការរស់នៅ ឬ សិទ្ធប្រពៃណីក្នុងការប្រើប្រាស់ប្រពៃណីឬមានសិទ្ធី សំរាប់ ប្រតិបត្តិការសហគមន៍ព្រៃឈើ. ជាលទ្ធផលជាមួយនឹងការធានាបន្តិចបន្តួចលើផ្នែកចំណូលសេដ្ឋកិច្ចប្រជាជននៅជនបទ មិនមាន គំនិតក្នុងការវិនិយោធនធានមនុស្សឬធនធានហិរញ្ញវត្ថុក្នុងសហគមន៍ព្រៃឈើទេ. បើសិនជាប្រជាជនត្រូវបានបើក អំណាចជាមួយអាជ្ញាធរគ្រប់គ្រង, ជំនាញផ្សេងៗហើយនឹងបានធានាសិទ្ធិក្នុងការទទួលផលប្រយោជន៍ពីព្រៃឈើនោះវិសាលភាព ដែលមានន័យជាក់លាក់ សំរាប់គ្រប់គ្រងព្រៃឈើដោយនិរន្តរភាពតាមរយៈសហគមន៍ព្រៃឈើ និង កើតមានជាមិនខាន.

# ៣- ការបង្កើតគោលលំនាំសំរាប់សហគមន៍ព្រៃឈើ

## ៣-១-ទិសដៅនៃគោលលំនាំ

២៨/ គោលលំនាំនេះមានគោលបំណងតាមពិតទៅក្នុងការព្យាយាមជាដំបូង គឺផ្តល់នូវយុទ្ធវិធីទូលំទូលាយ និង ការណែនាំ ប្រតិបត្តិដល់សហគមន៍ព្រៃឈើកម្ពុជាក្នុងការទ្រទ្រង់ទិសដៅនយោបាយដែលបានលើកឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បី ក្រសោបយក និង ធ្វើឱ្យមានសហគមន៍ព្រៃឈើ. គោលលំនាំនេះបានលើកឡើងនូវយុទ្ធវិធីធ្វើផែនការ និង ការអនុវត្តន៍ដល់ ទីកន្លែង

ដែលពាក់ពន្ធ័ដល់សហគមន៍ព្រៃឈើ. វាបានកំណត់ចេញនូវរបៀបដោះស្រាយ និង ស្នើឱ្យមានការសំរបសំរួលស្ថាប័ននៅ ថ្នាក់ជាតិ, ថ្នាក់ខេត្ត និង ថ្នាក់មូលដ្ឋានដែលអាចអនុញ្ញាតិឱ្យសហគមន៍ព្រៃឈើដំណើរការបាននៅក្នុងជនបទកម្ពុជា. បន្ថែម លើនេះទៀតគោលលំនាំនេះមានបំណងបង្កលក្ខណៈងាយស្រួលដល់ការអភិវឌ្ឍន៍ជំនាញ និង សមត្ថភាពរបស់រាជរដ្ឋាភិបាល និង បណ្តាអ្នក ពាក់ពន្ធ័ផ្សេងៗទៀតសំរាប់ការរីកចំរើននៃព្រៃឈើ.

ទិសដៅរបស់គោលលំនាំនេះគឺ :

- ដើម្បីបង្ហាញឱ្យស្គាល់ទស្សនៈគន្លឹះ និង វិធីសាស្ត្ររបស់សហគមន៍ព្រៃឈើទាំងឡាយដែលទាក់ទងនឹងការរីកចំរើនសហគមន៍ ព្រៃឈើនៅកម្ពុជា ដើម្បីផ្តល់នូវគំរោងសំរាប់ការចូលរួមដោយសហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព, ដោយផ្អែក លើការផ្ទេរសិទ្ធស្របច្បាប់ និង ការទទួលខុសត្រូវសំរាប់គ្រប់គ្រងដល់សហគមន៍ដើម្បីប្រើប្រាស់ និង ទទួលផលប្រយោជន៍ពីតំបន់ ព្រៃដែលបានជ្រើសរើស ដែលនៅទីនោះពួកគេអាចទទួលបានសកម្មប្រយោជន៍ និង ឯករាជភាព.
- ដើម្បីបង្ហាញផ្លូវក្នុងការធ្វើចលនា និង ពង្រឹងមូលដ្ឋានចាត់តាំងសហគមន៍សំរាប់ការធ្វើផែនការ, ការអនុវត្ត, ការតាមដាន, និងការវាយតំលៃរបស់សហគមន៍ព្រៃឈើ, ទទួលស្គាល់ និង គោរពច្បាប់ប្រពៃណី និង ចំណេះដឹងដែលទាក់ទងការប្រើប្រាស់ និងគ្រប់គ្រងព្រៃឈើ និង ការដាក់បញ្ចូលនារីភេទក្នុងការធ្វើសេចក្តីសំរេចចិត.
- ដើម្បីទ្រទ្រង់ក្នុងការធ្វើឱ្យជ្រះស្រឡះក្នុងការចាត់តាំងមុខងារ ទំនាក់ទំនង និង ការបង្កើតកិច្ចសំរបសំរួល និង សហ ប្រតិបត្តិការក្នុងចំណោមទីភ្នាក់ងាររាជរដ្ឋាភិបាលកម្ពុជា, ពង្រីកកិច្ចសហប្រតិបត្តិការរបស់អង្គការក្រៅរដ្ឋាភិបាល, និងឯកជន ក្នុងការអភិវឌ្ឍន៍សហគមន៍ព្រៃឈើដើម្បីបង្កើនល្បឿនការបង្ហាញនូវបច្ចេកទេសក្នុងស្រុកមួយសមស្របសំរាប់ធ្វើឱ្យផលិតកម្មព្រៃ ឈើកាន់តែល្អប្រសើរឡើង( ដូចជាកសិរុក្ខកម្ម, ធ្វើឱ្យកសិកម្មពនេចរកាន់តែប្រសើរឡើង, ផលិតកម្មកូនឈើ, ឬស្សី និង ផ្តៅ, និង ផលិតកម្មអនុផលព្រៃឈើ....)
- ដើម្បីបង្កើនការវិនិយោគឯកជនដោយចូលរួមជាមួយសហគមន៍ព្រៃឈើ( ដូចជាពាណិជ្ជកម្មដាំឈើ,ផលិតកម្មអនុផលព្រៃ ឈើ និង ការអភិវឌ្ឍន៍ទីផ្សារ, ផលិតកម្មកូនឈើជាលក្ខណៈឯកជន និង ការផ្តើមគំនិតតំរង់ទិសទីផ្សារផ្សេងទៀតដែលអាចជាភាគ បន្ថែម និង ពង្រឹងសហគមន៍ព្រៃឈើ.

## ៣-២ របៀបកសាងគោលលំនាំសហគមន៍ព្រៃឈើ

២៩/ គោលលំនាំនេះបញ្ចូលលាយគ្នានូវដំបូន្មាន និង សំណើពីអ្នកដឹកនាំ និង អ្នកចូលរួមក្នុងគំរោងសហគមន៍ព្រៃឈើនៅ កម្ពុជា, មន្ត្រីផ្លូវការថ្នាក់ជាតិ និង ថ្នាក់ខេត្ត, និង អ្នកមានវិជ្ជាជីវៈជាមួយម្ចាស់ព្រៃសម្បទាន, បណ្តាអង្គការក្រៅរដ្ឋាភិបាល និង បណ្តាអង្គការអន្តរជាតិ. ពតិមានទាំងអស់ត្រូវបានសំរេចយកមកប្រើប្រាស់តាមរយៈការពិគ្រោះនៅក្នុងសិក្ខាសាលាបីលើក ដែលរៀបចំឡើងដោយអង្គកាឌុនសឺនវើលវ៉ាយ និង គំរោងគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព. គោលលំនាំនេះក៏បានទាញយក មេរៀនអំពីបទពិសោធន៍សហគមន៍ព្រៃឈើក្នុងប្រទេសមួយចំនួននៅអាស៊ីពីនេប៉ាល់ដល់ហ្វីលីពីនផងដែរ.

## ៣-៣ ការពង្រីកគោលលំនាំបន្ថែមទៀតនៅពេលខាងមុខ

៣០/ តាមការពិចារណាអំពីការពិតគឺគោលលំនាំនេះបានរៀបចំឡើងនៅពេលដែលច្បាប់ព្រៃឈើកម្ពុជាកំពុងតែត្រូវបានពិនិត្យឡើងវិញ. វាជាការចាំបាច់ក្នុងការពិនិត្យសារឡើងវិញនៅពេលដែលច្បាប់ព្រៃឈើ និង អនុក្រឹត្យដែលជាឯកសារភ្ជាប់ត្រូវបានបញ្ជូនទៅថ្នាក់លើ. គោលលំនាំនេះអាចប្រើប្រាស់ជាមធ្យោបាយសំរាប់ជូនដំណឹងដល់ប្រជាជនមូលដ្ឋានអំពីច្បាប់ និង សិទ្ធិដែលអាចជួយពួកគេនៅក្រោមច្បាប់ថ្មី និងជូនដំណឹងដល់មន្ត្រីរដ្ឋាភិបាលអំពីគោលលំនាំនេះក៏ដូចជាការជូនដំណឹងនូវសិទ្ធិ និង ការទទួលខុសត្រូវរបស់ពួកគេចំពោះសហគមន៍ព្រៃឈើផងដែរ.

៣១/គោលលំនាំនេះក៏ត្រូវការផងដែរនូវការកែលំអលើមូលដ្ឋាននៃ ការសន្ទនាជូនដំណឹងក្នុងចំណោមអ្នកប្រកបមុខវិជ្ជាជីវៈ ព្រៃឈើ និង បណ្ដាអ្នកពាក់ព័ន្ធជាមួយសហគមន៍ព្រៃឈើ ក្នុងការឆ្លើយតបទៅនឹងមេរៀនដែលបានរៀនតាមរយៈការអនុវត្ត ពិសោធន៍. គោលលំនាំនេះត្រូវបានពង្រីកឡើងជាមួយនឹងអ្នកមានវិជ្ជាជីវៈសហគមន៍ព្រៃឈើប៉ុន្តែការសាកល្បងដល់ទីកន្លែង និង ការចំរាញ់ជាថ្មីត្រូវទាមទារឱ្យមានមុនពេលដែលគោលលំនាំនេះ ក្លាយជាឧបករណ៍សំរាប់អនុវត្តដល់ទីកន្លែងដ៏មានប្រសិទ្ធភាពពិត ប្រាកដមួយ. ក្រោយពេលដែលគោលលំនាំត្រូវបានសាកល្បង វាជាការចាំបាច់ដែលត្រូវឱ្យមានការពិភាក្សាម្ដងទៀត. ការពិភាក្សានៅពេលអនាគតអាចវាយតំលៃ និង ដឹកនាំក្នុងការកែលំអរលើភាពមានប្រយោជន៍នៃគោលលំនាំដែលសំរាប់ជាឧបករណ៍អនុវត្តដល់ទីកន្លែងពង្រឹងបន្ថែមដោយលំអិត និង ផ្ដល់ឱកាសក្នុងការពិភាក្សា និង ធ្វើតាមការពិបាក និង កាលៈទេសៈដែលអាចរកឃើញតាមរយៈការប្រើប្រាស់គោលលំនាំនេះនៅក្នុងប្រទេសកម្ពុជា. ហេតុនេះការពង្រឹងគោលលំនាំសហគមន៍ព្រៃឈើគឺជាដំណើរការមួយដែលមិននៅនឹងកន្លែងហើយដែលនឹងទាមទារជាបន្តទៀតនូវពត៌មានអំពីអ្នកមានវិជ្ជាជីវសហគមន៍ព្រៃឈើនៅពេលអនាគតថែមទៀត.

## ៤-ការពិចារណាអំពីយុទ្ធសាស្ត្រសហគមន៍ព្រៃឈើ

៣២/ ដើម្បីយល់ដឹងអំពីវិសាលភាពនៃសហគមន៍ព្រៃឈើសំរាប់ស្ថេរភាពនិង ភាពស្មើគ្នាលើការគ្រប់គ្រងព្រៃឈើនៅកម្ពុជា វាជាការចាំបាច់ក្នុងការបង្កើតឱ្យមានគោលនយោបាយច្បាស់លាស់មួយជាមួយនឹងការទ្រទ្រង់ផ្លូវច្បាប់ដើម្បីកំណត់មុខងារ និង ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធដើម្បីពង្រីកសមត្ថភាពដែលត្រូវទាមទារក្នុងការបំពេញតួនាទី និង ការទទួលខុសត្រូវទាំងអស់ នេះ. ផ្នែកនេះដាក់នូវបញ្ហាយុទ្ធសាស្ត្រគន្លឹះ និង ដាក់បន្ថែមទៀតនូវយន្ដការសំរាប់ដំណើរការកសាងផែនការ និង គ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព.

### ៤-១ ការអភិវឌ្ឍន៍ច្បាប់ និង គោលនយោបាយ

៣៣/ដោយទទួលស្គាល់សក្ដានុពលសហគមន៍ព្រៃឈើសំរាប់ជាវិភាគទានក្នុងការកែលំអការគ្រប់គ្រងព្រៃឈើ នៅដើមឆ្នាំ ១៩៩៩ រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្ដើមបទបញ្ញតិនយោបាយមួយដើម្បីកំណត់ទំហំ និង វិសាលភាពសហគមន៍ព្រៃឈើនៅក្នុង ប្រទេស. សិក្ខាសាលាមួយត្រូវបានបើកឡើងក្នុងឆ្នាំ ១៩៩៩ ដែលប្រមូលគំនិត និង ទស្សនៈពីបណ្ដាអ្នកពាក់ពន្ធ័យ៉ាងច្រើន. ការផ្ដួចផ្ដើមបន្តគឺនៅក្នុងទំរង់នៃការទ្រទ្រង់ដល់ជួរកម្មវិធី និង គ្រោងការណ៍បរទេសដែលស្វែងរកការជួយទ្រទ្រង់ដល់សហគមន៍

ព្រៃឈើតាមរបៀបផ្សេងៗ. ការអភិវឌ្ឍន៍នយោបាយដែលបានធ្វើជាចំបងនៅក្នុងសណ្ឋាននៃការធ្វើព្រាងច្បាប់, នៅពេលដែលសេចក្តីថ្លែងការណ៍នយោបាយដូចជាមិនទាន់បានបង្កើតឡើងនៅឡើយ. នយោបាយរបស់រដ្ឋាភិបាលមានន័យកំបាំងក្នុងព្រាង ច្បាប់, ពិសេសសេចក្តីសំរេច និង សេចក្តីបង្គាប់របស់រដ្ឋាភិបាល, សេចក្តីថ្លែងការដែលធ្វើឡើងដោយសមាជិកជាន់ខ្ពស់របស់ រដ្ឋាភិបាល និង ការអនុវត្តកន្លងមកថ្មីៗក្នុងវិស័យព្រៃឈើ.

៣៤-នៅក្នុងការអភិវឌ្ឍន៍ច្បាប់និងនយោបាយព្រៃឈើបន្តទៅមុខ ការពិចារណាជាបន្តបន្ទាប់ខាងក្រោមនេះ សុទ្ធតែសំខាន់ក្នុងការបង្កើតបរិយាកាសមួយដែលក្នុងនោះសក្តានុពលនៃសហគមន៍ព្រៃឈើជាមធ្យោបាយមួយក្នុងការកែលំអការគ្រប់គ្រងព្រៃឈើអាចនឹងជួបប្រទះ:

- គួរបង្កើតឱ្យមានលក្ខខណ្ឌសំរាប់ការទទួលស្គាល់នូវសិទ្ធិរបស់ប្រជាជនមូលដ្ឋាននិងដើម្បីសំរេចឱ្យសហគមន៍ដែលបានបង្ហាញសមត្ថកិច្ចក្នុងការគ្រប់គ្រងព្រៃឈើជាមួយនឹងសិទ្ធិរបស់អ្នកប្រើប្រាស់ដីព្រៃឈើ . ផលប្រយោជន៍ដែលបានមកពីការគ្រប់គ្រងដីព្រៃឈើដល់សហគមន៍មិនគួរកំរិតត្រឹមគ្រប់គ្រាន់តែចិញ្ចឹមជីវិតនោះទេ ប៉ុន្តែគួរអនុញ្ញាតិឱ្យសហគមន៍ពឹងផ្អែកជីវភាពរស់នៅរបស់ពួកគេលើការគ្រប់គ្រងព្រៃឈើដែលឆ្លុះបញ្ចាំងលើមូលដ្ឋានប្រកបដោយនិរន្តរភាព.
- តួនាទីនិងកាទទួលខុសត្រូវរបស់ទីភ្នាក់ងាររដ្ឋាភិបាលផ្សេងៗត្រូវតែកំណត់ឱ្យបានច្បាស់លាស់ និង សមស្រប. ដោយឡែកអាជ្ញាធរដែលសំរេចឱ្យសិទ្ធិប្រើប្រាស់ដីព្រៃជាផ្លូវការដល់សហគមន៍ប្រើប្រាស់ត្រូវតែកំណត់បង្កើតឱ្យមាននៅថ្នាក់ជាតិ និង ថ្នាក់ ខេត្ត . ដំណើរការពិគ្រោះជាបន្តបន្ទាប់ក្នុងការរៀបចំគោលលំនាំនេះអនុគ្រោះដល់ការសំរបសំរួលដ៏ទូលំទូលាយដូចខាងក្រោម: សំរាប់ព្រៃឈើនៅក្នុងតំបន់ការពារ ក្រសួងបរិស្ថាន មានការទទួលខុសត្រូវដលទីបំផុត. មន្ទីរបរិស្ថានខេត្តគួរមានអំណាចសំរាប់សំរេចឱ្យសិទ្ធិជាអ្នកប្រើប្រាស់ដល់ក្រុមអ្នកប្រើប្រាស់ដែលមានសមត្ថភាព. សំរាប់ព្រៃឈើដ៏ទៃទៀត ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទទទួលខុសត្រូវដល់ទីបំផុត តាមរយៈនាយកដ្ឋានជលផលសំរាប់ព្រៃលិចទឹក និង ព្រៃកោងកាង និង នាយកដ្ឋានរុក្ខា-ប្រមាញ់សំរាប់ព្រៃទាំងអស់ផ្សេងទៀតនៅក្នុងប្រទេស. មន្ទីកសិកម្មខេត្តគួរមានអំណាចក្នុងការសំរេច ឱ្យសិទ្ធិជាអ្នកប្រើប្រាស់ដោយផ្ទាល់ដល់ក្រុមអ្នកប្រើប្រាស់ដែលមានសមត្ថភាព. នាយកដ្ឋានរុក្ខា-ប្រមាញ់ត្រូវតែជាអង្គភាពដឹកនាំសហគមន៍ព្រៃឈើក្នុងប្រទេសជាមួយ នឹងការទទួលខុសត្រូវសំរាប់ការសន្ទនា និង ការសំរបសំរួលអន្តក្រសួង និង អន្តនាយកដ្ឋាន និង ពង្រីកយុទ្ធសាស្រ្តសំរាប់ដំណើរការសហគមន៍ព្រៃឈើទៅតាមបណ្តាខេត្ត.
- គួរបង្កើតឱ្យមានបទបញ្ញាតិ ឬ លក្ខណ្ឌសំរាប់ទីភ្នាក់ងារផ្សេងៗឯទៀតទោះជារបស់រដ្ឋាភិបាល ឬ ក្រៅរដ្ឋាភិបាលក្តីសំរាប់ ដើរតួជាអ្នកផ្តល់ពតិមានក្នុងការទ្រទ្រង់សហគមន៍ក្នុងដំណើរការពង្រីកផែនការគ្រប់គ្រងធនធានព្រៃឈើ និង ការអនុវត្តសំរាប់សិទ្ធិអ្នកប្រើប្រាស់. វាគួរតែបង្កើតឱ្យច្បាស់លាស់ថា ទីភ្នាក់ងាររដ្ឋាភិបាលផ្សេងទៀតដូចជា ក្រសួងអភិវឌ្ឍន៍ជនបទ និង ក្រសួងកិច្ចការ នារី និង អតីតយុទ្ធជនក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលគួរតែត្រូវបានអនុញ្ញាតិក្នុងការជួយផ្តល់ជំនួយការដល់សហគមន៍ដូចដែលគេ អាចបញ្ចូលជាមួយគ្នានៅក្នុងការងារអភិវឌ្ឍន៍ជនបទរបស់ទីភ្នាក់ងារទាំងអស់នោះ.
- សំរាប់ការដោះស្រាយទំនាស់គួរបង្កើតឱ្យមានអង្គការមួយដែលមានអំណាចក្នុងការធ្វើសេចក្តីសំរេចដល់កំពូល និង ចាត់តាំងបណ្តាទីភ្នាក់ងារផ្សេងៗដែលអាចដើតួរមចំណែកក្នុងការសំរបសំរួលដើម្បីដំណើរការដោះស្រាយទំនាស់ដែលកើតមានទាំងឡាយ.

**៤-២ បញ្ហាស្ថាប័ន**

៣៥/ នៅក្នុងការបញ្ចូលក្រុមអ្នកប្រាស្រ័យផលដ៏ច្រើនផ្សេងៗគ្នា ការគាំទ្រ និង ដំណើរការនៃសហគមន៍ព្រៃឈើអំពាវនាវឱ្យមានការរៀបចំយន្តការសហប្រតិបត្តិការមួយនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និង ថ្នាក់មូលដ្ឋាន. បទពិសោធន៍នៅថ្នាក់ជាតិ និង ថ្នាក់ខេត្តនៅកម្ពុជាកន្លងមកថ្មីៗនេះបានបង្ហាញឱ្យឃើញថា ការកំណត់តួនាទី និង ការទទួលខុសត្រូវក្នុងចំណោមស្ថាប័នគ្រប់ផ្នែកក្នុងរដ្ឋាភិបាលគឺមានការខុសឆ្គងដែលបង្កជាការបំពេញភារកិច្ចជាន់គ្នានៅក្នុងក្រសួង និង នាយកដ្ឋានផ្សេងៗ. ការពិបាកទាំងនេះទាមទារកិច្ចសហប្រតិបត្តិការ និង ការដឹកនាំដ៏មានកិរិតមួយដើម្បីឱ្យឈ្នះរាល់ការពិបាកទាំងនោះហើយត្រូវ អនុវត្តន៍រួមគ្នាក្នុងការបង្កើតការសំរបសំរួលឬគណៈកម្មាធិការដឹកនាំចំរុះដើម្បីបំពេញតួនាទីទាំងអស់នេះ. នៅក្នុងការអនុវត្តន៍ គណៈកម្មាធិការរបៀប នេះភាគច្រើនច្រើនតែធ្វើការងារតែលើក្រដាស តាមការពិតវាត្រូវទាមទារឱ្យមានសេចក្តីសាទរ, ការធ្វើ ឱ្យរំភើប, ថវិកា, ទីកន្លែង និង ធនធានមនុស្សសំរាប់មុខងាររបស់ពួកគេ. ដូច្នេះត្រូវតែមានការប្រុងប្រយត្ន័ក្នុងការស្នើបង្កើតឱ្យ មានគណៈកម្មាធិការថ្មីណាមួយ.

៣៦/ បណ្តាអ្នកចូលរួមក្នុងសិក្ខាសាលាដែលបានធ្វើឡើងដើម្បីរៀបចំគោលលំនាំសហគមន៍ព្រៃឈើនេះបានស្នើរឱ្យមានការបង្កើតគណៈកម្មាធិការទាំងនេះដែលមានមុខងារផ្សេងៗគ្នាដូចតទៅ:

**<u>គណៈកម្មាធិការចំរុះដឹកនាំសហគមន៍ព្រៃឈើថ្នាក់ជាតិ</u>**

គណកម្មកាធិការនេះមានតួនាទីសំរបសំរួលការធ្វើផែនការ និង អនុវត្តសកម្មភាពនឹងលើកឡើងពីបញ្ហាក្នុងអន្តរក្រសួងដែលពាក់ពន្ធ័សហគមន៍ព្រៃឈើ. គណៈកម្មាធិការនេះរួមបញ្ចូលតំណាងមកពីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ, ក្រសួង បរិស្ថាន, ក្រសួងអភិវឌ្ឍន៍ជនបទ ហើយនឹងក្រសួងរៀចំផែនដីនគររូបនីយកម្ម និង សំណង់. មុខងាររបស់គណៈកម្មាធិការចំរុះ នេះគឺ:

- ផ្លាស់ប្តូរពត៌មាន, លើកទឹកចិត្ត និង បង្កលក្ខណៈងាយស្រួលដល់ការសំរបសំរួលក្នុងចំណោមទីភ្នាក់ងារគន្លឹះទាំងឡាយ.
- បញ្ជាក់សមត្ថកិច្ច និង តួនាទីរបស់បណ្តាទីភ្នាក់ងារទាំងឡាយ.
- ធានាស្ថេរភាពក្នុងកិច្ចប្រតិបត្តិការគោលលំនាំសហគមន៍ព្រៃឈើ, ផ្សព្វផ្សាយ, ទ្រទ្រង់សំភារៈ និង បច្ចេកទេស និង ទ្រទ្រង់អភិវឌ្ឍន៍សហគមន៍ព្រៃឈើផ្តល់អនុម័ត, តាមដាន និង វាយតំលៃការអនុវត្តន៍.
- ធានាលើការរួមបញ្ចូលគ្នានូវការខិតខំ និង អភិវឌ្ឍន៍ធនធានក្នុងកិច្ចដំណើរការសកម្មភាពសហគមន៍ព្រៃឈើទូទាំង ប្រទេស.
- សហប្រតិបត្តិការជាមួយនឹងលេខាធិការដ្ឋានកែទំរង់គោលនយោបាយព្រៃឈើ, ទ្រទ្រង់ការសំរបសំរួលដែលចាប់ផ្តើមឡើងអំពីអង្គការអន្តរជាតិក្រៅរដ្ឋាភិបាល និង អង្គការក្រៅរដ្ឋាភិបាល.

៣៨/យកបង្កើតឱ្យមាននិង បន្តមុខងាររបស់គណៈកម្មាធិការនេះទាមទារឱ្យមានការបង្កើតទីភ្នាក់ងារមួយដែលត្រូវមានតួនាទីទទួលខុសត្រូវក្នុងការរៀបចំប្រជុំ និង ចែកចាយរាល់សេចក្តីសន្និដ្ឋានរបស់អង្គប្រជុំ និង ផ្តល់នូវហិរញ្ញវត្ថុចាំបាច់ (ថ្វីបើតិចតួចដែលការសំរាប់ការប្រជុំ និង ចែកចាយពិតមាន)

**<u>គណៈកម្មាធិការចំរុះដឹកនាំសហគមន៍ព្រៃឈើថ្នាក់ខេត្ត</u>**

៣៩/ ស្ថានភាពស្ថាប័ននៅខេត្តនីមួយៗមានការប្រែប្រួលយ៉ាងខ្លាំង និង មានអំណាចក្នុងចំណោមកិច្ចការផ្សេងៗដែលទាក់ទងទៅនឹងភាពខ្លាំងឬខ្សោយតាមមន្ទីជំនាញនានានៅក្នុងខេត្ត តាមក៏រិត និងតាមប្រភេទនៃអ្នករៀបចំកម្មវិធីទ្រទ្រង់ និង លក្ខណៈពិសេសនៃប្រជាជននៅក្នុងខេត្ត.

៤០/គណៈកម្មាធិការចំរុះដឹកនាំសហគមន៏ព្រៃឈើតាមមន្ទីជុំវិញខេត្តអាចរួមបញ្ចូលនាយក និង បុគ្គលិកដែលបានចាត់តាំងសមស្របអំពីបណ្តាមន្ទីក្នុងខេត្តដែលមានជាអាទិ៍មន្ទីកសិកម្មរុក្ខាប្រមាញ់ និង នេសាទ(រួមមានការិយាល័យរុក្ខា-ប្រមាញ់, ការិយាល័យផ្សព្វផ្សាយកសិកម្ម និងការិយាល័យជលផល (បើសិនជានៅក្នុងខេត្តនោះមានព្រៃលិចទឹក និង ព្រៃកោងកាង) មន្ទីអភិវឌ្ឍន៏ជនបទ មន្ទីផែនការ និងមន្ទីបរិស្ថាន(បើសិនជាក្នុងខេត្តនោះមានតំបន់ការពារធម្មជាតិ). នៅពេលរៀបចំគោលលំនាំសហគមន៏ព្រៃឈើនេះមិនទាន់បានយកចិត្តទុកដាក់ឱ្យបានសមស្របក្នុងការព្យាយាមបង្កើតស្ថាប័នទទួលខុសត្រូវមួយសំរាប់ធ្វើសេចក្តីសំរេចចិត្តឬបង្កើតគណៈកម្មធិការណាមួយមានសមត្ថកិច្ចក្នុងការសំរេចនៅតាមខេត្តណាមួយទេ. យ៉ាងណាក៏ដោយ គួរតែឱ្យមានមន្រ្តីផ្លូវការសមស្របសំរាប់ខេត្តសំខាន់ណាមួយដើម្បីបង្កើតជាគណកម្មាធិការដូចខាងលើ បើសិនគេយល់ថាសកម្ម ភាពរបស់ពួកគេទាមទារសំរបសំរួល និង ការឯកភាពលើការរួមចំណែកក្នុងការទទួលខុសត្រូវកិច្ចដំណើការគណៈកម្មាធិការ ខាងលើនេះ.

<u>**ការកសាងសមត្ថភាព**</u>

៤១/ សមត្ថភាពសំរាប់ចូលរួមធ្វើផែនការសហគមន៏ព្រៃឈើត្រូវតែបានពង្រឹងនោថ្នាក់ជាតិ, ថ្នាក់ខេត្ត និង ថ្នាក់មូលដ្ឋានដើម្បីឱ្យមានប្រសិទ្ធិភាពក្នុងការធ្វើចលនាសហគមន៏ព្រៃឈើទូទាំងប្រទេស. ដោយឡែកបើសិនជាផ្តល់ការទទួលខុសត្រូវលើការដឹកនាំសហគមន៏ព្រៃឈើនាយកដ្ឋានរុក្ខា-ប្រមាញ់នោះវាទាមទារឱ្យមានការតំរង់ទិសឡើងវិញ និង កសាងសមត្ថភាពយ៉ាងទូលំទូលាយបន្ថែមទៀតដើម្បីឱ្យពួកគេអាចបំពេញតួនាទីក្នុងការទ្រទ្រង់កិច្ចអភិវឌ្ឍន៏សហគមន៏ព្រៃឈើក្នុងតំបន់ព្រៃដ៏ច្រើននៅក្នុងប្រទេសបាន. យ៉ាងណាក៏ដោយដំណើរការដែលអាចបត់បែនបានមួយត្រូវយកមកប្រើសំរាប់អនុញ្ញាតិឱ្យមានការចូលរួម ពីបណ្តាទីភ្នាក់ងារផ្សេងៗ ដែលមានបុគ្គលិកគ្រប់គ្រាន់ និង មានជំនាញសហគមន៏ព្រៃឈើសមស្របដើម្បីដើម្បីឱ្យមានការចូល រួមក្នុងការផ្តួចផ្តើម និង ទ្រទ្រង់សហគមន៏ព្រៃឈើ.

**៤-៣ ការធ្វើផែនការដោយមានការចូលរួម**

៤២/ ការរីកចំរើន និង ការយល់ដឹងដ៏ទូលំទូលាយអំពីសហគមន៏ព្រៃឈើនៅក្នុងប្រទេសទាមទារ ប្រពន្ធ័កសាងផែនការ និង ផលឆ្លើយតប. ដំណើរការចូលរួមត្រូវបានស្នើឡើង ដែលដំណើរការនោះអាចបំពេញបន្ថែមគោលបំណងសំខាន់បួនដូច ខាងក្រោម:

- ដើម្បីផ្សារភ្ជាប់បណ្តាអ្នកប្រាស្រ័យផលធនធានព្រៃឈើក្នុងដំណើរការជាសាធារណៈមួយសំរាប់ការបង្កើត និង ការវិភាគផលប្រយោជន៏ផ្សេងៗនៃធនធានព្រៃឈើ, ការអះអាង, ទិសដៅ និង ការគ្រប់គ្រងដ៏ទៃទៀត.
- ដើម្បីបង្កើនការយល់ដឹង និង ការគោរពគ្នាទៅវិញទៅមកក្នុងចំណោមអ្នកប្រាស្រ័យធនធានព្រៃឈើផ្សេងៗគ្នាដែលជា មូលដ្ឋានសំរាប់ពង្រឹង និង ទ្រទ្រង់ការគ្រប់គ្រងធនធានព្រៃឈើជាទូទៅ.

- ដើម្បីបង្ហាញ និង ចង្អុលចរិតលក្ខណៈតំបន់ព្រៃដែលសហគមន៍មូលដ្ឋានបានអះអាងឬទទួលផលស្របច្បាប់ឬតំបន់ព្រៃដែលមានសក្តានុពលសំរាប់ធ្វើឱ្យការគ្រប់គ្រងកាន់តែប្រសើឡើងតាមរយៈសហគមន៍ព្រៃឈើ.
- ដើម្បីជួយឱ្យការវាយតំលៃ និងការជ្រើសរើសព្រៃដោយឡែកសំរាប់សហគមន៍ទុកជាមុនអាចធ្វើទៅបានដោយសម ស្របនៅក្នុងការកំណត់ព្រំដែនច្បាស់លាស់ដោយមានការចូលរួម និង ការធ្វើគំរោងសេចក្តីសំរេចដោយតំលាភាព.
- គំរោងដែលសមស្របសំរាប់ការចូលរួមធ្វើផែនការមួយដែលគេបានស្គាល់រួចមកហើយគឺការធ្វើផែនការប្រើប្រាស់ដីដោយមានការចូលរួម. គំរោងនេះផ្តល់នូវការសំរបសំរួល និង ការផ្លាស់ប្តូរពត៌មានក្នុងចំណោមអ្នកប្រាស្រ័យផល ឬអ្នកពាក់ពន្ធ័តាមកំរិតផ្សេងៗគ្នាដូចដែលបានកំណត់ចេញនៅក្នុងតារាងទីមួយ. ការធ្វើផែនការប្រើប្រាស់ដីដោយមានការចូលរួមនេះទ្រទ្រង់ការធ្វើសេចក្តីសំរេចតាមរបៀបរិមជ្ឈការដែលទទួលខុសត្រូវចំពោះតំរូវការរបស់ក្រុមអ្នកប្រាស្រ័យផលភាគច្រើនដែលបានទទួលឥទ្ធិពលដោយផ្ទាល់ពីក្រុមអ្នកប្រើប្រាស់ព្រៃឈើ. លក្ខណៈគន្លឹះសំរាប់ជំរុញការចូលរួមរបស់មូលដ្ឋានគឺត្រូវអនុវត្តន៍គោលការណ៍ពីក្រោមឡើងលើដែលផ្ទុយ និង គោលការណ៍ពីលើចុះក្រោម. ហេតុដូច្នេះជាមួយ និង ការផ្លាស់ប្តូរពត៌មានសមស្របដំណើរការកសាងផែនការគឺជាការបញ្ចូលគ្នាជាមួយនឹងផ្តល់អាទិភាពឱ្យសំដែងមតិ និង ជាការចាប់អារម្មណ៍របស់ប្រជាជនជនបទក្នុងការឆ្លើយតបទៅខាងលើ និង ជាការយល់ដឹងពេញលេញ ក្នុងការធ្វើសេចក្តីសំរេចចិត្ត និង ការបង្កបង្កើតគោលនយោបាយ.

| ថ្នាក់ | អ្នកណាចូលរួម? | មុខងារកសាងផែនការ |
|---|---|---|
| ជាតិ | បណ្តាក្រសួងដែលទទួលខុសត្រូវលើៈ<br>• ព្រៃឈើ ( ជាសំខាន់: កសិកម្មរុក្ខា - ប្រមាញ់ និង នេសាទ និង ស្រួងបរិស្ថាន )<br>• អភិវឌ្ឍន៍ជនបទ( ជាសំខាន់: អភិវឌ្ឍន៍ ជនបទអាចក្រសួងទេសចរណ៍ និង ក្រសួង កិច្ចការនារីផងដែរ .<br>• ស៊ុរិយោដី គណៈកម្មាធិការចំរុះអន្តរក្រសួង<br>• ស្ថាប័នជាតិផ្នែកច្បាប់ និង នយោបាយ នយោបាយ( សភាជាតិ, នាយករដ្ឋមន្រ្តី, តុលាការ | • កំណត់យុទ្ធសាស្រ្ត និង ទិសដៅរបស់ជាតិបញ្ជាក់ក្នុងគោលនយោបាយ និង គោលលំនាំរបស់ជាតិ<br>• ថ្លឹងថ្លែងការប្រកួតប្រជែងផលប្រយោជន៍ក្នុងវិស័យផ្សេងៗគ្នានៃសេដ្ឋកិច្ច, ដោះស្រាយទំនាស់នៅថ្នាក់ក្រោម<br>• កំណត់សមត្ថកិច្ច និង អាណត្តិរបស់បណ្តាទីភ្នាក់ងារ, តាម តំបន់ និង ភូមិភាគ( ខេត្ត, ចំរុះខេត្ត, និង អនុខេត្ត)<br>• កំណត់តួនាទី និង ការទទួលខុសត្រូវរបស់ទីភ្នាក់ងាររដ្ឋា ភិបាល, សហគមន៍មូលដ្ឋានផ្នែកឯកជន, គ្រួសារ .ល.<br>• សំរបសំរួលយុទ្ធសាស្រ្ត និង សកម្មភាពរបស់ទីភ្នាក់ងាររដ្ឋាភិបាលតាមតំបន់ និង ភូមិភាគ<br>• លៃលកធនធានសំរាប់តំបន់ និង ភុមិភាគផ្សេងគ្នា<br>• រៀបចំ និង ដាក់ឱ្យប្រតិបត្តិស្របច្បាប់គំរោងអភិបាលកិច្ចសំរាប់សហគមន៍ព្រៃឈើថ្នាក់ជាតិ |
| ខេត្ត | ទីភ្នាក់ងារនៅថ្នាក់ខេត្តទទួលខុសត្រូវលើការងារ : | • សំរបសំរួលយុទ្ធសាស្រ្តជាតិនៅថ្នាក់ខេត្ត<br>• កំណត់អាទិភាពខេត្ត |

| | | |
|---|---|---|
| | • ព្រៃឈើ<br>• អភិវឌ្ឍន៍ជនបទ<br>• គណៈកម្មាការចំរុះរៀបចំផែនការ<br>• សហគមន៍ព្រៃឈើថ្នាក់ខេត្ត, ស្ថិតនៅក្រោមគណៈកម្មាធិការអភិវឌ្ឍន៍ខេត្ត | • បណ្តុះបណ្តាល និង ជួយទ្រទ្រង់បុគ្គលិកសហ គមន៍ព្រៃឈើស្រុក ឃុំ និង មូលដ្ឋាន សំរាបកសាងផែនការសហគមន៍ព្រៃឈើ<br>• រៀបចំផែនការកំណត់ទុកដាក់ធនធានសំរាប់ស្រុក ឃុំ និង មូលដ្ឋាន ផ្តល់លទ្ធផលឆ្លើយតបទៅថ្នាក់ ជាតិអំពីដំណើរការ និង ការអនុវត្តផែនការ<br>• ដោះស្រាយជំលោះរវាងក្រុមមូលដ្ឋាន និង ធ្វើជាអ្នកកណ្តាលរវាងថ្នាក់មូលដ្ឋាន និង ថ្នាក់ជាតិ<br>• ពិនិត្យឡើងវិញ និង អនុម័តលើផែនការថ្នាក់ ក្រោមខេត្ត រួចផែនការថ្នាក់មូលដ្ឋាន |
| ស្រុក, ឃុំ | ទីភ្នាក់ងារថ្នាក់ស្រុក និង ឃុំ តំណាងរបស់ថ្នាក់មូលដ្ឋាន | • សំរបសំរួលយុទ្ធសាស្ត្រខេត្តនៅថ្នាក់ស្រុក និង ឃុំ<br>• កំណត់អាទិភាពស្រុក, ឃុំ<br>• បណ្តុះបណ្តាល និង ទ្រទ្រង់បុគ្គលិកសហគមន៍ព្រៃឈើនៅថ្នាក់មូលដ្ឋានក្នុងការកសាងផែនការ សហគមន៍ព្រៃឈើ<br>• ពិនិត្យផ្ទៀងផ្ទាត់ផែនការរបស់មូលដ្ឋាន<br>• សហប្រតិបត្តិការក្នុងការអនុវត្តគំរោងធំទូលាយ<br>• ផ្តល់លទ្ធផលឆ្លើយតបទៅថ្នាក់លើអំពីដំណើរការកសាងផែនការ និង ការអនុវត្ត<br>• ដោះស្រាយជំលោះ រវាងក្រុមមូលដ្ឋាន និងធ្វើជាអ្នកកណ្តាលរវាងថ្នាក់មូលដ្ឋាន និងថ្នាក់ខេត្ត |
| មូលដ្ឋាន ភូមិ អន្តរៈភូមិ | អ្នកដឹកនាំថ្នាក់មូលដ្ឋាន, អ្នកប្រើប្រាស់ ព្រៃឈើ, តំណាងអ្នកប្រាស្រ័យផល | • ធ្វើសារពើភណ្ឌ និង វិភាគធនធានដែលមាន<br>• ទំនាក់ទំនងជាមួយអ្នកប្រើប្រាស់ព្រៃឈើនៅមូលដ្ឋាន និង អ្នកប្រាស្រ័យផល<br>• រៀបចំផែនការមូលដ្ឋាន<br>• រៀបចំផ្ទៃដីសំរាប់ការប្រើប្រាស់ខុសៗគ្នា<br>• អនុវត្តផែនការ និង សកម្មភាព<br>• តាមដាន និង វាយតំលៃ និង ការអនុវត្ត |

ដំណើរការកសាងផែនការដោយមានការចូលរួម គឺជាការរួមបញ្ចូលលការងារ ប្រមូល, វិភាគ និង ការបញ្ចូលពត៌មានពី ថ្នាក់ខុសគ្នាគឺ ថ្នាក់មូលដ្ឋាន ថ្នាក់ខេត្ត និង ថ្នាក់ជាតិ និង ទៅតាមប្រភេទខុសៗគ្នាគឺ បរិស្ថាន សង្គម និង រដ្ឋបាលអំពីក្រុមអ្នក ប្រាស្រ័យផលផ្សេងៗ. ក្រុមអ្នកប្រាស្រ័យផលដែលចូលរួមក្នុងការកសាងផែនការរួមមានៈ សហគមន៍មូលដ្ឋាន អ្នកប្រើប្រាស់ ព្រៃឈើផ្សេងទៀត ទីភ្នាក់ងាររដ្ឋាភិបាលនៅមូលដ្ឋាន ខេត្ត និង ថ្នាក់ជាតិ ម្ចាស់ជំនួយ និង ទីភ្នាក់ងារជំនួយការបច្ចេកទេស ដែល ធ្វើសហប្រតិបត្តិការជាមួយសហគមន៍មូលដ្ឋាន ឬ ទីភ្នាក់ងាររដ្ឋាភិបាល. ក្នុងការធ្វើផែនការសហគមន៍ព្រៃឈើ ក្រុមអ្នក ប្រាស្រ័យផល ចូលរួមផ្តល់ទស្សនៈវិស័យរបស់គេ ទិសដៅ និង ការពិបាកទើសទាល់ និង ចូលរួមធ្វើកិច្ចការដើម្បីសំដៅការគាំទ្រ ទូលំទូលាយនិង ឯកភាពលើកិច្ចព្រមព្រៀងជាយុទ្ធសាស្រ្តសំរាប់និរន្តរភាពនៃផលិតភាព និង ជួសជុលធនធានព្រៃឈើនៅតំបន់ ជនបទ. លក្ខណៈសំខាន់មួយនៃការកសាងផែនការនេះគឺវាមានភាពបត់បែន ( មិននៅនឹងកន្លែង) បង្កអាទិភាពក្នុងការផ្លាស់ប្តូរ, មានការឆាប់យល់ដឹង និង មានស្ថានភាពសំរាប់ស្វែងយល់ និង ឆ្លើយតប.

៤៥/ មុខងារដែលចាំបាច់សំរាប់ដំណើរការចូលរួមកសាងផែនការនៅថ្នាក់ជាតិជាសំខាន់គឺការផ្លាស់ប្តូរពត៌មាន និង ការ សំរបសំរួលមុខងារដែលបានអធិប្បាយខាងលើដែលជាតួនាទីរបស់គណៈកម្មាធិការចំរុះដឹកនាំសហគមន៍ព្រៃឈើជាតិ. ការងារ ទាំងនេះគួរឈរលើមូលដ្ឋាននៃលទ្ធផលឆ្លើយតបអំពីថ្នាក់ខេត្ត និង ថ្នាក់មូលដ្ឋាន.

៤៦/ នៅថ្នាក់ខេត្តមុខងារកសាងផែនការជាសំខាន់គឺ រួមចំណែកក្នុងការអភិវឌ្ឍន៍សហគមន៍ព្រៃឈើនៅថ្នាក់ខេត្តដែល ត្រូវលើកទឹកចិត្ត និង ជួយឱ្យទីភ្នាក់ងាររបស់រដ្ឋាភិបាល និង ក្រៅរដ្ឋាភិបាលដើម្បីតំឡើង និង ទ្រទ្រង់សហគមន៍ព្រៃឈើ. កិច្ចការ ដោយឡែកក្នុងការកសាងផែនការនៅថ្នាក់ខេត្ត : បង្កើត និងកំណត់ព្រំដែនលើលក្ខណ្ឌទូទៅ, ព្រំប្រទល់រដ្ឋបាល និង ព្រំប្រទល់ រនៅក្នុងខេត្តរួមមានព្រៃឈើដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្មរុក្ខា ប្រមាញ់ និង នេសាទ ( នាយកដ្ឋានរុក្ខា-ប្រមាញ់ និង នាយកដ្ឋាន ជលផល) ក្រសួងបរិស្ថាន ក្រសួងឯទៀត និង ទីភ្នាក់ងាររដ្ឋបាល និង ឯកជន បង្កើត និង កំណត់ ច្បាស់លាស់ការប្រើប្រាស់ព្រៃឈើ និង ការអះអាងដោយសហគមន៍មូលដ្ឋានតាមរយៈដំណើរការដែលបង្កលក្ខណៈ ងាយស្រួល ក្នុងការចូលរួមរបស់មូលដ្ឋាន និង ការទទួលស្គាល់វប្បធម៌ ប្រពៃណី និង ការអនុវត្តដែលមានស្រាប់ទាក់ ទងទៅនឹងការប្រើប្រាស់ធនធានព្រៃឈើ.

៤៧/ នៅថ្នាក់មូលដ្ឋានដែលមានការគាំទ្រពីស្ថាប័នមានសមត្ថកិច្ចផ្សេងៗ សហគមន៍វាយតំលៃសេចក្តីត្រូវការផ្ទាល់ខ្លួន និង ផលប្រយោជន៍ព្រៃឈើ និង ទទួលខុសត្រូវក្នុងការរៀបចំគ្រប់គ្រងតំបន់ព្រៃនៅមូលដ្ឋាន. នៅពេលដែលការកសាងផែនការ នៅមូលដ្ឋានបញ្ចូលទាំងសមាជិកសហគមន៍ និង អ្នកអនុវត្តសហគមន៍ព្រៃឈើនោះ លក្ខណៈសំខាន់របស់វាគឺសមាជិកសហគមន៍ ធ្វើការជ្រើសរើស និងផ្តល់ពត៌មានចាំបាច់សំរាប់កសាងផែនការ. ផែនការគួរធ្វើឡើងជាភាសានៅមូលដ្ឋាន( ភាសាជាតិ, ប្រើពាក្យពេជន៍ដែលអាចយល់បានដោយក្រុមអ្នកប្រើប្រាស់ព្រៃឈើជាប្រចាំដើម្បីធានាថាផែនការអាចចូលគ្នាចុះជាមួយប្រពៃណី នៅមូលដ្ឋាន. ដើម្បីទ្រទ្រង់ការកសាងផែនការនេះ ការងារមួយចំនួនចាំបាច់ដែលត្រូវធ្វើឡើងដោយអ្នកធ្វេការថ្នាក់ខេត្តនៅតាម តំបន់ភូមិមានៈ

- ផ្តល់ពត៌មានឬជូនដំណឹងដល់ប្រជាជនមូលដ្ឋាន អ្នកដឹកនាំ និង មន្រ្តីផ្លូវការអំពីច្បាប់ និង គោលនយោបាយសហគមន៍ព្រៃ ឈើ បង្កលក្ខណៈងាយស្រួលដល់សហគមន៍ក្នុងការពិភាក្សាចំពោះផលប្រយោជន៍មូលដ្ឋាននៅក្នុងសហគមន៍ព្រៃឈើ, និងកសាង ការទុកចិត្តគ្នាទៅវិញទៅមករវាងអ្នកភូមិ និង បុគ្គលិកអនុវត្តការងារតាមភូមិ.

- ប្រមូលពិតមានអំពីសង្គម និង បច្ចេកទេសលើតំរូវការ និង ការប្រើប្រាស់ព្រៃឈើលើមូលដ្ឋាន ស្ថានភាពព្រៃឈើ និង ប្រពន្ធ័គ្រប់គ្រងព្រៃឈើតាមមូលដ្ឋាដែលមានស្រាប់ដើម្បីកំណត់អ្នកប្រើប្រាស់ព្រៃឈើ និង ក្រុមអ្នកប្រាស្រ័យផល និង រើកញែក សំគាល់ក្រុមអ្នកប្រើប្រាស់ព្រៃឈើផ្ទាល់ និង ប្រយោល.
- កំណត់គន្លឹះក្នុងការគ្រប់គ្រង និង ប្រើប្រាស់ព្រៃឈើ វាយតំលៃលក្ខណៈនៃការគ្រប់គ្រងព្រៃឈើ និង ពង្រីកផែនការ ព្រមទាំងជំនាញគ្រប់គ្រងព្រៃឈើដោយសហគមន៍មូលដ្ឋាន.
- បង្កលក្ខណៈងាយស្រួលក្នុងការកសាង និង ដំណើរការនៃការចាត់តាំងមូលដ្ឋានសហគមន៍សំរាប់សហគមន៍ព្រៃឈើ.
- បង្កើត និង កំណត់ព្រំប្រទល់ព្រៃដែលជាតំរូវការសំរាប់ការជ្រើសរើសសហគមន៍ព្រៃឈើ.

## ៤-៤ ការទ្រទ្រង់សហគមន៍ព្រៃឈើ

៤៨/មួយភាគធំនៃការទ្រទ្រង់សហគមន៍ព្រៃឈើគឺការទាមទារឱ្យមានការចូលរួមរបស់ស្ថាប័ននានាក្នុងកម្មវិធីសហគមន៍ព្រៃឈើនៅកម្ពុជាដើម្បីបានសំរេចលើសមត្ថភាពដែលត្រូវការ និង ចេញជាកម្មវិធីប្រសិទ្ធិភាពមួយទូទាំងប្រទេស. កន្លង មកមានការទ្រទ្រង់សហគមន៍ព្រៃឈើដែលបានផ្តល់ដោយអង្គការជាតិ អន្តរជាតិមួយចំនួន ដែលធ្វើការនៅតាមថ្នាក់ផ្សេងៗ. ការទ្រទ្រង់ដែលត្រូវការរួមមាន ការផ្តល់ពិតមាន និង ការទ្រទ្រង់បច្ចេកទេសក្នុងតំបន់ដូចជា រុក្ខវិប្បកម្ម, ការរៀបចំថ្នាលបណ្តុះ, ការដោះស្រាយទំនាស់ និង បញ្ហាស្ថាប័ន. សេចក្តីសង្ខេបអំពីតំរូវការពិតមាន និង បច្ចេកទេស នឹងបង្ហាញនៅក្នុងតារាងទី២ ហើយ និង តំបន់គន្លឹះដែលទាមទារការជួយគាំទ្រ និង បកស្រាយនៅខាងក្រោម .

## ការកសាងផែនការសំរាប់សហគមន៍ព្រៃឈើដោយមានការចូលរួម

៤៩/ មធ្យោបាយសំរាប់បង្កើតប្រពន្ធ័កសាងផែនការដោយមានការចូលរួមតាមពិតគឺ ការបញ្ចូលគ្នារវាង ថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់មូលដ្ឋាន ដែលនឹងអាចប្រើជាក្រុមការងារអន្តរក្រសួងមួយ ដែលអាចរួមបញ្ចូលក្រុមអ្នកផ្តល់ជំបូន្មានមកអំពីអ្នកគាំ ទ្រកម្មវិធីអន្តរជាតិ និង អង្គការក្រៅរដ្ឋាភិបាល. តាមការត្រឹមត្រូវការងារអន្តរក្រសួងខាងលើនេះអាចកសាងសម្ពន្ធ័ភាពជាមួយ នឹងអង្គការចាត់តាំងនៅថ្នាក់ខេត្តហើយនឹងអាចពង្រីកកម្មវិធីនៅតាមទីកន្លែងដែលរួមមានៈ

- ផ្តល់នូវឯកសារស្តីពីការធ្វើផែនការប្រើប្រាស់ដីដោយមានការចូលរួម.
- ផ្លាស់ប្តូរបទពិសោធន៍ក្នុងការកសាងផែនការប្រើប្រាស់ដីដោយមានការចូលរួមក្នុងចំណោមទីកន្លែងផ្សេងៗគ្នា នៅក្នុង ខេត្ត និង នៅក្នុងប្រទេសផ្សេងទៀតដែលសំបូរទៅដោយបទពិសោធន៍ក្នុងការកសាងផែនកាប្រើប្រាស់ដីដោយមានការចូលរួម.
- ជួយគាំទ្រដលអង្គការរបស់ រដ្ឋាភិបាលក្នុងការដឹកលំជំហានទ្រទ្រង់សំខាន់ៗ
- ជួយគាំទ្រដល់ ការផ្តួចផ្តើមរបស់លមូលដ្ឋាន ក្នុងការពង្រីកទំរង់ ការសំរបសំរួលក្នុងការធ្វើផែនការប្រើប្រាស់ដីដោយ មានការចូលរួមសមស្របសំរាប់បរិបទឆ្លងវប្បធម៌នៅក្នុងតំបន់ដែលមានជនជាតិភាគតិចតាមតែអាចប្រព្រឹត្តិទៅបានដោយយកលំនាំ តាមវិធីសាស្ត្រដែលបានអនុវត្ត នៅក្នុងបណ្តាប្រទេសផ្សេងៗទៀត.
- ពង្រីកគោលលំនាំសំរាប់កសាងផែនការប្រើប្រាស់ដីដោយមានការចូលរួមដែលទទួលស្គាល់បានជាផ្លូវការ ហើយនឹង អាចជាជំនួយពេញលេញក្នុងការអនុវត្តដល់ទីកន្លែងលើការងារបច្ចេទេស ស្ថាប័ន និង ដំណើរការចូលរួម.

- ពង្រីកការបណ្តុះបណ្តាល និង សំភារៈបណ្តុះបណ្តាលសំរាប់ការកសាងផែនការប្រើប្រាស់ដីដោយមានការចូលរួម រួមបញ្ចូលទាំងការសំរបសំរួលកម្មវិធី និង សំភារៈទាំងឡាយដែលបានអភិវឌ្ឍន៍រួចហើយនៅក្នុងប្រទេសផ្សេងៗទៀត.

៥០/ បន្ថែមលើការសំរបសំរួលក្នុងការកសាងផែនការសំរាប់សហគមន៍ព្រៃឈើជាមួយនឹងដំណើរការចូលរួលធនធាន ហើយនឹងការកសាងផែនការប្រើប្រាស់ដីដោយមានការចូលរួម អង្គការអន្តរជាតិនិង អង្គការក្រៅរដ្ឋាភិបាលចាំបាច់ត្រូវតែបញ្ចូល ការកសាងផែនការផ្ទាល់របស់ពួកគេជាមួយនឹងការកសាងផែនការរបស់ទីភ្នាក់ងាររាជរដ្ឋាភិបាលកម្ពុជា និង អាចជួយគាំទ្រជាមួយ នឹងដំណើរការសំរបសំរួលជាទូទៅ.

| ទិសដៅ | ថ្នាក់ជាតិ | ថ្នាក់ខេត្ត | ថ្នាក់មូលដ្ឋាន |
|---|---|---|---|
| ផ្លាស់ប្តូរពិតមាន និង បណ្តាញ ការងារ ពតិមាន ប្រមូល និង រៀបចំឯកសារបណ្តាញការ ងារសហគមន៍ព្រៃឈើ | បង្កើត និង ថែរក្សាមជ្ឈមណ្ឌលទុកដាក់ឯកសារ សហគមន៍ព្រៃឈើ និង ប្រពន្ធ័ សំរាប់ផលិតពិតមានដែលអាចរកបាន<br><br>រៀបចំបណ្តាញការងារសហគមន៍ព្រៃឈើជាតិជាមួយសម័យ ប្រជុំទៀងទាត់ ផ្តល់ទំនាក់ ទំនងសកម្មជាមួយបណ្តាញ ការងារជាតិផ្សេងទៀត (ព្រៃ សម្បទាន ធ្វើផែនការធនធាន ប្រពន្ធ័កសិកម្ម អភិវឌ្ឍន៍ជនបទ.ល.) និង បណ្តាញការ ងារអន្តរជាតិ | បង្កើត រក្សា និង ទំនាក់ទំនង សកម្មជាមួយមជ្ឈមណ្ឌលឯកសារសហគមន៍ព្រៃឈើជាតិ ធ្វើឱ្យពិតមានអាចរកបាន ប្រើប្រាស់ពិតមាន<br><br>រៀបចំបណ្តាញការងារសហគមន៍ព្រៃឈើខេត្តជាមួយនឹង សម័យប្រជុំទៀងទាត់ រួមបញ្ចូលអាជ្ញាធរខេត្តគណៈកម្មការព្រៃឈើភូមិ អាជ្ញាធរព្រៃ ឈើឃុំ អង្គការក្រៅរដ្ឋា ភិបាល អង្គការអន្តរជាតិ និង បុគ្គលិកអនុវត្តសហគមន៍ព្រៃឈើដលទីកន្លែង បង្កលក្ខណៈងាយស្រួលដល់បណ្តាញការ ងារភូមិ រក្សាទំនាក់ទំនង សកម្មជាមួយនឹងបណ្តាញការងារសហគមន៍ព្រៃឈើជាតិ | កសាងទំនាក់ទំនងសកម្មជាមួយមជ្ឈមណ្ឌលឯកសារសហគមន៍ព្រៃឈើ ប្រើប្រាស់ពិត មាន បង្កើតទំនាក់ទំនងសកម្ម រវាងគណៈកម្មការព្រៃឈើ ភូមិអាជ្ញាធរព្រៃឈើ ឃុំជាមួយនឹងបណ្តាញការងារសហគមន៍ព្រៃឈើថ្នាក់ជាតិ និង ថ្នាក់កខេត្ត<br><br>រៀបចំបណ្តាញ ការងារតាម ភូមិ |
| បណ្តុះបណ្តាល និង បំពាក់ បំប៉នរយៈពេលខ្លី | វាយតំលៃតំរូវការបណ្តុះ បណ្តាល( ថ្នាក់ជាតិ ខេត្ត មូលដ្ឋាន ) ពង្រីកសមត្ថភាព | វាយតំលៃតំរូវការបណ្តុះ បណ្តាល ថ្នាក់ខេត្ត និង ថ្នាក់មូលដ្ឋាន ពង្រីកសមត្ថ ភាពនិងផែនការបណ្តុះ | ចូលរួមក្នុងការវាយតំលៃ ការ អភិវឌ្ឍន៍ និងការអនុវត្តអំពី ការបណ្តុះបណ្តាលដែលសម ស្របសំរាប់មូលដ្ឋាន |

| | | | |
|---|---|---|---|
| និង បណ្តុះបណ្តាលក្នុងការងារ<br><br>• អប់រំអំពីប្រពន្ធ័កសិដ្ឋានព្រៃឈើ និង អភិវឌ្ឍន៍ជនបទ | បណ្តុះបណ្តាល( បណ្តុះបណ្តាល<br>ជំនាញមាតិការបណ្តុះបណ្តាល<br>និងផែនការនិងផ្តល់ការបណ្តុះបណ្តាលសមស្របទាក់ទងទៅនឹងបរិបទផ្សេងៗខុសគ្នា :<br>• តំបន់ព្រៃមិនសម្បទាន<br>• ព្រៃសម្បទាន<br>• តំបន់ការពារ<br>• ព្រៃលិចទឹក និងព្រៃកោង កាង<br>• តំបន់គ្មានព្រៃ<br><br>ពង្រឹងមុខវិជ្ជានៅមហាវិទ្យាល័យ និងបញ្ចូលសហគមន៍ព្រៃឈើក្នុងកម្មវិធីសិក្សា.<br><br>បង្កើតទំនាក់ទំនងរវាងស្ថាប័នអប់រំរួមបញ្ចូលទំនាក់ទំនងជាតិ និងអន្តរជាតិ | បណ្តាលរៀបចំ និង ដឹកនាំការបណ្តុះបណ្តាលសមស្រប<br><br>បង្កើតទំនាក់ទំនងសកម្មរវាងស្ថាប័នអប់រំជាមួយនឹងគ្រោងការ<br>សហគមន៍ព្រៃឈើតាមទី កន្លែង<br>បង្កលក្ខណៈងាយ<br>ស្រួលឱ្យសិស្សនិងនិស្សិតចុះ<br>ធ្វើទស្សនៈកិច្ចសិក្សាដល់ទី កន្លែង | បង្កលក្ខណៈងាយ ស្រួលឱ្យ<br>សិស្សនិងនិស្សតចុះ ធ្វើ<br>ទស្សនៈកិច្ចសិក្សាដល់ទី<br>កន្លែងនិងសិក្សាអំពីទីតាំងសហគមន៍ព្រៃឈើតាមមូលដ្ឋាន និង តាមគ្រោងការ |
| ជំនួយការបច្ចេកទេសកសាង | ជំនួយការបច្ចេកទេស<br>ដើម្បីកសាងផែនការសហគ | ជំនួយការបច្ចេកទេសសំរាប់កសាងផែនការសហគមន៍ព្រៃ ឈើនៅថ្នាក់ខេត្ត និង | ជំនួយការបច្ចេកទេសសំរាប់<br>ការកសាងផែនការសហគមន៍ព្រៃឈើនៅថ្នាក់ |

| | | | |
|---|---|---|---|
| ផែនការសហគមន៏ព្រៃឈើ | មន៏ព្រៃឈើថ្នាក់ជាតិ ខេត្ត និង មូលដ្ឋានបង្កលក្ខណៈងាយស្រួលដល់ជំនាញ បច្ចេកទេស កសាងផែនការ និង ទិន្នន័យ ក្នុងទំរង់សមស្រប សំរាប់ផ្នែក ផ្សេងៗ | ថ្នាក់មូលដ្ឋាន( ជួយសំរួល ជំនាញបច្ចេកទេសកសាង ផែនការនិងទិន្នន័យសមស្របទៅតាមផ្នែកផ្សេងៗសំរាប់ ខេត្ត. | មូលដ្ឋានសមស្របសំរាប់មូលដ្ឋាន |
| ការអនុវត្តសហគមន៏ព្រៃឈើ<br><br>តាមដាន និងវាយតំលៃសហគមន៏ព្រៃឈើ<br><br>វាយតំលៃ និង ពង្រឹងស្ថាប័ន | ជំនួយការបច្ចេកទេសសំរាប់ថ្នាក់ជាតិ ខេត្ត និង មូលដ្ឋាន ក្នុងការអនុវត្តសហគមន៏ព្រៃឈើ( រៀបចំ ការគ្រប់គ្រងរុក្ខវប្បកម្មសំរបសំរួលតាមរបៀបមូលដ្ឋានសំរាប់សហគមន៏ព្រៃឈើដោះស្រាយទំនាស់)<br><br>តាមដាននិងវាយតំលៃការ រៀបចំបច្ចេកទេស សេដ្ឋកិច្ច និង ការប្រតិបត្តិបរិស្ថាននៅថ្នាក់ជាតិ<br><br>វាយតំលៃសមត្ថភាពស្ថាប័ន<br><br>ជាតិសំរាបទ្រទ្រង់បច្ចេកទេស រួមទាំងរចនាមម្ព័ន្ធចាត់តាំង និង សមត្ថភាពបុគ្គលិក | ជំនួយការបច្ចេកទេសអនុវត្តសហគមន៏ព្រៃឈើនៅថ្នាក់ ខេត្ត និងមូលដ្ឋាន( រៀបចំ គ្រប់គ្រងរុក្ខវប្បកម្មសំរាប់សហគមន៏ព្រៃឈើដោយសំរបសំរួលតាមរបៀបមូលដ្ឋាន ដោះស្រាយទំនាស់)<br><br>តាមដាននិងវាយតំលៃការ រៀបចំបច្ចេកទេសសេដ្ឋកិច្ច និងការប្រតិបត្តផ្នែកបរិស្ថាន នៅថ្នាក់ខេត្ត<br><br>វាយតំលៃសមត្ថភាពស្ថាប័ន ខេត្តសំរាប់ទ្រទ្រង់បច្ចេកទេស រួមទាំងរចនាសម្ព័ន្ធចាត់តាំង និង សមត្ថភាពបុគ្គលិក | ទ្រទ្រង់ការអនុវត្តសំរាប់ថ្នាក់មូលដ្ឋាន( រៀបចំ គ្រប់គ្រងរុក្ខវប្បកម្មសំរបសំរួលតាមរបៀមូលដ្ឋាន ដោះស្រាយទំនាស់)<br><br>តាមដាន និងវាយតំលៃការប្រតិបត្តិ សហគមន៏ព្រៃឈើនៅថ្នាក់ មូលដ្ឋាន<br><br>វាយតំសមត្ថភាពស្ថាប័នមូលដ្ឋានសំរាប់ការទ្រទ្រង់បច្ចេក ទេស |
| ព្រាងការងារស្រាវជ្រាវ និង ដំណើរការការងារ | អនុវត្ត និងពង្រីកកម្មវិធីស្រាវជ្រាវរបស់ជាតិដោយលើក | សហប្រតិបត្តការក្នុការពង្រីក និង អនុវត្តការស្រាវជ្រាវអំពីបញ្ហាសហគមន៏ព្រៃឈើទាក់ទងទៅនឹង | សហប្រតិបត្តការក្នុងការពង្រីក និង អនុវត្តការស្រាវជ្រាវ អំពីបញ្ហាសហគមន៏ព្រៃឈើ |

| | | | |
|---|---|---|---|
| សារជ្រាវ សំរាប់កិច្ចការផ្សេង ៗ និង ធានាថាលទ្ធផលនៃ ការស្រាវ ជ្រាវត្រូវបានទទួល ស្គាល់ក្នុង គោលនយោបាយនិ ងការរៀបចំកម្ម វិធី | ឡើងបញ្ហាគន្លឹះសហគមន៍ព្រៃ ឈើដូចជា :<br>• ធនធានព្រៃឈើ ការប្រើ ប្រាស់ព្រៃឈើនៅ មូលដ្ឋាន ស្ថានភាពសេដ្ឋកិច្ច សង្គម និង ការទាក់ទងជាមួ យធនធាន<br>• បញ្ហាកាន់កាប់ព្រៃឈ្មោ និង ជំរើសក្នុងការដោះស្រាយ<br>• សេដ្ឋកិច្ចនៃសហគមន៍ព្រៃ ឈើរួមបញ្ចូលទាំងការវាយ តំលៃពេញលេញ និងការ វិភាគលើថ្លៃដើម និង ប្រាក់ចំណេញក្នុង ការគ្រប់គ្រង<br>• ជំរើសក្នុងការអភិ វឌ្ឍន៍ វិស័យឯកជន ក្នុងសមាគមរួម បញ្ចូលទាំងឈើ ហ៊ុប និង អនុ | ថ្នាក់ខេត្ត និង មូលដ្ឋាន | ដែលទាក់ទងទៅនឹងថ្នាក់ មូលដ្ឋាន |

| | | | |
|---|---|---|---|
| | ផលព្រៃឈើ<br>• សហគមន៍ព្រៃឈើទាក់ទងទៅនឹងការគ្រប់គ្រងជីវសាស្ត្រចំរុះ | | |

## ការធ្វើផែនទី

៥១/ ការរៀបចំផែនទីដោយឡែកនៅថ្នាក់មូលដ្ឋានរួមបញ្ចូលការចុះពិនិត្យដល់ទីកន្លែងជាមួយអ្នកប្រើប្រាស់ព្រៃឈើ និង កាផេលិតផែនទីព្រាងតំណាងព្រៃឈើ និង ផែនទីកន្លែងណាមួយផ្សេងទៀតក្នុងទ្រង់ទ្រាយដែលនឹងអាចយល់បានដោយពួក អ្នក ភូមិ. សារៈសំខាន់ក្នុងការធ្វើផែនទីរបៀបនេះ គឺ ដំណើរការ( បច្ចេកវិជ្ជាទាប) ដែលគួរយកមកគិតថ្លឹងថ្លែងមើលចំពោះការ ប្រើប្រាស់បច្ចេកវិជ្ជាកន្លងមកដើម្បីបង្កើនភាពត្រឹមត្រូវរបស់ផែនទី ផ្លាស់ប្តូរទិន្នន័យធ្វើផែនទី និង ការបញ្ចូលផែនទីដែលបាន រៀបចំរួចនៅក្នុងខ្នាតផ្សេងៗខុសៗគ្នាដើម្បីបង្កើតជាផែនទីមួយសមរម្យ និង ប្រើប្រាស់បាននៅគ្រប់ថ្នាក់ដែលចូលរួមក្នុងការធ្វើ ផែនការសំរាប់សហគមន៍ព្រៃឈើ. ការប្រើប្រាស់បច្ចេកវិជ្ជាខ្ពស់ដូច ខាងក្រោមនេះត្រូវបានដាក់បញ្ចូលសំរាប់ប្រើប្រាស់ក្នុងការ ធ្វើផែនការដោយមានការចូលរួម. បច្ចេកវិជ្ជាទាំងនោះមានៈ

- ប្រើប្រាស់ឧបករណ៏ GPS នៅថ្នាក់មូលដ្ឋានក្នុងការកសាងព្រៃឈើភូមិដើម្បីកំណត់ព្រំប្រទល់ និង ទីតាំរបស់ផែនទីកន្លែងណាផ្សេងទៀត.
- ប្រើប្រាស់ប្រពន្ធ័ពិតមានភូមិសាស្រ្ត (GIS) នៅថ្នាក់ជាតិ និង កន្លែងដែលមានលទ្ធភាពប្រើ GIS នេះ នៅថ្នាក់ខេត្ត ដើម្បីកត់ត្រាទិន្នន័យដែលបានប្រមូលលើ GPS ជាមួយនឹងការពណ៌នាទិន្នន័យផ្សេងទៀត រក្សាទុកទិន្នន័យប្រាកដ និង រៀបចំផែនទីតាមខ្នាតផ្សេងៗដែលត្រូវការដោយភ្នាក់ងារទាំងឡាយដែលចូលរួមក្នុងសហគមន៏ព្រៃឈើនៅគ្រប់កំរិត.

៥២/ បច្ចេកទេសទ្រទ្រង់ក្នុងការកសាងផែនទីដែលកន្លងមកមានស្រាប់នៅមជ្ឈមណ្ឌលជាតិរួមមាន មជ្ឈមណ្ឌលបញ្ចូលធនធានពិតមាន(IRIC) នាយកដ្ឋានរុក្ខា-ប្រមាញ់ ក្រសួងបរិស្ថាន និង នាយកដ្ឋានសុរិយោដីគួរបង្កលក្ខណៈងាយស្រួលក្នុងការពង្រីកGIS/RS/GPSជាមូលដ្ឋានវិធីសាស្រ្តកសាងផែនទី និង ត្រូវជួយពង្រឹងសមត្ថភាពខេត្តក្នុងការធ្វើផែនទីដើម្បីធានាការធ្វើផែនការដោយមានការចូលរួម.

## ការគ្រប់គ្រងពតិមាន

៥៣/ ការទ្រទ្រង់បច្ចេទេសចំពោះសហគមន៍ព្រៃឈើរួមមាន ការគ្រប់គ្រងព័តមាន ការណែនាំបច្ចេកទេសតាមតំបន់ផ្សេងៗ ការបណ្តុះបណ្តាល និង ការស្រាវជ្រាវ.

៥៤/ ការផ្លាស់ប្តូរពតិមាន និង បទពិសោធន៍ដែលទទួលបានដោយក្រុមអ្នកភូមិ បុគ្គលិក និង បណ្តាទីភ្នាក់ងារទ្រទ្រង់មាន សារៈសំខាន់សំរាប់ការពង្រីក ការយកមកប្រើប្រាស់ដើម្បីសំរបសំរួលសហគមន៍ព្រៃឈើក្នុងជួរសង្គម មជ្ឈដ្ឋាន និង ស្ថាប័នក្នុង កម្ពុជា. ការងារនេះទាមទារការបង្កើតឱ្យមានពតិមានគ្រប់គ្រាន់សំរាប់អ្នកទាំងឡាយដែលត្រូវការ នៅពេលណាដែលគេត្រូវការ និង ក្នុងរូបភាពដែលគេអាចប្រើប្រាស់. សមត្ថភាពក្នុងការផ្តល់ និង ចែកចាយពតិមានត្រូវតែពង្រីកបន្ថែមនៅថ្នាក់ជាតិ ខេត្ត និង មូលដ្ឋាន ក្នុងចំណោមស្ថាប័នរដ្ឋ អង្គការអន្តរជាតិ និង អង្គការក្រៅរដ្ឋាភិបាល.

៥៥/ ការទ្រទ្រង់បច្ចេកទេសសំរាប់សហគមន៍ព្រៃឈើក៏រួមបញ្ចូលផងដែរនូវដំបូន្មានបច្ចេកទេសអំពីបុគ្គលិករដ្ឋាភិបាលដែល បានបណ្តុះបណ្តាល និង បទពិសោធន៍លើការងារសហគមន៍ព្រៃឈើនោះ មានសារៈសំខាន់បំផុត. តំបន់ដែលមានជំនួយការបច្ចេក ទេសអាចប្រើប្រាស់ក្នុងការអនុវត្តការងាររុក្ខវប្បកម្ម ការងារគ្រប់គ្រងថ្នាលបណ្តុះ ការដោះស្រាយទំនាស់ និង បញ្ហាស្ថាប័ន.

# ៥- គោលលំនាំសំរាប់ការអនុវត្តន៏សហគមន៏ព្រៃឈើដល់ទីកន្លែងនៅកម្ពុជា

## ៥-១ សេចក្តីផ្តើម គោលបំណងនៃគោលលំនាំអនុវត្តដល់ទីកន្លែង

៥៦/ គោលលំនាំអនុវត្តសហគមន៏ព្រៃឈើដល់ទីកន្លែងនេះពិពណ៌នាអំពីវិធីសាស្រ្ត និង ដំណើរការដែលបានស្នើរ ឡើងសំរាប់ពង្រីកការអនុវត្តសហគមន៏ព្រៃឈើនៅកម្ពុជា និង មានបំណងសំរាប់ប្រើប្រាស់ក្នុងការអនុវត្តសហគមន៏ព្រៃឈើដល់ ទីកន្លែង. គោលលំនាំសំរាប់ការអនុវត្តសហគមន៏ព្រៃឈើដល់ទីកន្លែងនេះរួមបញ្ចូលទស្សនៈ និង វិធីសាស្រ្តដែលបានសាក ល្បង និង បានប្រើប្រាស់ដោយគំរោងសហគមន៏ព្រៃឈើមួយចំនួនដែលបានអនុវត្តនៅកម្ពុជា និង ក្នុងប្រទេសដ៏ទៃបង្ហាញឱ្យឃើញ នូវការអនុវត្តបាន និង ភាពខុសគ្នា ពីការអនុវត្តគំរោងដ៏ទៃទៀត( មិនមែនគំរោងសហគមន៏ព្រៃឈើ). គោលលំនាំអនុវត្ត សហគមន៏ព្រៃឈើដល់ទីកន្លែងនេះមានគោលបំណងដាក់ឱ្យប្រើសំរាប់ប្រជាជនសហគមន៏មូលដ្ឋាន ក្នុងជួរទីភ្នាក់ងាររដ្ឋាភិបាល ម្ចាស់ជំនួយ និង អង្គការក្រៅរដ្ឋាភិបាល ដែលជាប់ទាក់ទងជាមួយការទ្រទ្រង់ និង ការពង្រីកសហគមន៏នៅកម្ពុជា.

៥៧/ ផ្នែកទីមួយបកស្រាយអំពីរបៀបធ្វើផែនការ និង ការរៀបចំសហគមន៏ព្រៃឈើនៅថ្នាក់ខេត្ត និង ថ្នាក់មូលដ្ឋាននៅ ក្នុងគំរោងរបស់ខេត្តសំរាប់អភិវឌ្ឍន៏នៅក្នុងប្រទេសកម្ពុជា[៣]. វាបានព្រាងដំណើរការចូលរួម និង សកម្មភាពសំរាប់ពង្រីក ផែនការប្រតិបត្តិ និង ការរៀបចំរចនាសម្ពន្ធ័សមស្របសំរាប់សហគមន៏ព្រៃឈើ តំរូវការសំរាប់ភាពស្ថិតស្ថេរនៃការចូលរួម របស់ប្រជាជនមូលដ្ឋានក្នុងការគ្រប់គ្រងព្រៃឈើ. ផ្នែកជាបន្តបន្ទាប់នេះនឹងពិភាក្សាដោះស្រាយអំពីការប្រកួតប្រជែងការតវ៉ា ទាមទារដើម្បីស្នើរដាក់បញ្ចូលសហគមន៏ព្រៃឈើក្នុងជំហានកសាងផែនការ.

៥៨/ មុននឹងពិពណ៌នាអំពីដំណើរការដែលបានស្នើឡើងក្នុងការធ្វើផែនការសំរាប់សហគមន៍ព្រៃឈើវាជាការចាំបាច់ត្រូវកំណត់ឱ្យបានច្បាស់ថាតើការកសាងផែនការនេះជាអ្វី? អ្នកណាជាអ្នកធ្វើផែនការនេះ? ហើយតើសហគមន៍ជាអ្វី និង សហគមន៍ ព្រៃឈើជាអ្វី?

**តើការកសាងផែនការសំរាប់អ្វី?**

៥៩/ ការកសាងផែនការគឺសំរាប់ឱ្យប្រជាជនបង្កើតកិច្ចព្រមព្រៀងលើទិសដៅ និង សកម្មភាពចំពោះព្រៃឈើ និង ធនធានផ្សេងៗទៀតរបស់ពួកគេ.

៦០/ ការកសាងផែនការសំរាប់សហគមន៍ព្រៃឈើចាំបាច់ត្រូវធ្វើនៅមូលដ្ឋានដើម្បីធានាការចូលរួមពិតប្រាកដនៅមូល ដ្ឋាន និង ត្រូវធ្វើនៅខេត្តដើម្បីបង្កើតភាពស្របច្បាប់សំរាប់សិទ្ធិរបស់មូលដ្ឋាន និងធានាខុសត្រូវ និង ដើម្បីរួមបញ្ចូលផែនការសំរាប់គ្រប់គ្រងធនធានព្រៃឈើនៅថ្នាក់ជាតិ ខេត្ត មូលដ្ឋានជាមួយគ្នា.

**ការកសាងផែនការសហគមន៍ព្រៃឈើថ្នាក់ខេត្ត**

៦១/ ការរៀបចំផែនការសហគមន៍ព្រៃឈើគឺមានគោលបំណងក្នុងការប្រមូល វិភាគ និង ផ្តល់ពិតមានចាំបាច់សំរាប់ ភិបាល និង អង្គការក្រៅរដ្ឋាភិបាលក្នុងការទ្រទ្រង់ និង ផ្សាយសហគមន៍ព្រៃឈើ និង ដើម្បីជួយទ្រទ្រង់ថ្នាក់មូលដ្ឋាន ក្នុងការធ្វើផែនការសំរាប់សហគមន៍ព្រៃឈើ. សារៈសំខាន់ដោយឡែករបស់ការកសាងផែនការសហគមន៍ប្រៃឈើថ្នាក់ខេត្តគឺដើម្បី :

- ស្វែងយល់ទីកន្លែងដែលមានសហគមន៍ពឹងផ្អែកលើព្រៃឈើ និង ស្វែងយល់អំពីរបៀបដែលសហគមន៍មូលដ្ឋានប្រើ ប្រាស់ និង គ្រប់គ្រងព្រៃឈើ.
- ស្វែងយល់កន្លែងដែលមានព្រៃឈើ ស្ថានភាពព្រៃឈើ និង ដើម្បីបង្ហាញថា មួយណាជាតំបន់ព្រៃការពារ( ក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន) ព្រៃលិចទឹក( ក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានជលផល) កន្លែងកម្មសិទ្ធិឯកជន ក្រោមការគ្រប់គ្រងរបស់ព្រៃសម្បទានឬប្រភេទព្រៃផ្សេងទៀត និង ការទុកដាក់ព្រៃឈើដោយឡែកសំរាប់ធ្វើអ្វីម្យ៉ាង .

៦២/ ពតិមានត្រូវរធ្វីការចងក្រង វិភាគ និង រក្សាទុក. នៅកន្លែងដែលមានភាពងាយស្រួលឬកន្លែងណាមួយដែលអាចធ្វើបាននោះការប្រើប្រាស់កុំព្យុទ័រ ក្នុងការពង្រីក និង រក្សាទុកពតិមានគឺមានតំលៃបំផុតបើមិនដូច្នោះមិនចាំបាច់ទេ.

៦៣/ ពតិមានត្រូវបង្កើតឱ្យមាន និង ត្រូវបានប្រើប្រាស់សំរាប់ការអភិវឌ្ឍន៍សហគមន៍ព្រៃឈើ.

**ការធ្វើផែនការសំរាប់ថ្នាក់មូលដ្ឋាន**

៦៤/ ការធ្វើផែនការសំរាប់ថ្នាក់មូលដ្ឋានគឺ បង្កើតមូលដ្ឋានសំរាប់ការអនុវត្តសហគមន៍ព្រៃឈើនៅកន្លែងដែលប្រជាជន មូលដ្ឋាន អង្គការរដ្ឋ និង អង្គការក្រៅរដ្ឋាភិបាល និងបណ្តាផ្នែកឯកជនចូលរួមកែលំអការគ្រប់គ្រងព្រៃឈើទាំងអស់គ្នាដោះស្រាយ

(៣) រាជរដ្ឋាភិបាលកម្ពុជាកំពុងបង្ហាញគំរោងចំរុះមួយនៅតាមខេត្តដោយឈរលើកម្មវិធីសិលា (SEILA) ដែលទ្រទ្រង់និងបង្កើនដោយអង្គការ CARERE

បញ្ហា និង ពង្រីកធនធានព្រៃឈើសំរាប់តំរូវការទៅអនាគត.

---

៦៥/ ការលេចធ្លោរឡើងជាចំបងរបស់ការកសាងផែនការសំរាប់ថ្នាក់មូលដ្ឋាន គឺស្ថិតនៅលើការចូលរួមរបស់សហគមន៍លើការវាយតំលៃតំរូវការ និង ការប្រើប្រាស់ព្រៃឈើរបស់ពួកគេ និង ការពង្រីកផែនការមូលដ្ឋានរបស់ សហគមន៍ដើម្បីដោះស្រាយទិសដៅ និង តំរូវការរបស់ពួកគេចំពោះព្រៃឈើ . គោលបំណងនៃការកសាងផែនការសហគមន៍ ព្រៃឈើនៅថ្នាក់មូលដ្ឋានគឺដើម្បីៈ

- បង្ហាញទស្សនៈ និង គោលបំណងសហគមន៍ព្រៃឈើ និង កសាងទំនុកចិត្តគ្នាទៅវិញទៅមករវាងពួកអ្នកភូមិនឹងបុគ្គលិកដែលចុះធ្វើការដល់មូលដ្ឋាន.
- ចាប់ផ្តើមកិច្ចពិភាក្សានៅក្នុងសហគមន៍អំពីផលប្រយោជន៍របស់មូលដ្ឋានក្នុងព្រៃឈើ ពិភាក្សាក្នុងសហគមន៍អំពីធន ធានព្រៃឈើ និងការគ្រប់គ្រងព្រៃឈើដែលបានប្រើប្រាស់ជាមូលដ្ឋានដោយសហគមន៍.
- ប្រមូលពិតមានអំពីព្រៃឈើ និង ធនធានព្រៃឈើ តើប្រជាជនណាប្រើប្រាស់ព្រៃឈើ ហើយគេគ្រប់គ្រងព្រៃឈើដោយ របៀបណា.
- ស្វែងយល់ពីរបៀបដែលអ្នកភូមិចាត់ចែងដោយពួកគេផ្ទាល់ក្នុងការគ្រប់គ្រងព្រៃឈើ និងដើម្បីលើកសំណើរអំពីរបៀបបង្កើតគណៈកម្មាធិការឬរចនាសម្ព័ន្ធឯទៀតដែលអាចមានសារៈសំខាន់សំរាប់ដំណើរការគ្រប់គ្រង.
- បង្កើត និង កំណត់ព្រំប្រទល់តំបន់ព្រៃសំរាប់ការគ្រប់គ្រងដោយមូលដ្ឋាន និង អភិវឌ្ឍន៍ផែនការគ្រប់គ្រងព្រៃឈើ.

៦៦/ ការកសាងផែនការសហគមន៍ព្រៃឈើសំរាប់មូលដ្ឋានចាំបាច់ត្រូវមាន ការចូលរួមយ៉ាងពេញលេញ និង ជំរុញឱ្យមានសហប្រតិបត្តិការយ៉ាងជិតស្និតរវាងសហគមន៍ និង បុគ្គលិកដែលចុះធ្វើការដល់ទីកន្លែង .ដើម្បីលើកទឹចិត្តដល់ការងារនេះ និងដើម្បីភាពងាយស្រួលក្នុងការអនុវត្តការប្រើប្រាស់ភាសាជាតិ( ភាសាមូលដ្ឋាន) និង ការប្រើប្រាស់ប្រជុំសព្ទបច្ចេកទេសមូលដ្ឋានប្រពន្ធ័ចាត់ថ្នាក់តាមបែបមូលដ្ឋាន និង ចំណេះដឹងផ្សេងទៀតរបស់មូលដ្ឋានប្រាកដជាផ្តល់មកនូវអត្ថប្រយោជន៍ដ៏ខ្ពង់ខ្ពស់.

**<u>ការទ្រទ្រង់សំរាប់ការធ្វើផែនការ និង ការអនុវត្តសហគមន៍ព្រៃឈើ</u>**

៦៧/ គួរកំណត់ក្នុងចិត្តថាដំណើរសហគមន៍ព្រៃឈើទាមទារការទ្រទ្រង់ដលសហគមន៍ទាំងឡាយគ្រប់ប្រភេទប្រសិនបើសហគមន៍ទាំងនោះបានរៀបចំកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើជាមួយរដ្ឋាភិបាល និង បានអនុវត្តផែនការរបស់ពួកគេដោយ ប្រសិទ្ធិភាព. ប្រភពនៃការទ្រទ្រង់ទាំងអស់នេះអាចចេញមកពីទីភ្នាក់ងារអភិវឌ្ឍន៍មួយឬអង្គការរបស់រដ្ឋាភិបាលដែលបានចូល រួមក្នុងកិច្ចអភិវឌ្ឍន៍ជនបទ តំរូវការដែលកំណត់នូវពេលកសាងផែនការសំរាប់សហគមន៍ព្រៃឈើ . ប្រភេទនៃតំរូវការទ្រទ្រង់ សំរាប់ការធ្វើផែនការរួមមានៈ

- បច្ចេកទេសជំនាញក្នុងការធ្វើផែនការ( ដើម្បីគ្រប់គ្រងប្រភពពិតមាន និង ពិតមានអំពីសហគមន៍ រក្សាទុកពិតមាន ធ្វើឱ្យពិតមានអាចប្រើប្រាស់បានជាប្រចាំ និង បកស្រាយពិតមានលើផែនទីឬសំណុំបែបបទឯទៀតដែលងាយយល់).
- បច្ចេកទេសជំនាញព្រៃឈើ( រួមបញ្ចូលការងារយល់ដឹងលើបច្ចេវិជ្ជាទាំងឡាយដែលមានស្រាប់ និង ការអនុវត្តបាននូវបច្ចេកវិជ្ជាទាំងនោះជាពិសេសសំរាប់ការងាររុក្ខវប្បកម្ម និង ផលិតកម្មបណ្តុះកូនឈើ.
- ជំនាញក្នុងការជួយសំរួល( របៀបធ្វើការជាមួយប្រជាជនមូលដ្ឋាន របៀបរកដំណោះស្រាយជាមួយប្រជាជនមូលដ្ឋាន ក្តាប់បានស្ថានភាពប្រចាំថ្ងៃរបស់ប្រជាជនមូលដ្ឋាន).
- ជំនាញទំនាក់ទំនង( រួមមានមូលដ្ឋាន កន្លែងដែលសមស្រប).

| |
|---|
| យល់ដឹងអំពីការប្រើប្រាស់ព្រៃឈើនៅមូលដ្ឋាន<br><br>ដើម្បីជួយសម្រួលដល់ការពង្រីកសហគមន៍ព្រៃឈើនៅកន្លែងណាមួយជាមុន បុគ្គលិកនៃគំរោង( ការចូលរួមគ្រប់គ្រងធនធានធម្មជាតិនៅតំបន់បឹងទន្លេសាប) បានដំណើរការប្រជុំក្រៅផ្លូវការយ៉ាងល្អិតល្អន់ជាមួយប្រជាជនដែលប្រើប្រាស់ធនធានព្រៃឈើ និង ធនធានឯកទៀតដែលមានស្រាប់. ពតិមានធានាត្រូវបានប្រមូលមកពីគ្រប់ទី កន្លែង និង គ្រប់សមាសភាពក្នុងសហគមន៍ ក្មេង ចាស់ ប្រុស ស្រី មាន និង ក្រ ដើម្បីស្វែងយល់អំពីរបៀបប្រើប្រាស់ធនធានដោយមូលដ្ឋាន អំពីតំរូវការ និង ការផ្គត់ផ្គង់ឈើ និង អនុផលព្រៃឈើ អំពីជំរើស និង កាលៈទេសៈសំរាប់កែលំអការគ្រប់គ្រងធនធាន. អ្នកជួយសំរួលត្រូវបានបង្រៀនឬបណ្តុះបណ្តាលឱ្យចេះសួរសំណួរសមស្របក្នុងរបៀបឥតព្រាងទុក និង បង្រៀនឱ្យចេះសង្កេត និង ស្រាវជ្រាវក្នុងដំណើរការរបស់គេដើម្បីតាញយកការយល់ដឹងច្បាស់លាស់មួយអពីការប្រើប្រាស់ធនធានដែលមាននៅក្នុងតំបន់. ករណើសិក្សាត្រូវបានព្រាងឡើងសំរាប់កន្លែងនីមួយៗហើយក្រុមអ្នកប្រើប្រាស់ធនធានទាំងអស់សុទ្ធតែ ត្រូវបានកំណត់ផ្តល់អាទិភាពក្នុងការចូលរួមសិក្ខាសាលា និង ពិភាក្សានៅមូលដ្ឋាន. ដំណើរជាយថាហេតុនាំឱ្យមានការរៀបចំ និង ការពង្រីកសហគមន៍ព្រៃឈើដូចដែលបានកំណត់ក្នុងគោលការណ៍ណែនាំនេះ. |

**សហគមន៍ជាអ្វី?**

៦៨/ សហគមន៍គឺជាពាក្យមួយដែលបត់បែនបានហើយអាចប្រើបានចំពោះក្រុមមួយតូចឬធំ. ជាគោលបំណងនៃសហគមន៍ ព្រៃឈើ សហគមន៍គឺជាក្រុមមនុស្សមួយក្រុមដែលបានកំណត់ក្នុងរង្វង់ពួកគេផ្ទាល់ក្នុងការបែងចែក ផលប្រយោជន៍ និង កំណត់ អនាគតរួមគ្នា. ជាទូទៅភូមិត្រូវបានចាត់ទុកជាគំនិតមូលដ្ឋានដែលប្រជាជនបានសំរេចថាតើត្រូវរៀបចំដំណើរការជាមួយគ្នាដើម្បីកែលំអការគ្រប់គ្រងព្រៃឈើឱ្យកាន់តែប្រសើរឡើងរបៀបណា. ជារឿយៗគណៈកម្មាធិការព្រៃឈើភូមិ( គពភ) ដើរតួជាយន្តការមួយសំរាប់ប្រមូលផ្តុំ និង ទំនាក់ទំនងអំពីផលប្រយោជន៍ និង តំរូវការរបស់អ្នកភូមិដែលទាក់ទងជាមួយព្រៃ និង ធនធានព្រៃឈើហើយកិច្ចការនេះអាចមានប្រសិទ្ធិភាពច្រើនបើគិតថាបើកទូលាយដល់មនុស្សគ្រប់រូបក្នុងភូមិ គ្រួសារ ព្រះសង្ឃ គ្រូបង្រៀន និង ក្រុមជនជាតិភាគតិច .

៦៩/ ជារឿយៗមានករណីដែលភូមិពីរឬច្រើនភូមិដែលប្រើប្រាស់តំបន់ព្រៃឈើជាមួយគ្នា. ក្នុងករណីដូច្នេះការប្រើប្រាស់ជាន់គ្នាឬការទាមទារជាន់គ្នាអាចបង្កជាជំលោះរវាងភូមិ. វាអាចមានភូមិច្រើនឬភូមិរាប់ឡូត៍ ដែលជួនកាលភូមិទាំងនោះអាចស្ថិតនៅក្នុងឃុំឬស្រុកតែមួយប៉ុន្តែជួនកាលក៏អាចស្ថិតនៅក្នុងឃុំឬស្រុកពីរឬបីផ្សេងៗគ្នា. ដើម្បីដោះស្រាយតំរូវការសំរាប់ទំនាក់ទំនងអំពីព្រៃឈើក្នុងចំណោមភូមិជាច្រើន សមាគមព្រៃឈើ សហគមន៍អន្តរភូមិមួយ គួរបង្កើតឡើងហើយដើរតួជាយន្តការប្រសិទ្ធិភាពមួយសំរាប់ការប្រមូលផ្តុំ និង ទំនាក់ទំនងរវាងភូមិដែលមានករបែងចែកផលប្រយោជន៍រួមគ្នាហើយមានតំរូវការ និង ធនធានព្រៃឈើរួមគ្នា[៤]. សមាគមព្រៃឈើអាចមានសមាសភាពជាតំណាងមកពីគណៈកម្មាធិការព្រៃឈើភូមិរបស់ភូមិនីមួយៗ ក៏ដូចជាតំណាងមកពីអាជ្ញាធររដ្ឋបាល ឃុំ ស្រុក បើសិនជាសមស្រប. សមាគមព្រៃឈើសហគមន៍ត្រូវបំពេញកិច្ចការដោយរលូន

---

(៤)សមាគមព្រៃឈើសហគមន៍អន្តរភូមិនេះដូចគ្នាទៅនឹងប្រភេទអង្គការមួយដែលបានកសាងឡើងនៅក្នុងគំរោងទ្រទ្រាយសហគមន៍ព្រៃឈើរបស់អង្គការ MCC នៅ ខេត្តតាកែវក៏ដូចគ្នាទៅនឹងគំរោងទ្រទ្រង់សហគមន៍ព្រៃឈើរបស់អង្គការ CONCERN នៅខេត្តកំពង់ឆ្នាំង និង ខេត្តពោធិសាត់អង្គការ FAOនៅខេត្តសៀមរាប និង គំរោងអនុផលព្រៃឈើ(NTFP)នៅខេត្តរតនគីរី.

តាមច្បាប់ដែលឡើងដោយសមាគមព្រៃឈើសហគមន៍ខ្លួនឯងផ្ទាល់ហើយដែលច្បាប់នេះត្រូវពង្រឹក និង យកជាការដើម្បីធានា

តុល្យភាពរបស់តំណាង និង ការចូលរួមត្រូវបានថែរក្សា.

**ព្រៃឈើសហគមន៍ជាអ្វី?**

៧០/ សំរាប់គោលបំណងរបស់គោលការណ៍ណែនាំនេះ ព្រៃឈើសហគមន៍គឺជា ការកំណត់តំបន់ព្រៃឈើមួយដែលបានគ្រប់គ្រងដោយសហគមន៍មូលដ្ឋានតាមរយៈអង្គការចាត់តាំងសហគមន៍មូលដ្ឋានដោយអនុលោមតាមផែនការគ្រប់គ្រងព្រៃឈើ និង ជាមួយនឹងសិទ្ធិជាអ្នកប្រើប្រាស់ដែលផ្តល់ឱ្យសហគមន៍ដោយរដ្ឋាភិបាល ដែលសិទ្ធិនេះមានចែងលំអិតនៅក្នុងកិច្ចព្រមព្រៀង ដោយឡែក.

៧១/ ព្រៃឈើសហគមន៍បង្កើតឡើងនៅក្នុងកន្លែងណាមួយដែលៈ

- សហគមន៍បានបង្ហាញ និង អាចពិនិត្យឱ្យដឹងខុសត្រូវលើការប្រើប្រាស់ឬផលប្រយោជន៍ក្នុងតំបន់ហើយព្រមព្រៀង និង ស្ម័ប្ប័ចំពោះការគ្រប់គ្រងតំបន់ជាព្រៃឈើសហគមន៍ដូចដែលបានបកស្រាយខាងលើ.
- មិនមានការប្រកួតប្រជែងទាមទារចំពោះតំបន់ឬធនធានដែលបានស្នើរសំរាប់សហគមន៍ព្រៃឈើឬអាចដោះស្រាយបាន រាល់បញ្ហាទាមទារពីបណ្តាអ្នកទាមទារដោយឆ្លងកាត់កិច្ចព្រមព្រៀង.

៧២/ ការទទួលស្គាល់ព្រៃឈើសហគមន៍មួយ ការបញ្ចូលក្នុងឯកសារស្តីពីកិច្ចព្រព្រៀងសហគមន៍ព្រៃឈើ និង ការទទួលស្គាល់តាមផ្លូវច្បាប់ដោយអជ្ញាធរទទួលខុសត្រូវគឺសកម្មភាពរបស់រដរដ្ឋាភិបាល. ការទទួលស្គាល់អង្គភាពសហគមន៍ព្រៃឈើណា មួយ

គឺជាការផ្តល់សិទ្ធិដល់សហគមន៍ឱ្យទទួលខុសត្រូវចំពោះការកំណត់ដោយច្បាស់លាស់នៅផលប្រយោជន៍ពីព្រៃឈើរបស់ សហគមន៍ និង ធ្វើឱ្យសហគមន៍ទទួលខុសត្រូវលើកាតព្វកិច្ចគ្រប់គ្រង.

៧៣/ ក៏រិតរយៈនៃកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើមួយអាចមានសុពលភាព៣០ឆ្នាំហើយអាចបន្តបានដោយស្វ័យប្រវត្តិ. ការបញ្ចប់កិច្ចព្រមព្រៀងព្រៃឈើអាចធ្វើទៅបានលុះត្រាតែអនុលោមតាម កិច្ចព្រមព្រៀងសហគមន៍ព្រៃឈើ. ព្រៃឈើរបស់ សហគមន៍ឬកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើមិនអាចលក់ ផ្ទេរឬប្រើប្រាស់ជាបំណុលបានទេ.

## ៥-២ ជំហានក្នុងការរៀបចំផែនការសហកមន៍ព្រៃឈើថ្នាក់ខេត្ត

៧៤/ ការកសាងផែនការសហគមន៍ព្រៃឈើនៅថ្នាក់ខេត្តគឺធ្វើឡើងលើមូលដ្ឋាននៃពិតមានអំពីស្ថានភាពធនធានព្រៃឈើ ការប្រើប្រាស់ធនធានព្រៃឈើ និង ការកាន់កាប់( ស្របច្បាប់ និង ជាប្រពៃណី ) អំពីផលប្រយោជន៍ និង សក្តានុពល របស់សហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងតំបន់ព្រៃឈើ និង សមត្ថភាពរបស់ទីភ្នាក់ងារផ្សេងៗសំរាប់តំឡើងកំរិត និង ទ្រទ្រង់ សហគមន៍ព្រៃឈើ. ពិតមាននេះត្រូវបានប្រើប្រាស់សំរាប់ធ្វើផែនការសកម្មភាពសហគមន៍ព្រៃឈើនៅថ្នាក់ខេត្តដោយអនុលោម តាមអាទិភាពអភិវឌ្ឍន៍របស់ខេត្តជាមួយធនធានដែលមានស្រាប់.

៧៥/ នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្នអង្គភាពសមស្របសំរាប់ទទួលរ៉ាប់រងសកម្មភាពសហគមន៍ព្រៃឈើនៅថ្នាក់ខេត្តមាន ការប្រែប្រួលពីខេត្តមួយទៅខេត្តមួយ. មានមន្ទីរ និងការិយាល័យពាក់ពន្ធ័ជាច្រើននៅក្នុងខេត្ត រួមទាំងការិយាល័យរុក្ខា-ប្រមាញ់ ខេត្តផងដែរកន្លងមកមានការខ្វះខាតទាំងពីរផ្នែកគឺ ធនធាន និង មុខជំនាញសំរាប់អនុវត្តការងារសហគមន៍ព្រៃឈើ. វាអាចជា ការសមស្របមួយដែរ ក្នុងការចាត់វិធានការបណ្តោះអាសន្នដើម្បីបង្កើតក្រុមអន្តរភ្នាក់ងារមួយដូចជា លេខាធិការដ្ឋានសហគមន៍ ព្រៃឈើមួយសំរាប់ទ្រទ្រង់ និង ជួយសំរួលសកម្មភាពសហគមន៍ព្រៃឈើនៅថ្នាក់ខេត្ត.

៧៦/ ដំណើរការដើម្បីកសាងផែនការសកម្មភាពសហគមន៍ព្រៃឈើនៅខេត្តគួរធ្វើជាជំហានបន្តិចម្តងៗកសាងលើសមត្ថភាព ផែនការពាក់ពន្ធ័( និងការទ្រទ្រង់ហិរញ្ញវត្ថុ) នៅពេលដែលកិច្ចការទាំងអស់បានរៀបចំរួចហើយ.

### ការរៀបចំ និងចាត់ចែង

- ធានាថាក្រុមដែលចូលរួមធ្វើកិច្ចការកសាងផែនការមានការយលគ្រប់គ្រាន់អំពីគោលការ និង វិសាលភាពនៃសហគមន៍ ព្រៃឈើយល់គ្រប់គ្រាន់អំពីបច្ចេកទេសធ្វើផែនការដោយមានការចូលរួម និង បច្ចេកទេសមូលដ្ឋាក្នុងការធ្វើផែនទី. បើសិនជាមានកុំព្យូទ័រសំរាប់ប្រើប្រាស់ត្រូវធានាថាពួកគេមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់សំរាប់ប្រតិបត្តិការ និង ក្នុងការថែរក្សា.
- ចាត់ចែងផែនការការងារ( ចាត់ការទទួលខុសត្រូវសំរាប់កិច្ចការដែលត្រូវអនុវត្ត កំណត់តារាងពេលវេលាការងារ ត្រៀម បំរុងភស្តុភា និង ហិរញ្ញវត្ថុសំរាប់ទ្រទ្រង់).
- ចាត់រកថវិការសំភារៈផែនទី ទិន្នន័យ ឯកសារ.

- ត្រៀមបំរុងការងារធ្វើផែនទីទូទៅ និង ការបង្កើតទិន្នន័យ និង ទំរង់ការ.
- បង្កើតទំនាក់ទំនងជាមួយបណ្តាទីភ្នាក់ងារឬផ្នែកសមស្របនៅក្នុងខេត្ត និង នៅថ្នាក់ជាតិ( មជ្ឈឹម).

**ការត្រៀមបំរុងបច្ចេកទេស**

- កំណត់ដោយច្បាស់លាស់លទ្ធផលសង្ឃឹមនៃផែនការប្រភេទធនធានព្រៃឈើ លក្ខណៈវិនិច្ឆ័យសំរាប់សំគាល់បណ្តាផ្នែក វិធីសាស្រ្តគូរផែនទី ជញ្ជីង និង សំភារៈ ផែនទីលាតត្រដាង និង បកស្រាយ ធ្វើរបាយការណ៍ .ល. គួររំលឹកផងដែរថាវត្ថុទាំងឡាយចាំបាច់ត្រូវតែអាចបត់បែនបានក្នុងការបញ្ចូលសព្វមូលដ្ឋាន ប្រពន្ធ័ចាត់តាំង និង ចំណេះវិជ្ជាផ្សេងទៀតរបស់មូលដ្ឋានដែលអាចរកបាន.
- បង្ហាញពិតមានចាំបាច់ ទិន្នន័យផ្លូវការ និង ចំណេះវិជ្ជាមូលដ្ឋាន.
- ប្រមូលទិន្នន័យពាក់ពន្ធ័( ផែនទី ទិន្នន័យជាតួលេខរូបថតពីលើអាកាស) .ល.
- ចងក្រង និងចាត់ចែងទុកទិន្នន័យក្នុងចំណែកទិន្នន័យមូលដ្ឋាន បង្កើតប្រពន្ធ័សំរាប់តភ្ជាប់ ទិន្នន័យរបស់មូលដ្ឋាន( ដកស្រង់ចេញពីការធ្វើផែនការមូលដ្ឋានជាមួយនឹងទិន្នន័យថ្នាក់ខេត្ត).

**បញ្ចូលទិន្នន័យជាមួយគ្នាសំរាប់ការធ្វើផែនការសកម្មភាពសហគមន៏ព្រៃឈើនៅថ្នក់ខេត្ត**

- ប្រៀបធៀប និង ប្រមូលផ្តុំពតិមានអំពីព្រៃឈើ សហគមន៏ និង ការប្រើប្រាស់ព្រៃឈើដោយសហគមន៏.
- វាយតំលៃផលិតផលណាដែលសហគមន៏ប្រើប្រាស់ សហគមន៏ត្រូវការផលិតផលទាំងនោះប៉ុន្មាន និង លទ្ធភាពអាចផ្គត់ផ្គង់របស់ព្រៃឈើ.
- វាយតំលៃភាពសមស្របនៃតំបន់ផ្សេងៗគ្នាសំរាប់សគមន៏ព្រៃឈើ.
- រៀបចំ និង ផ្គត់ផ្គង់ផែនទីដែលអាចជួយសហគមន៏ជាមួយនឹងបុគ្គលិកដែលចុះធ្វើការងារដល់ទីកន្លែង អាចទទួលរ៉ាប់រងទទួលធ្វើផែនការ និង មានភាពលំអិតគ្រប់គ្រាន់សំរាប់ប្រើប្រាស់ ក្នុងការអនុវត្តដើម្បីកំណត់តំបន់ព្រៃ ជាព្រៃរបស់ សហគមន៏.
- នៅពេលដែលមានទិន្នន័យថ្មីគ្រប់គ្រាន់ ពិនិត្យផែនទីឡើងវិញ
- បង្កើតឱ្យមានពិតមានសំរាប់អ្នកកសាងផែនការសហគមន៏ព្រៃឈើ សំរាប់បុគ្គលិកចុះអនុវត្តន៏ដល់ទីកន្លែង និង សំរាប់អង្គការដែលជួយទ្រទ្រង់.

**រូប ៥-១ ការធ្វើផែនការថ្នាក់ខេត្ត**




**អត្តសញ្ញាណនៃតំបន់សមស្របសំរាប់សហគមន៍ព្រៃឈើ**

៧៧/ តំបន់ទាំងឡាយដែលមានលក្ខណៈសមស្របខ្ពស់សំរាប់សហគមន៍ព្រៃឈើជាទូទៅមានជាលក្ខណៈប្លែកៗដោយសារ

- មានប្រជាជនមូលដ្ឋានប្រើប្រាស់ព្រៃឈើយ៉ាងសកម្មដូចជា ការរកអុស ឈើសំរាប់សំណង់នៅមូលដ្ឋាន រុក្ខជាតិឱសថ ផ្លែ និង គ្រាប់ឈើ ផ្តៅ និង ឬស្សី ចំណីសត្វ ឬការចិញ្ចឹមសត្វ និងកសិកម្មពនេចរ( រួមបញ្ចូលទាំងខួបនៃការលូតលាស់ ឡើងវិញរបស់ព្រៃឈើ.
- មានប្រវត្តិឬប្រពៃណីប្រើប្រាស់ព្រៃឈើដោយសហគមន៍មូលដ្ឋានដូចជាព្រៃដូនតា ទីកប់ខ្មោច តំបន់ព្រៃជំនឿ ( ព្រៃអារក្ស).
- សហគមន៍មូលដ្ឋានមានចរិតលក្ខណៈសមស្របដោយការតាំងយូរអង្វែង គោរពការដឹកនាំ និង មានសុឆន្ទៈក្នុងការចាត់ចែង.
- បង្ហាញឱ្យដឹងនូវការទទួលផលប្រយោជន៍អំពីការថែរក្សា ឬការបង្កើនធនធានព្រៃឈើមូលដ្ឋានអំពីព្រៃ ឬតំបន់គ្មានព្រៃ

- មូលដ្ឋានសហគមន៍គ្រប់គ្រងព្រៃឈើមានរួចជាស្រេច ឬ មូលដ្ឋានអភិវឌ្ឍន៍សហគមន៍ដែលបញ្ជាក់ពីបទពិសោធន៍មូលដ្ឋានដែលទាក់ទងទៅនឹងសហគមន៍ព្រៃឈើ.
- មានការសង្ឃឹមទុកសមស្របសំរាប់ការចរចារដោះស្រាយចំពោះជំលោះដែលទាក់ទងដល់ការប្រកួតប្រជែងទាមទារតំបន់ព្រៃឈើជាទិសដៅ និងធនធានរបស់វា.

៧៨/ បញ្ហាសមកវិញតំបន់ដែលខ្វះខាតនូវចរិតលក្ខណៈខាងលើទាំងអស់នេះសុទ្ធតែជាបញ្ហាសំរាប់សហគមន៍ព្រៃឈើ និងមានការពិបាកខ្លាំងសំរាប់សហគមន៍ព្រៃឈើ ដែលត្រូវតែប្រមើលមើលទុកជាមុន.

## ៥-៣ ជំហានក្នុងការកសាងផែនកានៅថ្នាក់មូលដ្ឋាន

៧៩/ការធ្វើផែនការសំរាប់ថ្នាក់មូលដ្ឋាន និង ការធ្វើឱ្យមានចលនាសំរាប់សហគមន៍ព្រៃឈើជាធម្មតាធ្វើតាមជំហានទៅមុខ ជាលំដាប់. ជំហាននៅក្នុងផ្នែកនេះ ផ្តល់នូវអនុសាស្ត្រទូទៅ និង ការណែនាំចំពោះសកម្មភាពទំរង់ការ និងសណ្តាប់ធ្នាប់ ក្នុងការធ្វើធ្វើផែនការសហគមន៍ព្រៃឈើនៅថ្នាក់មូលដ្ឋានយ៉ាងណាក៏ដោយ ភាពត្រឹមត្រូវ និង លំដាប់លំដោយនៃសកម្មភាពទាំងឡាយអាចមានការប្រែប្រួល. នៅក្នុងគំរូ ៥-២ បញ្ជាក់អំពីការបង្រួម និង គំនូរវដ្យាក្រាមនៃជំហាន ក្នុងការកសាងផែនការថ្នាក់មូលដ្ឋាន . គោលការណ៍ណែនាំលំអិតបន្ថែមសំរាប់ជំហានទាំងឡាយ និង សំរាប់ការកសាងផែនការសហគមន៍ព្រៃឈើដែលទាក់ទងជាមួយបណ្តាព្រៃសម្បទាន តំបន់ការពារ នឹងមានបញ្ជាក់នូវក្នុងផ្នែកទី ៥ និង តារាងឧបសម្ពន្ធ័.

៨០/ អាស្រ័យលើការជ្រើសរើសសហគមន៍ព្រៃឈើជំហានទាំងនេះអាចមានឡើងជាបន្តបន្ទាប់ដោយក្រុមឬទីភ្នាក់ងារណាមួយដែលចូលរួមក្នុងការទ្រទ្រង់សហគមន៍ដែលបានពង្រីកផែនការគ្រប់គ្រងព្រៃឈើសហគមន៍របសពួកគេ និង បានស្វែងរកការអនុម័តយល់ព្រមរបស់រដ្ឋាភិបាលសំរាប់ពួកគេ. ទីភ្នាក់ងារទាំងនេះក៏អាចជួយសំរួលដំណើរការជ្រើសរើស និង ផ្តល់នូវដំណើរការ បច្ចេកទេស និងការគាំទ្រឯទៀត.

**រូប. ៥-២ ជំហានក្នុងការកសាងផែនការថ្នាក់មូលដ្ឋាន**




លំអិតសកម្មភាពក្នុងជំហាននៃការកសាងផែនការថ្នាក់មូលដ្ឋានត្រូវបានផ្តល់ជូននៅខាងក្រោមៈ

- **ការរៀបចំ**
  - ជំហានដំបូងនៃការរៀបចំនេះគឺមិនមែនជាភារកិច្ចរបស់អាជ្ញធររដ្ឋាភិបាលទទួលខុសត្រូវសំរាប់ការជ្រើសរើសព្រៃសហគមន៍ទេ ជំហានដំបូងគឺការកសាងទំនាក់ទំនងជាមួយអាជ្ញាធរសមស្របដើម្បីធានាសហប្រតិបត្តការកើតមានតាម រយៈដំណើរការជាពិសេសសំរាប់ជ្រើសព្រៃសហគមន៍.
  - បង្កើតក្រុមសំរបសំរួល បញ្ជាក់អំពីកិច្ចសន្យាមុខងារ(ឡើស្រ), ការទទួលខុសត្រូវ , តួនាទី, ការគាំទ្រក្នុងចំណោមបណ្តាអង្គការ និង ទីភ្នាក់ងារដែលបានចូលរួម.
  - បណ្តុះបណ្តាលក្រុមសំរបសំរួល
  - ប្រមូល និង ពិនិត្យឡើងវិញនូវពត៌មានដែលមានស្រាប់អំពីភូមិ, ទិន្នន័យព្រៃឈើ ,ផែនការ, ផែនទី.....ល.
  - ធ្វើទំនាក់ទំនងជាមួយភូមិគោលដៅ និង រៀបចំ
  - កម្មវិធទិសដៅសំរាប់ចុះតាមភូមិ

**ការវិភាគភេទក្នុងការប្រើប្រាស់ឈើ**

ការនេះមានសារៈសំខាន់គឺការប៉ាន់ប្រមាណការប្រើ ប្រាស់ និងគ្រប់គ្រងធនធានព្រៃឈើ ដោយមានការចូលរួម របស់ស្ត្រីភេទពីព្រោះថា:

- ស្ត្រី និង បុរសរមែងមានភាពខុសគ្នាក្នុងតំរូវការ និង ការប្រើប្រាស់ធនធានព្រៃឈើ ហើយរាល់ គំរោងការ ព្រៃឈើ ក៏មានឥទ្ធិពលទៅលើបុរស និង ស្ត្រីខុសគ្នាដែរ.
- ស្ត្រីមានភាពសកម្មក្នុងការប្រើប្រាស់ និង គ្រប់ គ្រងព្រៃឈើ ប៉ុន្តែដោយសារការងារព្រៃឈើ បានត្រូវចាត់ទុកថា ជាការងារបុរស ដូច្នេះ ហើយតួនាទីបុរសចណពោះព្រៃឈើ មិនត្រូវ បានមើលឃើញពីអ្នកចាត់ចែងគំរោង និង អ្នក ធ្វើនយោបាយព្រៃឈើ .
- សមភាព និងយុទ្ធិធម៌ ស្ត្រី និងសហគមន៍ព្រៃ ឈើគោលការណ៍ណែនាំសំរាប់ការរៀបចំ និង

- **ការតំរង់ទិសមូលដ្ឋាន**
    - ណែនាំ, បញ្ជាក់ទិសដៅ និងតួនាទីក្នុងចំណោមទីភ្នាក់ងារ និងប្រជាជនមូលដ្ឋាន.
    - ណែនាំគំនិតសហគមន៍ព្រៃឈើ នយោបាយ ទំហំការងារ
    - រៀបចំប្រពន្ធ័សំភាសន៍ក្រៅផ្លូវការជាមួយក្រុមសហ គមន៍ ធ្វើដំណើរកាត់ភូមិ កាត់ព្រៃប្រមូលទិន្នន័យមូលដ្ឋាន ផ្ទៀងផ្ទាត់អំពីសហគមន៍ ធ្វើការប៉ាន់ប្រមាណ ជាដំបូងអំពូផលប្រយោជន៍មូលដ្ឋាន និង ការពឹងពាក់លើ ព្រៃឈើ (រួមទាំងវិភាគរកលើកដំបូង) កំណត់ជាដំបូង អំពីបណ្តាអ្នកប្រាស្រ័យផលព្រៃឈើ.
    - ពិភាក្សា និង ពិនិត្យឡើងវិញ និង វិភាគលទ្ធផលជាមួយភូមិ
    - ផែនការសំរាប់ជំហានទៅមុខ.
- **ការប្រជុំសហគមន៍ និង ការរៀបចំជាដំបូង**
    - ពិភាក្សាអំពីផលប្រយោជន៍ និងសារៈសំខាន់ក្នុងសហគមន៍ ព្រៃឈើជាមួយភូមិ
    - បង្ហាញឬណែនាំកម្មវិធីផែនការសហគមន៍
    - ផែនការសំរាប់ជំហានបន្តទៅមុខ
- **ការប្រមូលពិតមាន**
    - ការវាយតំលៃសហគមន៍ ស្ថានភាពប្រជារាស្ត្រ ការរៀបចំ សេដ្ឋកិច្ច
    - វាយតំលៃការប្រើប្រាស់ និងការពឹងផ្អែកលើព្រៃឈើ(រួមបញ្ចូលទាំងការវិភាគភេទ) គូរផែនទីតំបន់មូលដ្ឋានរួមទាំងផែនទីប្រើប្រាស់ព្រៃឈើមូលដ្ឋាន ព្រៃឈើដែលទាមទារ(ផែនទីបញ្ជាក់អំពីរបៀបប្រើប្រាស់ដី និងព្រំប្រទល់មូលដ្ឋាន) សារពើភណ្ឌជាដំបូង, វាយតំលៃការគ្រប់គ្រងព្រៃឈើតាមចំណេះដឹងរបស់មូលដ្ឋាន.

**ផែនទីដោយមានការចូលរួម:** ជាវិធីសាស្ត្រមួយសំរាប់សិក្សាពីតំរូវការរបស់សហគមន៍

ក្នុងឆ្នាំ១៩៩៨ ដោយមានការជួយសំរបសំរួលពីបុគ្គលិកអង្គការខុនសឺនវើលវ៉ាយ សមាជិក សហគមន៍នៅភូមិ អារ៉ែន ក្នុងខេត្តពោធិសាត់ បានគូសឡើងនូវផែនទីដែលជា ផ្នែកមួយនៃការចូលរួម ប៉ាន់ប្រមាណពីតម្រូវការផ្សេងៗ របស់សហគមន៍. ដោយបានប្រើប្រាស់នូវសំភារៈ

ដែលមាននៅក្នុងសហគមន៍ ដូចជា ថ្មតំណាងអោយផ្ទះ ស្លឹកឈើ តំណាងអោយតំបន់ព្រៃរិចរិល ផេះតំណាងអោយ ផ្លូវ រទេះនិងផ្លូវថ្នល់ ទាំងនេះបញ្ជាក់នូវទ្រង់ទ្រាយនិងព្រំប្រទល់ភូមិ. ទាំងអស់នេះ អាចអោយសមាជិកសហគមន៍ ពិភាក្សាគ្នាពីបញ្ហាដែលទាក់ទងទៅនឹងធនធានខុសៗគ្នា ហើយនឹក គិតពីលទ្ធភាពដើម្បីកែប្រែ. ផ្តើមចេញពីការងារនេះ អ្នកភូមិបានបង្ហាញអោយឃើញនូវបញ្ហានានា ដែលរួមមានៈ

- ការប្រើប្រាស់ដោយសេរីនៅតំបន់ព្រៃដែលធ្លាប់មានពីមុន បណ្តាលអោយផលិតផលព្រៃឈើ ថយចុះ
- អ្នកភូមិត្រូវធ្វើដំណើរឆ្ងាយដើម្បីស្វែងរកផលិតផលព្រៃឈើចាំបាច់ផ្សេងៗសំរាប់ប្រើប្រាស់
- ការថយចុះនូវផ្ទៃដីព្រៃ ធ្វើអោយកើនឡើងនូវវាលស្មៅសំរាប់សត្វពាហនៈ តែធ្វើអោយថយចុះនូវ ជីវជាតិដី
- ខ្វះការរួមសហការគ្នាក្នុងសហគមន៍ដើម្បីរបឈមមុខទៅនឹងបញ្ហាដែលកើតឡើងទាំងនេះ ការគូសផែនទី និងការពិភាក្សាលើបញ្ហាទាំងនេះ បានបង្កលក្ខណៈងាយស្រួលដល់ដំណើរការក្នុងការកំណត់នូវ សាស្ត្រសមស្របដោយរួមទាំងការបង្កើតតំបន់ព្រៃសហគមន៍ និងអភិវឌ្ឍន៍អោយមានប្រសិទ្ធិភាព នូវផែនការគ្រប់គ្រង នានា.

**ផែនទីដោយមានការចូលរួមៈ ជាវិធីសាស្ត្រមួយសំរាប់សិក្សាពីតំរូវការរបស់សហគមន៍**

ក្នុងឆ្នាំ១៩៩៨ ដោយមានការជួយសំរបសំរួលពីបុគ្គលិកអង្គការខុនសឺនវើលវាយ សមាជិក សហគមន៍នៅភូមិ អារ៉ែន ក្នុងខេត្តពោធិសាត់ បានគូសឡើងនូវផែនទីដែលជា ផ្នែកមួយនៃការចូលរួម ប៉ាន់ប្រមាណពីតម្រូវការផ្សេងៗ របស់សហគមន៍. ដោយបានប្រើប្រាស់នូវសំភារៈ ដែលមាននៅក្នុងសហគមន៍ ដូចជា ថ្មតំណាងអោយផ្ទះ ស្លឹកឈើ តំណាងអោយតំបន់ព្រៃរិចរិល ផេះតំណាងអោយ ផ្លូវ រទេះនិងផ្លូវថ្នល់ ទាំងនេះបញ្ជាក់នូវទ្រង់ទ្រាយនិងព្រំប្រទល់ភូមិ . ទាំងអស់នេះ អាចអោយសមាជិកសហគមន៍ ពិភាក្សាគ្នាពីបញ្ហាដែលទាក់ទងទៅនឹងធនធានខុសៗគ្នា ហើយនឹក គិតពីលទ្ធភាពដើម្បីកែប្រែ. ផ្តើមចេញពីការងារនេះ អ្នកភូមិបានបង្ហាញអោយឃើញនូវបញ្ហានានា ដែលរួមមានៈ

- ការប្រើប្រាស់ដោយសេរីនៅតំបន់ព្រៃដែលធ្លាប់មានពីមុន បណ្តាលអោយផលិតផលព្រៃឈើ ថយចុះ
- អ្នកភូមិត្រូវធ្វើដំណើរឆ្ងាយដើម្បីស្វែងរកផលិតផលព្រៃឈើចាំបាច់ផ្សេងៗសំរាប់ប្រើប្រាស់
- ការថយចុះនូវផ្ទៃដីព្រៃ ធ្វើអោយកើនឡើងនូវវាលស្មៅសំរាប់សត្វពាហនៈ តែធ្វើអោយថយចុះនូវ ជីវជាតិដី
- ខ្វះការរួមសហការគ្នាក្នុងសហគមន៍ដើម្បីប្រឈមមុខទៅនឹងបញ្ហាដែលកើតឡើងទាំងនេះ
- ការគូសផែនទី និងការពិភាក្សាលើបញ្ហាទាំងនេះ បានបង្កលក្ខណៈងាយស្រួលដល់ដំណើរការក្នុងការកំណត់នូវ សាស្ត្រសមស្របដោយរួមទាំងការបង្កើតតំបន់ព្រៃសហគមន៍ និងអភិវឌ្ឍន៍អោយមានប្រសិទ្ធិភាព នូវផែនការគ្រប់គ្រង នានា.

- បើសិនការទាមទារជាន់គ្នា នោះសំរាប់ពិចារណាលើបញ្ហានេះមាននៅក្នុងផ្នែកទី៤.៤.
- ពិភាក្សា ពិនិត្យមើលឡើងវិញ និងវិភាគលទ្ធផល ជាមួយភូមិនានាអំពីជំហានបន្ទាប់នៃគំរោងផែនការ

**<u>ការបង្កើតគណៈកម្មការព្រៃឈើភូមិ ឬសមាគមសហគមន៍ព្រៃឈើ</u>**

- បង្កើតជាដំបូងនូវរចនាសម្ព័ន្ធដឹកនាំ ដើម្បីរៀបចំធ្វើគំរោងផែនការសហគមន៍ព្រៃឈើ
- ពិនិត្យមើលនូវលទ្ធផលឡើងវិញជាមួយភូមិនានា ដោយកំណត់ភូមិចាប់អារម្មណ៍ ក្នុងការបង្កើតព្រៃ សហគមន៍មួយ
- ពិភាក្សាអំពីតួនាទី និងរចនាសម្ព័ន្ធរបស់គណៈកម្មាធិការព្រៃឈើភូមិ ឬ សមាគមសហគមន៍ព្រៃឈើ
- រៀបចំគណៈកម្មាធិការព្រៃឈើភូមិ ឬ សមាគមសហគមន៍ព្រៃឈើ
- ធ្វើគំរោងផែនការសំរាប់ជំហានបន្ទាប់ រួមទាំងបង្កើតលក្ខន្តិកៈប្រសិនបើមានការចាំបាច់
- ការរៀបចំសំណើសំរាប់បង្កើតព្រៃឈើសហគមន៍
- គូសផែនទីដែលមានការចូលរួម ហើយកំណត់ព្រំប្រទល់ព្រៃឈើសហគមន៍

**<u>រៀបចំពាក្យស្នើសុំបង្កើតព្រៃឈើសហគមន៍</u>**

- ពាក្យស្នើសុំនេះ រួមមាន:

ក-ផែនទីបង្ហាញពីខ្សែរយៈទទឹង បណ្តោយ និងពត៌មានទូទៅស្តីពីជីវៈសាស្ត្រនៃធនធាន. បើសិន មានលទ្ធភាពអាចប្រើផែនទីដែលមានមាត្រដ្ឋាន ១:២៥ ០០០ ប៉ុន្តែទោះយ៉ាងណាក៏ដោយ ទ្រង់ទ្រាយផែនទី ដែលប្រើប្រាស់ត្រូវមានខ្សែបរិព័ទ្ធទីតាំងអោយបានច្បាស់លាស់. ឧទារណ៍ ការគូសព្រាងលើផែនទីពីលើអាកាសអាចជាការសមស្របបំផុត.

ខ-បញ្ជាក់ពីទីតាំងភូមិសាស្ត្រ ប្រជាជន របចិញ្ចឹមជីវិតសំខាន់ៗរបស់សហគមន៍ ការប្រើប្រាស់ ព្រៃឈើ និងការប្រើប្រាស់ដីជាទំលាប់របស់សហគមន៍(ក្នុងភូមិមួយឬច្រើន)

ឃ-គោលបំណងនៃការគ្រប់គ្រងទូទៅ

ង-សមាសភាពនៃសមាជិកគណៈកម្មាធិការព្រៃឈើភូមិ ឬ សមាគមសហគមន៍ព្រៃឈើ

ច-ពិភាក្សាឬផ្ទៀងផ្ទាត់ឡើងវិញនូវពាក្យស្នើសុំជាមួយសហគមន៍

ឆ-ផ្ញើពាក្យស្នើសុំទៅអាជ្ញាធរមានសមត្ថកិច្ច

ជ- ធ្វើផែនការសំរាប់ជំហានបន្ទាប់ នៅពេលទទួល

បានការអនុញ្ញាតអោយបង្កើតព្រៃសហគមន៍

| |
|---|
| **បទបញ្ញតិប្រើប្រាស់ព្រៃសហគមន៍** |

គំរោង ណទធក ខេត្តរតនគិរី កំពុងធ្វើក្នុង ភូមិ ភូមិចំនួន៦ ដោយបានព្រាងបទ បញ្ញត្តិសំរាប់ការពារព្រៃឈើក្នុងឃុំពយ ស្រុកអូរជុំ. ពង្រាងនេះបានហាមខាត់ការ ដុតព្រៃ បាញ់ដីរី ខ្លា ខ្លាឃ្មុំ ប្រើប្រាស់អាវុធ ជាតិផ្ទុះក្នុងព្រៃការពារ. ក្នុងនោះ ក៏បាន បញ្ជាក់ផងដែរនូវការអនុញ្ញាតអោយ ប្រមូលអនុផល ព្រៃឈើ ស្របតាម បទបញ្ញត្តិសមាគមព្រៃឈើ ច្បាប់នានា របស់រដ្ឋ និងនិរន្តភាព នៃបរិស្ថាន.

**<u>ផែនការគ្រប់គ្រងព្រៃសហគមន៏</u>**

- និងបញ្ជាក់បន្ថែមនៅក្នុងផ្នែកបន្ទាប់នៃគោលការណែពិនិត្យឡើងវិញនូវផែនការគ្រប់គ្រងព្រៃសហគមន៏ជា បន្តបន្ទាប់ដើម្បីធ្វើអោយប្រាកដថារាល់អ្នកពាក់ព័ន្ធ ទាំងអស់ដែលបានកំណត់បានចូលរួមក្នុងការគ្រប់គ្រង ព្រៃឈើ សមស្របនឹងទំហឹការងារ
- ពិនិត្យមើលបញ្ហានានានិងពង្រឹងគោលបំណងនៃព្រៃឈើ សហគមន៏
- ប្រមូលផ្តុំរាល់ទិន្នន័យនានា និងពត៌មានស្តីពីធនធានព្រៃឈើ. ករណីខ្លះវាអាចសមស្របក្នុងការ អនុវត្តន៏ការ ធ្វើសារពើភ័ណ្ឌព្រៃអោយបានច្បាស់លាស់ដោយផ្តល់នូវលទ្ធផលដែលគួរអោយជឿបាន ហើយបានបង្ហាញនូវ ភាពងាយស្រួលដែលអាចងោយអ្នកភូមិយលបាន
- វិភាគលើវិធីសាស្រ្តនៃគ្រប់គ្រងព្រៃឈើ ដោយមានគ្រោងសកម្មភាពសំរាប់គ្រប់គ្រង និងលទ្ធផលរំពឹងទុក (រួមទាំងកំណត់នូវក៏រិតអនុញ្ញាតប្រមូលផលលើប្រភេទធនធានខុសគ្នា) ហើយបែងចែកនូវកំរៃ និងផល ប្រយោជន៏
- ពិភាក្សានិងវិភាគលើវិធីសាស្រ្តនៃការគ្រប់គ្រងព្រៃឈើជាមួយសហគមន៏ ដោយជ្រើសរើសនូវវិធីសាស្រ្ត គ្រប់គ្រងណាដែលពេញចិត្ត
- រៀបចំនូវផែនការគ្រប់គ្រងព្រៃឈើសហគមន៏ ដោយមានបទបញ្ញត្តិ ក៏រិតអនុញ្ញាតប្រមូលផលលើ ប្រភេទ ធនធានខុសគ្នា និងគោលការណ៏ណែនាំសំរាប់បែងចែកប្រយោជន៏
- ពិភាក្សានិងផ្ទៀងផ្ទាត់ឡើងវិញនូវផែនការគ្រប់គ្រងព្រៃឈើសហគមន៏ រួមទាំងលក្ខន្តិកៈគណៈកម្មាធិការ ព្រៃឈើភូមិ ឬ សមាគមសហគមន៏ព្រៃឈើជាមួយសហគមន៏
- ផ្ញើផែនការគ្រប់គ្រងព្រៃឈើសហគមន៏ និងលក្ខន្តិកៈគណៈកម្មាធិការព្រៃឈើភូមិ ឬសមាគមសហគមន៏ ព្រៃឈើទៅអាជ្ញាធរពាក់ព័ន្ធ.

សេចក្តីពិស្តារស្តីពីវិធីសាស្រ្ត និងបែបបទសំរាប់បំពេញសកម្មភាព ត្រូវបានកំណត់ក្នុងជំហាននានានៅក្នុងគោល លំនាំនេះ.

**គំនូសបំព្រួញ ៥.៣ សង្ខេបជំហាននាននៅថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋានសំរាប់ផែនការសហគមន៏ព្រៃឈើ**

| | |
|---|---|
| **ការរៀបចំ** | - បង្កើតនិងបណ្តុះបណ្តាលដល់ក្រុមសំរបសំរួល<br>- ប្រមូលនិងពិនិត្យមើលពត៌មានដែលមានស្រាប់ៈទិន្នន័យភូមិនិងព្រៃឈើ<br>- ជួបជាមួយមនុស្សសំខាន់ៗនិងរៀបចំធ្វើផែនការជាមួយភូមិគោលដៅ |
| **តំរង់ទិសដៅសហគមន៍** | - ធ្វើការណែនាំនិងកំនត់គោលបំណងនិងតួនាទី<br>- បង្ហាញពីគំនិត គោលនយោបាយ សក្តានុពលភាពនៃសហគមន៍ព្រៃឈើ<br>- បង្កើតអោយមានមូលដ្ឋានប្រមូលពត៌មានអំពីសហគមន៍ការពឹងពាក់លើធនធាន<br>- ព្រៃឈើ កំណត់អ្នកពាក់ព័ន្ធនានា |
| **រៀបចំរចនា<br>សម្ព័ន្ធដឹកនាំ** | - ពិភាក្សាពីការចាប់អារម្មណ៍លើការងារសហគមន៍ព្រៃឈើជាមួយភូមិគោលដៅ<br>- ណែនាំអោយមានកម្មវិធីផែនការព្រៃសហគមន៍<br>- ធ្វើគំរោងផែនការសំរាប់ជំហានបន្ទាប់ |
| **ប្រមូលពត៌មាន** | - ប៉ាន់ស្មានពីតម្រូវការរបស់សហគមន៍ លើការប្រើប្រាស់ធនធានព្រៃឈើឬការ ពឹងពាក់លើការកាន់កាប់ដី សារពើភ័ណ្ឌ និង ការគ្រប់គ្រងព្រៃឈើរបស់ជនជាតិ<br>- កំណត់និងវិភាគក្នុងការទាមទារលើតំបន់តែមួយជាន់គ្នា<br>- ពិភាក្សាលទ្ធផលជាមួយភូមិគោលដៅនានា និង ធ្វើផែនការសំរាប់ ជំហាន បន្ទាប់ |
| **ការបង្កើតគណៈកម្មការ<br>ព្រៃឈើភូមិ<br>ឬសមាគមសហគមន៍<br>ព្រៃឈើ** | - បង្កើតជាដំបូងនូវរចនាសម្ព័ន្ធដឹកនាំ ដើម្បីរៀបចំធ្វើផែនការ<br>- កំណត់ភូមិចាប់អារម្មណ៍ ក្នុងការបង្កើតព្រៃ សហគមន៍<br>- បង្កើតគណៈកម្មាធិការព្រៃឈើភូមិ ឬ សមាគមសហគមន៍ព្រៃឈើ ប្រសិនបើអាច<br>- ធ្វើផែនការសំរាប់ជំហានបន្ទាប់ |
| **ការរៀបចំសំណើសំរាប់<br>បង្កើតព្រៃឈើសហគមន៍** | - គូសផែនទីដែលមានការចូលរួម ហើយកំណត់ព្រំប្រទល់ព្រៃឈើសហគមន៍<br>- រៀបចំពាក្យស្នើសុំបង្កើតព្រៃឈើសហគមន៍<br>- ពិភាក្សាឬផ្ទៀងផ្ទាត់ឡើងវិញនូវពាក្យស្នើសុំជាមួយសហគមន៍<br>- ធ្វើពាក្យស្នើសុំទៅអាជ្ញាធរមានសមត្ថកិច្ច<br>- ធ្វើផែនការសំរាប់ជំហានបន្ទាប់ នៅពេលទទួលបានការអនុញ្ញាតអោយបង្កើត ព្រៃសហគមន៍ |
| **ផែនការគ្រប់គ្រង<br>ព្រៃសហគមន៍** | - ពិនិត្យសហគមន៍ឡើងវិញនិងសិក្សាពីតម្រូវការនៃប្រើប្រាស់ឬពឹងពាក់លើព្រៃឈើ កំណត់អ្នកពាក់ព័ន្ធ កំណត់បញ្ហានានានិងគោលបំណងសហគមន៍ព្រៃឈើ<br>- រៀបរាប់ពីធនធានព្រៃឈើ<br>- វិភាគលើការគ្រប់គ្រងព្រៃឈើ<br>- ជ្រើសរើសនូវវិធីសាស្ត្រ គ្រប់គ្រងណាមួយដែលពេញចិត្ត<br>- រៀបចំនូវផែនការគ្រប់គ្រងព្រៃឈើសហគមន៍និងលក្ខន្តិកៈកម្មាធិការព្រៃឈើភូមិឬ សមាគមសហគមន៍ព្រៃឈើជាមួយសហគមន ជាមួយសហគមន៍<br>- ធ្វើផែនការគ្រប់គ្រងព្រៃឈើសហគមន៍ និងលក្ខន្តិកៈទៅអាជ្ញាធរពាក់ព័ន្ធ |

## ការទាមទារស្នើសុំបង្កើតព្រៃឈើសហគមន៍ត្រួតគ្នាលើកន្លែងតែមួយ

៨១។ ជាចាំបាច់ ត្រូវដោះស្រាយទំនាស់ដែលកើតចេញពីការទាមទារ ស្នើសុំបង្កើតព្រៃឈើសហគមន៍ត្រួតគ្នា លើកន្លែងតែមួយ ក្នុងដំណាក់កាលធ្វើផែនការ. ក្នុងបំណងជៀសវាង ឬកាត់បន្ថយការលំបាកក្នុងពេលខាងមុខ

អោយនៅកំរិតអប្បរមា. ទំនាស់ដោយសារការទាមទារកើតឡើង វានឹងបង្កការលំបាកថែមទៀត ហើយ អាចប៉ះពាល់ដល់ប្រសិទ្ធិភាពនៃដំណើការមុនពេលប្រព័ន្ធគ្រប់គ្រងសហគមន៍មួយត្រូវបានបង្កើតឡើង. ក្រៅពីនេះវា មាន សារៈសំខាន់ ចំពោះអ្នកពាក់ព័ន្ធនានា រួមទាំងអ្នកប្រើប្រាស់ទាំងអស់ និងអ្នកទាមទារស្នើសុំយកតំបន់ព្រៃឈើ ដែល តម្រូវអោយ មានការកំណត់ និងបញ្ចូលទៅក្នុងការពិគ្រោះយោបល់ និងក្នុងដំណើការរៀបចំគំរោង ពីព្រោះមានតែអ្នកប្រើប្រាស់ និងអ្នកស្នើសុំ ស្ម័គ្រចិត្តអនុវត្តន៍ តាមកិច្ចព្រមព្រាង មួយក្នុងការគ្រប់គ្រង ដែលជំរុញអោយមានការសហការគ្នា. ការទំនាក់ទំនង និងការសំរុះ សំរួលគ្នា ក្នុងចំណោម អ្នកប្រើប្រាស់ និងអ្នកទាមទារ ចំបងបំផុតត្រូវដោះស្រាយទំនាស់ អោយបានសំរេច. ការប្រជែងគ្នាទាមទារ អាចកើតមាននៅក្នុងសហគមន៍ និងរវាងសហគមន៍ ជាមួយអ្នកប្រើប្រាស់ ឬ*អ្នកទាមទារពីខាងក្រៅសហគមន៍*.

82. ការដោះស្រាយនូវនៅការប្រជែងគ្នាទាមទារ ដើម្បីស្នើសុំបង្កើតព្រៃឈើសហគមន៍មួយ តម្រូវអោយ មានការកំណត់ច្បាស់លាស់ចំពោះអ្នកប្រើប្រាស់ និងអ្នកទាមទារទាំងនោះ ថាតើអ្នកណាចូលរួមសហការក្នុងការ គ្រប់គ្រងក្នុងតំបន់ព្រៃឈើពិសេសមួយ ដូចជាព្រៃឈើសហគមន៍ ហើយអ្នកណាមាន សហគមន៍មកដល់ ពេល បច្ចុប្បន្ន. នេះអាចជាដំណើរការដ៏វែងឆ្ងាយមួយ រួមមានទាំងការប្រជុំជាមួយអ្នកពាក់ព័ន្ធនៅសហគមន៍ ដើម្បីកំណត់នូវអ្នកចាប់ ចាប់អារម្មណ៍ និងស្ម័គ្រចិត្តចូលរួមសហការក្នុងការគ្រប់គ្រង ក្នុងតំបន់ព្រៃឈើពិសេសមួយ ដូចជាព្រៃឈើសហគមន៍. ដំណើការ ការធ្វើសេចក្តីសំរេចចិត្ត និង កិច្ចព្រមព្រាងគួរតែរៀបចំជាឯកសារ អោយបានច្បាស់លាស់.

៨៣។ ការប្រជែងគ្នាទាមទារ ក្នុងចំណោមអ្នកប្រើប្រាស់ព្រៃឈើ និងអ្នកទាមទារក្នុងសហគមន៍ គួរដោះស្រាយ ឡើងវិញដូចខាងក្រោមៈ

- ចំពោះទំនាស់ក្នុងភូមិតែមួយៈ អ្នកចូលរួមដោះស្រាយមាន រដ្ឋបាលភូមិ គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ឬសហគមន៍ព្រៃឈើភូមិ ប្រសិនបើបានបង្កើត
- ចំពោះទំនាស់រវាងភូមិផ្សេងគ្នា ដែលចូលរួមសហការក្នុងព្រៃសហគមន៍ អ្នកចូលរួមដោះស្រាយមាន រដ្ឋបាលឃុំ ឬស្រុក៥ ឬសមាគមសហគមន៍ព្រៃឈើភូមិ ប្រសិនបើបានបង្កើត ការប្រជែងគ្នាទាមទារ រវាងសហគមន៍និងអ្នកប្រើប្រាស់ ឬអ្នកទាមទារក្រៅសហគមន៍ អាចកើតឡើង ដោយសារៈ
- តំបន់មួយមានការទាមទារដោយភូមិច្រើន ក្នុងនោះយ៉ាងហោចណាស់មានភូមិមួយ មិនចូលរួម សហការ ក្នុងការគ្រប់គ្រងតំបន់ព្រៃឈើពិសេសមួយ ដូចជាព្រៃឈើសហគមន៍
- តំបន់មួយត្រូវបានយល់ព្រម ឬជាដីសម្បទានសំរាប់ដំណាំកសិ-ឧស្សាហកម្ម ព្រៃសម្បទាន ឡូនេសាទ ឬ សំរាប់សម្បទានផ្សេងទៀត
- តំបន់ដែលស្ថិតនៅតំបន់ពិសេស ដូចជា តំបន់ការពារ តំបន់ព្រៃលិចទឹកឬព្រៃកោងកាង ឬតំបន់ ប្រើប្រាស់សំរាប់បំរើអោយវិស័យយោធា
- តំបន់ស្ថិតនៅក្រោមការកាន់កាប់របស់ឯកជន

- តំបន់ត្រូវបានទាមទារជាបុគ្គលឬជាក្រុមដោយអ្នកផ្សេង ករណីនេះយោងទៅតាមភាពខ្វះខាតនៅក្នុងការ រៀបចំច្បាប់ប្រើប្រាស់ដី.

[៥] ករណីខ្លះហគមន៍អាចនៅក្នុងឃុំឬស្រុកតែមួយ ប៉ុន្តែករណីខ្លះទៀតសហគមន៍មាននៅឃុំឬស្រុកផ្សេងគ្នា.

**ការបង្កើតតំបន់គ្រប់គ្រងនិងកំណត់ព្រំប្រទល់ ដែលអនុវត្តន៏ដោយអង្គការ ៣ នៅខេត្តសៀមរាប**

អង្គការ FAO អនុវត្តន៏កម្មវិធី" ចូលរួមគ្រប់គ្រងធនធានធម្មជាតិក្នុងតំបន់បឹងទន្លេសាប" គំរោងបានផ្តើមគំនិតរៀបចំ ដំណើរការកំណត់ និងបញ្ជាក់នូវការគ្រប់គ្រងព្រមទាំង ព្រំប្រទល់ព្រៃសហគមន៏ក្នុងខេត្តសៀមរាប ដោយមានការ សំរបសំរួល ពិភាក្សាជាមួយសមាជិកសហគមន៏ និងអ្នកផ្សេងទៀតដែលប្រើប្រាស់ធនធាន ដើម្បីកំណត់រកអ្នក ប្រើប្រាស់ពិតប្រាកដ. តាមរយៈដំណើរការនេះ ជំលោះនៃការទាមទារធនធានពីប្រជាជនក្រៅតំបន់ ត្រូវបានកំណត់. កិច្ចពិភាក្សាក៏បានធ្វើឡើងផងដែរ ជាមួយមេឃុំក្នុងឃុំជិតខាង និងជាមួយកងកំលាំងប្រដាប់អាវុធក្នុងតំបន់ ដើម្បី ធ្វើអោយប្រាកដថា ការកំណត់ព្រំប្រទល់ព្រៃសហគមន៏មានការយល់ព្រមពីភាគីនានា. បង្គោលត្រូវបានដាំនៅលើដីតាម ព្រំប្រទល់ ហើយផ្ទៀងផ្ទាត់ជាក់ស្តែងជាមួយសមាជិកសហគមន៏ ដើម្បីអោយច្បាស់ថាព្រំប្រទល់នេះស្ថិតនៅជាយូរិ អង្វែង

1. ការដោះស្រាយឡើងវិញចំពោះការប្រជែងទាមទារ សំរាប់ព្រៃសហគមន៏មួយ រវាងសហគមន៏និងអ្នកប្រើប្រាស់ ឬអ្នកទាមទារពីក្រៅសហគមន៏ ជាលក្ខខ័ណ្ឌមួយត្រូវត្រៀមមុន សំរាប់គំរោងព្រៃសហគមន៏មួយ ។ ការប្រជែងគ្នា ទាមទារ អាចដោះស្រាយតាមវិធីពីរយ៉ាងដូចខាងក្រោមៈ

- ការប្រជែងគ្នាទាមទារ ត្រូវដកចេញឬបដិសេដធ៏ចោល នូវការយល់ព្រមលើការស្នើសុំបង្កើតព្រៃ សហគមន៏ ដោយទុកជាមោឃៈនូវកិច្ចព្រមព្រាង. សហគមន៏នឹងតម្រូវអោយមានការបន្ថយ ឬកែប្រែ នូវសំណើសុំបង្កើតព្រៃសហគមន៏ ដើម្បីដោះស្រាយទំនាស់ជាមួយអ្នកទាមទារផ្សេងទៀត ហើយសំរុះសំរួលគ្នាជាថ្មីអោយបានសំរេច.
- អ្នកប្រជែងទាមទារ ព្រមព្រាងសហការចូលរួមក្នុងយុទ្ធសាស្ត្រគ្រប់គ្រង ដើម្បីអោយមានការឯកភាព លើសំណើសុំបង្កើតព្រៃសហគមន៏ ដែលបានដោះស្រាយទំនាស់ឡើងវិញ ដោយបង្កើតនូវក៏រិតលើសិទ្ធិ និងកាតព្វកិច្ច នៃអ្នកទាមទាររៀង១ខ្លួន ក្នុងតំបន់ឬធនធានក្នុងព្រៃសហគមន៏. ជាទូទៅ សហគមន៏នឹង តម្រូវអោយមានការយល់ព្រមទាំងបង្ខំ លើការប្រើប្រាស់ព្រៃសហគមន៏ ហើយអាចអោយអ្នកទាមទារ ដ៏ទៃទៀត សំរេចអោយបាននូវគោលបំណងរបស់គេ.

2. តំបន់ដែលមានការប្រជែង ឬអះអាងមិនច្បាស់លាស់ លើដីព្រៃដែលមានស្រាប់រវាងសហគមន៏ ( ភូមិមួយ ឬច្រើន) និងម្ចាស់ព្រៃសម្បទាន ឬ ដីសម្បទានសំរាប់ដំណាំកសិកម្ម ការបង្កើតគណៈកម្មការពិគ្រោះយោបល់ សហគមន៏ព្រៃឈើ( គពសព) គួរតែមានវេទិការសមស្រប ដើម្បីបង្កើតនិងសំរួបសំរួល ទំនាក់ទំនង និងដោះស្រាយ ទំនាស់រវាងសហគមន៏ និងម្ចាស់ព្រៃសម្បទាន៦ ។ កិច្ចព្រមព្រាងមួយគួររៀបចំដើម្បីកំណត់បញ្ហាអោយបានច្បាស់ និងចងក្រងឯកសារទាក់ទងនឹង សេចក្តីសំរេចចិត្តនានា ។ គពស គួរមានតំណាងពីព្រៃឈើសហគមន៏ ឬសមាគមសហគមន៏ព្រៃឈើដែលមាននៅក្នុង ភូមិ

តំណាងអាជ្ញាធរមានសមត្ថកិច្ចទទួលខុសត្រូវព្រៃសម្បទាន និងអាជ្ញាធរឃុំឬស្រុក ហើយគួរប្រត្តិបត្តិតាមលក្ខន្តិកៈ ដែលរៀបចំឡើងដោយ គពសព។ គពសព គួរប្រត្តិបត្តិក្នុងសមាគម ជាមួយគណៈកម្មាធិការអភិវឌ្ឍន៍ឃុំនិង

គណៈកម្មាធិការអភិវឌ្ឍន៍ស្រុក (គអឃ និង គអស) ប្រសិនបើបានបង្កើត.

៦ ពង្រាងអនុក្រិត្យស្តីពីការគ្រប់គ្រងព្រៃសម្បទាន បានថែងពីការបង្កើត" គណៈកម្មការពិគ្រោះយោបល់អចិន្ត្រៃយ៍ សំរាប់សហគមន៍ ដូចជាចំណុចប្រសព្វមួយសំរាប់ធ្វើការពិភាក្សា និងដោះស្រាយបញ្ហានានាទាក់ទងទៅនឹងព្រៃ សម្បទាន នឹងសហគមន៍ នៅក្នុងព្រៃសម្បទាន និងជាប់តំបន់ព្រៃសម្បទាន" . គោលការណែនាំ រួមបញ្ចូលទាំងការថែងដែលរួមមានទាំងការកែប្រែ ដែលបង្ហាញ អោយឃើញ នូវលក្ខណៈប្លែកពីគ្នារវាង គំរោងអាណាចិន្ត្រៃយ៍ របស់គណៈកម្មាធិការ (គណៈកម្មការពិគ្រោះយោបល់របស់សហគមន៍) និង ដើម្បីកំណត់ពីតម្រូវការ គណៈកម្មាធិការគ្រប់គ្រងព្រៃឈើ( គណៈកម្មាធិការគ្រប់គ្រងព្រៃឈើលើតំបន់រួមគ្នា).

3. តំបន់ដែលមានការប្រជែង ឬអះអាងមិនច្បាស់លាស់ លើដីព្រៃដែលមានស្រាប់ រវាងសហគមន៍ (ភូមិមួយ ឬ ច្រើន) និងព្រៃការពារ៧ ឬ តំបន់ពិសេសផ្សេងទៀត (ដូចជាព្រៃលិចទឹក ព្រៃកោងកាង ព្រៃរដ្ឋដាំ .ល.) គណៈកម្មការនេះ គួរតែសំរួបសំរួលក្នុងការទំនាក់ទំនង និង ដោះស្រាយទំនាស់រវាង សហគមន៍ និងអាជ្ញាធរ គ្រប់គ្រងព្រៃឈើ. គពសព គួរមានតំណាងពីព្រៃឈើសហគមន៍ ឬសមាគមសហគមន៍ព្រៃឈើដែលមានក្នុងភូមិ តំណាងអាជ្ញាធរមានសមត្ថកិច្ចទទួលខុសត្រូវ ព្រៃការពារ ឬតំបន់ពិសេស រួមជាមួយអាជ្ញាធរឃុំឬស្រុក ហើយគួរប្រត្តិបត្តិតាមលក្ខន្តិកៈ ដែលរៀបចំឡើងដោយ គពសព. គពសព គួរប្រត្តិបត្តិក្នុងសមាគម ជាមួយគណៈកម្មាធិការអភិវឌ្ឍន៍ឃុំនិង គណៈកម្មាធិការអភិវឌ្ឍន៍ស្រុក (គអឃ និង គអស) ប្រសិនបើបានបង្កើត.

4. ក្នុងតំបន់ដែលមានការប្រជែងទាមទារ លើដីព្រៃឈើមានស្រាប់ហើយមានលំនឹងក្នុងធម្មជាតិ និងតម្រូវអោយ មានការចែករំលែកគ្នាប្រើប្រាស់ក្នុងតំបន់ រវាងសហគមន៍មួយ(ឬច្រើន) និង អាជ្ញាមានសមត្ថកិច្ច ដូចជាការទាមទារ របស់សហគមន៍ក្នុងព្រៃឈើសម្បទាន ដីសម្បទានសំរាប់ដំណាំកសិកម្ម ដីព្រៃគ្រប់គ្រងដោយរដ្ឋ ឬតំបន់ការពារ គណៈកម្មការគ្រប់គ្រងព្រៃឈើរួមគ្នាមួយ អាចបង្កើតឡើង ដើម្បីផ្តល់នូវយន្តការអចិន្ត្រៃយ៍មួយ សំរាប់គ្រប់គ្រង ព្រៃឈើរួមគ្នា ក្នុងតំបន់ត្រួតស៊ីគ្នា.

**គំនូសបំព្រួញ ៩.៤ រចនាសម្ព័ន្ធសហគមន៍ព្រៃឈើនិងព្រៃសម្បទាន**




<u>កំណត់សំគាល់</u>

-គពភ: គណៈកម្មាធិការព្រៃឈើភូមិ

-សសព: សមាគមន៍សហគមន៍ព្រៃឈើ

-គពសព: គណៈកម្មការពិគ្រោះយោបល់សហគមន៍ព្រៃឈើ

បទដ្ឋានបច្ចេកទេស

**សេចក្តីផ្តើមអំពីបទដ្ឋានបច្ចេកទេស**

81. ផ្នែកនេះផ្តល់ការបកស្រាយលំអិតអំពីសំណួមពរនិងពត៌មាន លើផ្នែកសំខាន់នៃសហគមន៍ព្រៃឈើនៅកម្ពុជា ជាពិសេសរបៀបបង្កើតសហគមន៍ព្រៃឈើ ហើយនិង ការផ្តោតការយកចិត្តទុកដាក់ជាពិសេសនិង ដំណើរការសំរាប់ព្រៃសម្បទាននិងព្រៃការពារ. ពត៌មានទាំងនោះត្រូវបានបង្ហាញក្នុងផ្នែកផ្សេងៗ ពីព្រោះតាមបទពិសោធន៍ ដែលមានតាមសហគមន៍ព្រៃឈើនានក្នុងប្រទេស ហើយចាំបាច់ត្រូវធ្វើអោយវាទាន់សភាពការតាមតែអាចលំអិតទៅបានក្នុងគោលការណ៍ណែនាំ. តាមរយៈនេះគោលលាំនាំអាចបន្តកែសំរួល អោយក្លាយទៅជាមធ្យោបាយមួយសំរាប់អ្នកធ្វើការតាមសហគមន៍.

**គំរោងរៀបចំបង្កើតព្រៃឈើសហគមន៍**

81. ការរៀបចំជាផ្លូវការ សំរាប់បង្កើតសហគមន៍ព្រៃឈើ ឈរលើមូលដ្ឋានឯកភាពគ្នាក្នុង ចំណោមអ្នក ពាក់ព័ន្ធ ទាំងអស់ ជាពិសេសរវាងសហគមន៍ប្រើប្រាស់ព្រៃឈើនិងស្ថាប័នរដ្ឋ វាជាជំហានសំខាន់ណាស់ក្នុងការបង្កើត និង ប្រើប្រាស់សហគមន៍ព្រៃឈើ នេះជាដំណើការផ្លូវការ ដែលអាចហៅថាជាដំណើការគ្រោងរៀបចំហើយ ជាជោគ ជ័យនៃតម្រូវការដើម្បីបញ្ចប់នៅដំណើការផ្លាស់ប្តូរពតិមាននិងសំរុះសំរួល រវាងសហគមន៍និងអាជ្ញាធររៀបចំគំរោង. ផ្នែកនេះរៀបរាប់ពីជំហាននានាដើម្បីឈានទៅសំរេចជោគ ជ័យក្នុងការរៀបចំសហគមន៍.

<u>ពាក្យស្នើសុំបង្កើតព្រៃឈើសហគមន៍</u>

៨២។ បន្ទាការផ្ទៀងផ្ទាត់និងពិនិត្យលើការឯកភាពពីសហគមន៍ ហើយពាក្យស្នើសុំគួរផ្ញើទៅអាជ្ញាធរមានសមត្ថកិច្ច ក្នុងខេត្ត តាមផ្នែកដូចខាងក្រោមៈ

- សំណើសុំបង្កើតព្រៃសហគមន៍ក្នុងដែនព្រៃ ព្រៃលិចទឹក ព្រៃកោងកាង ឬក្រៅតំបន់ព្រៃ ត្រូវស្នើទៅ មន្ទីរកសិកម្មខេត្ត (ចម្លងជូនខេត្តសាម៉ី ដែលបានបង្កើតស្ថាប័នសំរាប់សហគមន៍ព្រៃឈើ)
- សំណើសុំបង្កើតព្រៃសហគមន៍ក្នុងដែនព្រៃការពារ ត្រូវស្នើទៅមន្ទីរបរិស្ថានខេត្ត ផ្នែកគ្រប់គ្រងតំបន់ ព្រៃការពារ(ចម្លងជូនខេត្តសាម៉ី ដែលបានបង្កើតស្ថាប័នសំរាប់សហគមន៍ព្រៃឈើ)
- សំណើសុំបង្កើតព្រៃសហគមន៍ក្នុងដែនព្រៃ ពុំមានការកំណត់ច្បាស់លាស់ ត្រូវស្នើទៅមន្ទីរកសិកម្មខេត្ត និងចម្លងជូនលេខាធិការដ្ឋានការសហគមន៍ព្រៃឈើ

៨១។ ពាក្យស្នើសុំគួរចម្លងជូនសាលាស្រុកក្នុងពេលតែមួយ ផ្សព្វផ្សាយក្នុងកំឡុងពេលមួយខែ

**គំនូសបំព្រួញ ៦.១ ដំណើការដើម្បីទទួលស្គាល់សហគមន៍ព្រៃឈើជាផ្លូវការ**




<u>កំណត់សំគាល់</u>

គបសខ គណៈកម្មការប្រត្តិបតិសហគមន៍ព្រៃឈើខេត្ត

គអជខ គណៈកម្មការអភិវឌ្ឍន៍ជនបទខេត្ត

ពេលអាជ្ញាធរមានសមត្ថកិច្ចទទួលពាក្យស្នើសុំ (ឬឯកសារចំលង) ហើយគួរផ្តល់បង្កាន់ដៃទទួលពាក្យ ដល់ សហគមន៍ ដោមានបញ្ជាក់ពីកាលបរិច្ឆេទ និងឈ្មោះទទួលពាក្យ. សហគមន៍គួរចម្លងទុកនូវពាក្យស្នើសុំ និងបង្កាន់ ទទួលពាក្យ.

81. អាជ្ញាធរមានសមត្ថកិច្ចដែលបានទទួលពាក្យស្នើសុំ ទទួលខុសត្រូវចំពោះការផ្តល់ដំណឹងដល់អាជ្ញាធរខេត្ត រួមទាំងក្រុមពិគ្រោះយោបល់ចូលរួមក្នុងការងារសហគមន៍ព្រៃឈើ និង អាជ្ញាធរថ្នាក់ជាតិ ដែលពាក់ព័ន្ធ នឹង ពាក្យស្នើសុំ ក្នុងកំឡុងពេលពីរសប្តាហ៍បន្ទាប់ពីបានទទួលពាក្យស្នើសុំ.

**ការកត់សំគាល់និងការអង្កេត**

81. ក្នុងរយៈពេលមួយខែនៃការកត់សំគាល់ និងការអង្កេតនៅលើពាក្យស្នើសុំ សំរាប់បង្កើតព្រៃសហគមន៍ គួរតែផ្តល់អោយបានឆាប់. ការិយាល័យខេត្ត ស្រុកដែលបានទទួលពាក្យ ត្រូវធ្វើការកត់សំគាល់និងអង្កេត ក្នុងកំឡុងពេលមួយខែ. ប្រសិនបើគ្មានការជំទាស់តវ៉ា ក្នុងដំណាក់កាលនេះ ដំណើរការនៃពាក្យស្នើសុំ គួរតែបន្ត អោយបានឆាប់រហ័ស. ប្រសិនបើមានការជំទាស់តវ៉ាក្នុងការបង្កើតព្រៃសហគមន៍ អាជ្ញាធរខេត្ត ស្រុកដឹង បញ្ហានេះហើយ គួរផ្តល់ដំណឹងដល់គណៈកម្មាធិការព្រៃសហគមន៍ ឬសមាគមសហគមន៍ព្រៃឈើវិញ ក្នុងកំឡុងពេល ពីរសប្តាហ៍. ការជំទាស់តវ៉ាតម្រូវអោយមានការដោះស្រាយឡើងវិញ ក្នុងដំណើការរត់បែបបទស្នើសុំនេះ.

**ការផ្ទៀងផ្ទាត់ឡើងវិញនូវពាក្យស្នើសុំ**

81. អាជ្ញាធរខេត្តដែលទទួលខុសត្រូវ៍ រួមទាំងអាជ្ញាធរស្រុក គួរតែពិនិត្យឡើងវិញនូវពាក្យស្នើសុំ ដើម្បីផ្ទៀងផ្ទាត់ថាពតិមានក្នុងឯកសារពិតជាត្រឹមត្រូវ គ្មានទំនាស់ ក្នុងការសុំបង្កើតសហគមន៍ព្រៃឈើ. ការចុះស្រាវជ្រាវ គួរដំណើរការ និងបំពេញអោយចប់ក្នុងកំឡុងពេលពីរខែ ចាប់ពីពេលបញ្ចប់ដំណាក់ កត់សំគាល់ និងការអង្កេត .

៨២។ អាជ្ញាធរខេត្តដែលទទួលខុសត្រូវ គួរចេញនូវកិច្ចព្រមព្រាងព្រៃឈើងសហគមន៍ ទៅសហគមន៍ ក្នុងរយៈពេល

ពីរសប្តាហ៍ ចាប់ពីពេលបញ្ចប់ដំណាក់ចុះស្រាវជ្រាវ លើកលែងតែពាក្យស្នើសុំផ្ទុយពីការពិតឬមិនបានបំពេញអោយ ច្បាស់លាស់. កិច្ចព្រមព្រាង ជាផ្នែកមួយចែងក្នុងគំរោងស្នើសុំបង្កើតសហគមន៍ព្រៃឈើ ដែលបានផ្តល់នូវសិទ្ធិ និងកាតព្វកិច្ចដើម្បីអោយសហគមន៍ទទួលខុសត្រូវ ហើយចុងបញ្ចប់នៃប្រការនានាមានក្នុងលក្ខន្តិកៈ ត្រូវមានការយល់ព្រមពីគណៈកម្មាធិការព្រៃសហគមន៍ឬសមាគមសហគមន៍ព្រៃឈើ និងស្របតាមផែនការគ្រប់គ្រងព្រៃឈើ សហគមន៍ និង លក្ខន្តិកៈយោងតាមការណែនាំ និងទំរង់ការជាក់លាក់ទាំងឡាយ.

83. ប្រសិនបើពាក្យស្នើសុំត្រូវបានកំណត់ថាមិនពិតប្រាកដ និងបំពេញអោយបានច្បាស់លាស់ សមត្ថកិច្ចដែលទទួលខុសត្រូវនៅខេត្ត ត្រូវផ្តល់ពតិមានទៅសហគមន៍ក្នុងកំឡុងពេលពីរសប្តាហ៍នៃដំណាក់កាលចុះស្រាវជ្រាវ ដោយមាន

ពន្យល់លំអិតពីពត៌ដែលត្រូវបំពេញបន្ថែម. សហគមន៍គួរផ្តល់ពត៌មានបន្ថែមដល់ សមត្ថកិច្ចដែលទទួលខុសត្រូវនៅ ខេត្ត ហើយសមត្ថកិច្ចនោះ ត្រូវបំពេញពត៌មានបន្ថែម ដោយអនុវត្តន៏ការងារនេះក្នុង រយៈពេល២ខែ.

84. សហគមន៍អាចស្នើសុំដោយគ្មានការប្រឆាំងតប ឬ ដកពាក្យស្នើសុំបញ្ជូនទៅគេណៈកម្មាធិការប្រតិបត្តិសហគមន៍ ព្រៃឈើ ឬគណៈកម្មាធិការអភិវឌ្ឍន៏ជនបទខេត្ត ដោយផ្តល់នូវយុត្តិធម៌សំរាប់ការងារនេះ.

**គំរោងនិងការចុះឈ្មោះក្នុងបញ្ជីនៃព្រៃសហគមន៍**

៨១។ កិច្ចព្រមព្រាងជាមួយស្ថាប័នពាក់ព័ន្ធ គួរតែត្រូវបានចុះហត្ថលេខាលើឯកសារពីរច្បាប់ ដោយអាជ្ញាធរមាន សមត្ថកិច្ច ដូចខាងក្រោមៈ

- ប្រធានមន្ទីរពាក់ព័ន្ធក្នុងខេត្តក្នុងការចេញកិច្ចប្រមព្រាងនេះ
- មន្ត្រី និង រាល់សមាជិក( ប្តីប្រពន្ធនៃសមាជិកគ្រួសារនិមួយៗ) ក្នុងគណៈកម្មការព្រៃឈើសហគមន៍ ឬសហគមន៍ សហគមន៍ព្រៃឈើ
- ប្រធានគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត

[៨] អាជ្ញាធរខេត្តដែលទទួលពាក្យស្នើសុំ

៨១។ បង្កើតកិច្ចព្រមព្រាងព្រៃឈើសហគមន៍ និងគំរោងព្រៃឈើសហគមន៍ ហើយផ្តល់នូវការទទួលស្គាល់ស្របច្បាប់ អំពីសិទ្ធិនិងកាតព្វកិច្ចរបស់សហគមន៍ទាក់ទងនិងព្រៃឈើសហគមន៍. កិច្ចព្រមព្រាងក៏បានបញ្ជាក់ដែរថា សហគមន៍ និងអាជ្ញាធរចេញកិច្ចព្រមព្រាង មិនទទួលខុសត្រូវចំពោះទំនាស់ពីការទាមទារបង្កើតព្រៃ សហគមន៍. កិច្ចព្រមព្រាងត្រូវបញ្ជាក់អោយបានច្បាស់អំពី ទីតាំងសហគមន៏និងព្រៃឈើ គោលបំណងនៃការគ្រប់គ្រង និងសមាសភាពគណៈកម្មាធិការ អោយបានលំអិតនៅក្នុងផ្នែកនៃជំហានផែនការកំរិតថ្នាក់សហគមន៍ ដូចខាងក្រោម

82. អាចនឹងមានការចំណាយបន្តិចបន្តួច សំរាប់ដំណើរការ ក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រាង.

83. ការចេញលិខិតទទួលស្គាល់ត្រូវទទួលខុសត្រូវលើការផ្តល់ពត៌មានទៅអាជ្ញាខេត្តផ្សេងៗទៀត ដោយមានរួមទាំង គណៈកម្មាធិការប្រតិបត្តិសហគមន៏ព្រៃឈើ គណៈកម្មាធិការអភិវឌ្ឍន៏ជនបទខេត្ត មន្ទីរនគររូបនីយកម្មនិង សំណង់ខេត្ត និងស្ថាប័នជំនាញពាក់ព័ន្ធថ្នាក់ជាតិ ទាក់ទងទៅនឹងការចេញកិច្ចព្រមព្រាង.

84. កិច្ចព្រមព្រាងគម្បីថែរក្សាអោយបានល្អ នៅកន្លែងដែលមានសុវត្ថិភាព ដោយតំណាងសហគមន៍ ដែលស្នើ សុំ និងស្ថាប័នជំនាញចេញកិច្ចព្រមព្រាង. ច្បាប់ចម្លងគួររក្សាទុកដោយអាជ្ញាធរស្រុក. ស្ថាប័នជំនាញខេត្តដែលចេញ កិច្ចព្រមព្រាង ត្រូវផ្ញើមួយច្បាប់ទៅស្ថាប័នជំនាញថ្នាក់ជាតិ.

85. ថេរៈវេលានៃកិច្ចព្រមព្រាងព្រៃសហគមន៏ត្រូវបញ្ជាក់អោយច្បាស់ក្នុងឯកសារ ដែលសមរម្យគឺ៣០ឆ្នាំ. កិច្ចព្រមព្រាងនេះ គួរតែរៀបចំជាថ្មីដោយស្វ័យប្រវត្តិនៅពេលចប់អាណត្តិ. (កិច្ចព្រមព្រាងនឹងត្រូវបញ្ជាក់ពី ប្រសិទ្ធិភាព ដល់ទីបញ្ចប់).

86. កិច្ចព្រមព្រាងគួរតែកែប្រែ ក្នុងពេលដែលមានការផ្លាស់ប្តូរក្នុងសហគមន៍ ឬកែប្រែផែនការគ្រប់គ្រងព្រៃ ឈើសហគមន៍ និងគណៈកម្មាធិកាព្រៃឈើសហគមន៍ ឬសមាជិកសមាគមព្រៃឈើសហគមន៍ និងលក្ខន្តិកៈ .

**៦.៣ សហគមន៍ព្រៃឈើក្នុងតំបន់ព្រៃសម្បទាន**

ទិដ្ឋភាពទូទៅ

81. ព្រៃសម្បទានមានឥទ្ធិពលយ៉ាងខ្លាំងក្លាលើសហគមន៍មូលដ្ឋានរាប់ពាន់ក្នុងប្រទេសកម្ពុជាហើយសហគមន៍មូលដ្ឋានទាំងអស់អាចមានឥទ្ធិពលយ៉ាងខ្លាំងក្លាលើតំបន់ព្រៃសម្បទានដែរ . នាពេលបច្ចុប្បន្នប្រព័ន្ធព្រៃសម្បទាន ទទួលបានបរាជ័យទាក់ទងនិងសិទ្ធិនិងតម្រូវការរបស់ប្រជាជន តាមមូលដ្ឋានដើម្បីកំណត់ ពីទំនាក់ទំនង និងកាតព្វកិច្ចរបស់ម្ចាស់ព្រៃសម្បទាន ស្ថាប័នរដ្ឋាភិបាល សហគមន៍មូលដ្ឋាននិងអ្នកដែលពាក់ព័ន្ធព្រៃឈើ ហើយ ដើម្បីដោះស្រាយទំនាស់ដោយសមភាព . ការកំណត់និងលើកឡើងនូវសិទ្ធិនិង តម្រូវការរបស់ប្រជាជនតាម តំបន់ ដែលពាក់ពន្ធ័និងតំបន់ព្រៃសម្បទានគឺចាំបាច់ត្រូវឆ្លើយតបទៅនិងគោលបំណងរួមគ្នា របស់សហគមន៍មូលដ្ឋាន និង ម្ចាស់ព្រៃសម្បទាននិងរបៀបដែលសហគមន៍ព្រៃឈើដើរតួយ៉ាងសំខាន់និងអនុវត្តការគ្រប់គ្រង តំបន់ព្រៃសម្បទាន ដើម្បីទទួលបានជោគជ័យក្នុងការគ្រប់គ្រង ព្រៃឈើអោយមាននិរន្តរភាព.

82. តាមរយះការពិភាក្សាសាកល្បងលើសហគមន៍ព្រៃឈើដែលពាក់ព័ន្ធនិងតំបន់ព្រៃសម្បទានដែលធ្វើឡើងសំរាប់ការរៀបចំគោលការណ៍ទាំងនេះឡើងអ្នកតំណាងម្ចាស់ព្រៃសម្បទាននិងរដ្ឋាភិបាលបានព្រមព្រៀងគ្នាថាសហគមន៍គឺត្រូវទទួលបានផលប្រយោជន៍ពីតំបន់ព្រៃឈើសម្បទាន ហើយសហគមន៍គួរតែត្រូវបានអនុញ្ញាត្តិអោយចូល ទៅក្នុង តំបន់ ព្រៃសម្បទាន ដើម្បីប្រមូលអនុផលព្រៃឈើ . លើសពីនេះទៀតអ្នកចូលរួមបានព្រមព្រៀងគ្នាថា បណ្តាសហគមន៍មានសិទ្ធិទទួលបាននូវផលិតផលឈើហ៊ុបពីតំបន់ព្រៃដែលពួកគេធ្លាប់ប្រើប្រាស់ជាលក្ខណះប្រពៃណីនៅក្នុងតំបន់ព្រៃសម្បទានដោយផែកលើការពិភាក្សា និងយល់ព្រមរវាងម្ចាស់ព្រៃសម្បទាន តំណាងសហគមន៍មូលដ្ឋាននិងរដ្ឋាភិបាល . អ្នកចូលរួមក៏បានអោយយោបល់ផល ដែរថាផលប្រយោជន៏ដែលទទួលបានដោយ ប្រយោលពីការគ្រប់គ្រង ព្រៃ សម្បទាន. ពន្ធដែលបង់ទៅអោយរដ្ឋាភិបាល គួរតែ ប្រគល់ដោយផ្ទាល់ទៅដល់សកម្មភាព អភិវឌ្ឍន៏សហគមន៏ ដើម្បីផ្តល់ជាប្រយោជន៏ដល់សហគមន៏ដែលរស់នៅក្នុង ឬជាប់និង តំបន់ព្រៃសម្បទាន .

83. មានការគ្រោងទុកជាមុនថាផែនការដែលមានការចូលរួមនិងដំណើរការពិគ្រោះយោបល់ ដែលមានដូចខាងក្រោម នឹងអនុវត្តន៏ដោយក្រុមបណ្តុះបណ្តាល ដែលមានការចូលរួមចំណែកពីម្ចាស់ព្រៃសម្បទាន . ដំណើរការការងារនេះគឺជាមធ្យោបាយយ៉ាងមានប្រសិទ្ធិភាពសំរាប់ម្ចាស់ព្រៃសម្បទាន ដើម្បីធានាអោយ បាន ថារាល់ តម្រូវការរបស់សហគមន៏មូលដ្ឋានពឹងពាក់លើព្រៃឈើត្រូវបានគេឆ្លើយតបនិងថែមទាំងបាន បំពេញ នូវចំណុច សំខាន់ៗក្នុងការធ្វើអោយការគ្រប់គ្រងតំបន់ព្រៃសម្បទានមាននិរន្តរភាព .

**<u>ជំហានក្នុងការធ្វើផែនការសហគមន៏ព្រៃឈើក្នុងតំបន់ព្រៃសម្បទាន</u>**

៨១។ ដោយអនុវត្តតាមនិតិវិធីដូចគ្នានិងជំពូក " ជំហានក្នុងការធ្វើផែនការក្នុងកំរិតមូលដ្ឋាន " សេចក្តីពិស្តារនៃ ការបង្កើតសហគមន៏ព្រៃឈើក្នុងតំបន់ព្រៃសម្បទានមានដូចខាងក្រោម ប៉ុន្តែមានបញ្ចូលចំណុចបន្ថែមខ្លះ ដើម្បី

- លើកឡើងនូវសិទ្ធិនិងកាតព្វកិច្ចរបស់សហគមន៍មូលដ្ឋាននិងសិទ្ធិនិងកាតព្វកិច្ចរបស់ម្ចាស់ព្រៃសម្បទាន .
- ប៉ាន់ស្មាននិងលើកឡើងនូវតម្រូវការរបស់សហគមន៏មូលដ្ឋានដែលពាក់ពន្ធ័និងដីព្រៃដែលប្រគល់អោយ ព្រៃសម្បទាន គ្រប់គ្រង .

- បង្កើតគណកម្មការពិគ្រោះយោបល់ ដើម្បីសំរបសំរួលដល់ការទំនាក់ទំនងនិងដោះស្រាយបញ្ហាដែលពាក់ពន្ធ័ .
- បង្កើតឡើងនិងទទួលស្គាល់ព្រំដែនសំរាប់ការគ្រប់គ្រងរបស់សហគមន៏លើតំបន់ព្រៃដែលប្រគល់អោយព្រៃ សម្បទានគ្រប់ គ្រង .
- ជួយក្នុងដំណើរការត្រួតពិនិត្យនិងវាយតំលៃដែលធ្វើឡើងដោយរដ្ឋាភិបាល ដើម្បីធានាអោយបាន ថា តម្រូវការរបស់សហគមន៏មូលដ្ឋានត្រូវបានគេលើកឡើងនៅក្នុងការធ្វើផែនការគ្រប់គ្រង និងអនុវត្តផែនការ នេះ .

81. ដំណើរការពិស្តារខាងក្រោមគឺដើម្បីបង្កើតតំបន់ប្រើប្រាស់សំរាប់សហគមន៏ព្រៃឈើ នៅក្នុងតំបន់ព្រៃស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រៃសម្បទាន . ក្រៅពីការបង្កើតព្រំដែនព្រៃសំរាប់សហគមន៏ព្រៃឈើ សហគមន៏ មូលដ្ឋានដែលរស់នៅក្នុងឬនៅក្បែរតំបន់ព្រៃសម្បទាន សហគមន៏មានសិទ្ធិប្រមូល និងប្រើប្រាស់ផលិតផល អនុផល ព្រៃឈើពីតំបន់ព្រៃសម្បទាន .

*ការរៀបចំ*

- បង្កើតក្រុមសំរបសំរួល កំណត់អោយបានច្បាស់ពីកិច្ចព្រមព្រៀងក្នុងការងារ តួនាទី ការទទួលខុសត្រូវ គាំទ្រក្នុងចំណោមស្ថាប័នចូលរួម/អង្គការដែលចូលរួម.
- ហ្វឹកហ្វឺនដល់ក្រុមសំរបសំរួល .
- ទំនាក់ទំនងនិងធ្វើកាលវិភាគសំរាប់ការចុះទស្សកិច្ចលើកដំបូងក្នុងសហគមន៏និងម្ចាស់ ព្រៃសម្បទានគោលដៅ .
- ប្រមូលនិងត្រួតពិនិត្យមើលឡើងវិញលើពតិមានដែលទទួលបានអំពីភូមិនិងតំបន់ព្រៃ ផែនការ ផែនទី ផែនទីតំបន់ព្រៃសម្បទាននិងពតិមានសំរាប់ធ្វើការទំនាក់ទំនង .ល.

*ការងារដំបូងនៅក្នុងភូមិ*

- ជួបជាមួយសហគមន៏មូលដ្ឋាននិងម្ចាស់ព្រៃសម្បទាន ដើម្បីកំណត់អោយបានច្បាស់នូវគោលបំណង និង តួនាទី ក្នុងចំណោមស្ថាប័នក្រុមហ៊ុនព្រៃសម្បទាននិងប្រជាជនមូលដ្ឋាន ដើម្បីប៉ាន់ស្មានផល ប្រយោជន៏ ទូទៅក្នុងការបង្កើតសហគមន៏ព្រៃឈើនៅក្នុងតំបន់ព្រៃសម្បទាន .
- បង្កើតនិងផ្សព្វផ្សាយពតិមានរួមទាំងសម្ភារះអប់រំ ដល់គ្រប់សហគមន៏ទាំងអស់ ដែលទទួលឥទ្ធិពល របស់តំបន់ព្រៃ សម្បទានគ្រប់ក្រុមហ៊ុនព្រៃសម្បទានទាំងអស់និងរដ្ឋអំណាចមូលដ្ឋានដែលពាក់ពន្ធ័ ស្តីអំពី:

  ១-សិទ្ធិនិងកាតព្វកិច្ចរបស់សហគមន៏មូលដ្ឋាន ឬក្រុមហ៊ុនតំបន់ព្រៃសម្បទាននិងរដ្ឋាភិបាលក្នុងដំណើរការ បែងចែកធ្វើផែនការនិងដំណើរការគ្រប់គ្រងតំបន់ព្រៃសម្បទាន .

  ២-គោលនយោបាលនិងវិសាលភាពរបស់សហគមន៏ព្រៃឈើ ដោយរួមទាំងការអភិវឌ្ឍន៏សហគមន៏ ព្រៃឈើក្នុងរង្វង់តំបន់ព្រៃសម្បទាន .

  ៣-ការយល់ដឹងអំពីយែនឌ័រនិងសហគមន៏ព្រៃឈើ .

- ប្រើបច្ចេកទេសដូចជាសំភាសន៍ក្រៅផ្លូវការជាមួយក្រុមសហគមន៍ អ្នកភូមិ អ្នកចូលទៅក្នុងព្រៃ ដើម្បីប្រមូល និង កំណត់ពត៌មានមូលដ្ឋានអំពីសហគមន៍ធ្វើការប៉ាន់ស្មានដំបូង លើផលប្រយោជន៍ មូលដ្ឋានក្នុងការគ្រប់គ្រងនិងពឹងផ្អែកលើព្រៃឈើ រួមមានការប៉ាន់ស្មានផ្អែកយែនឌ័រក្នុង ការប្រើប្រាស់ ធនធានព្រៃឈើនិងការកំណត់អោយបានច្បាស់លើ ជាដំបូងនូវអ្នកដែលពាក់ពន្ធ័ . ការងារទាំងនេះ ទាមទារការហ្វឹកហ្វឺននិងបទពិសោធន៍ និងប្រហែលជាត្រូវការ ជំនួយផ្នែកបច្ចេកទេសក្នុង ការធ្វើផែនការ និងអនុវត្តការងារទាំងនេះ .
- ធ្វើការពិភាក្សា ត្រួតពិនិត្យការងារឡើងវិញនិងវិភាគលើលទ្ធផលជាមួយសហគមន៍ ធ្វើផែនការ សំរាប់ជំហានទៅមុខ ទៀត .

*ការពិភាក្សាជាមួយសហគមន៏*

៨១។ នៅពេលដែលចុះធ្វើការតាមមូលដ្ឋានជាដំបូងបានសំរេចថាវាជាការសំខាន់ក្នុងការពិភាក្សាអំពីជំរើសជាមួយ សហគមន៏ទាំងមូល ពីព្រោះថាពេលប្រមូលពត៌មាននៅជំហានដំបូង មានសមាជិករបស់សហគមន៏ខ្លះ មិនបាន ចូលរួមពិភាក្សាឡើយ . គួរតែមានការប្រជុំធំដើម្បី :

  - ត្រួតពិនិត្យឡើងវិញលើគំនិតរបស់សហគមន៏ព្រៃឈើ គោលនយោបាយ វិសាលភាពនិង ការគ្រប់គ្រង តំបន់ព្រៃ សម្បទាន .
  - ណែនាំអំពីដំណើរការប៉ាន់ប្រមាណសហគមន៏និងធ្វើផែនការកម្មវិធី និងទំនាក់ទំនងជាមួយការគ្រប់គ្រង តំបន់ព្រៃ សម្បទាន .
  - ពិភាក្សាលើផលប្រយោជន៏សហគមន៏ ការរៀបចំលើកដំបូង ផែនការសំរាប់ជំហានទៅមុខទៀត .

*ការបង្កើតគណកម្មការតំបន់ព្រៃក្នុងភូមិ/សមាគមន៏សហគមន៏ព្រៃឈើនិងគណកម្មការទីប្រឹក្សាសហគមន៏ព្រៃឈើ*

១។ នៅពេលដែលបុគ្គលិកមូលដានរបស់សហគមន៏ព្រៃឈើនិងអ្នកភូមិយល់ដឹងអំពីព្រៃឈើ ដែនព្រៃឈើនិងការប្រើ ប្រាស់ព្រៃឈើក្នុងតំបន់
ចាំបាច់ត្រូវចាប់ផ្តើមដំណើរការបង្កើតការចរចារជាផ្លូវការនិងបន្តការចរចាររវាងសហគមន៏និងក្រុមហ៊ុនព្រៃសម្ប ទាន អំពីរយះពេលរបស់ព្រៃសម្បទាន. សំណូមពរមធ្យោបាយការងារនេះគឺការបង្កើតគណកម្មការពិគ្រោះយោបល់ សហគមន៏ព្រៃឈើ . បច្ចុប្បន្នដំណើរការនេះកំពុងមានការគាំទ្រនៅក្នុងច្បាប់របស់ប្រទេសកម្ពុជា នៅក្នុងអនុក្រិត្យ ស្តីអំពីការគ្រប់គ្រងតំបន់ព្រៃសម្បទាន. ដើម្បីបង្កើតគណកម្មការនេះត្រូវដំណើរការតាមជំហានដូចខាងក្រោមនេះ:

- ដំណើរការពិភាក្សានិងចរចារជាដំបូងរវាងសហគមន៏និងម្ចាស់ក្រុមហ៊ុនព្រៃសម្បទាន ដែលពាក់ពន្ធ័ជាមួយការបង្កើត សហគមន៏ព្រៃឈើនៅក្នុងតំបន់ព្រៃសម្បទាន .
- ត្រួតពិនិត្យឡើងវិញលើលទ្ធផលជាមួយសហគមន៏និងម្ចាស់ព្រៃសម្បទាន .
- ពិភាក្សាអំពីមុខងាររបស់គណកម្មការព្រៃឈើភូមិ/សមាគមន៏ព្រៃឈើ និងគណកម្មការពិគ្រោះយោបល់សហគមន៏ ព្រៃឈើ .

- ពិភាក្សាអំពីសារៈសំខាន់នៃវត្តមានរបស់គ្រប់សមាជិកសហគមន៍ទាំងអស់ក្នុងជួរគណៈកម្មការ រួមទាំងនារី ចាស់ព្រឹទ្ធាចារ្យ និងប្រជាជនផ្សេងៗទៀតដែលប្រើប្រាស់ព្រៃឈើ .
- រៀបចំ គណៈកម្មការព្រៃឈើភូមិ/សមាគមន៍ព្រៃឈើ និងគណៈកម្មការពិគ្រោះយោបល់សហគមន៍ ព្រៃឈើ ដូចដែលបាន រៀបរាប់យ៉ាងពិស្តារខាងលើ .
- ធ្វើផែនការសំរាប់ជំហានទៅមុខទៀត .

*ការទទួលស្គាល់សហគមន៍ព្រៃឈើ*

១១ សហគមន៍ព្រៃឈើដែលត្រូវបានបង្កើតតាមរយៈដំណើរការពិគ្រោះយោបល់ដែលបានរៀបរាប់ដូចខាងលើ នឹងលាតសន្ធឹងទាំងមូលឬដោយផ្នែកៗ ក្នុងតំបន់ដែលប្រគល់អោយព្រៃសម្បទាន . តំបន់សហគមន៍ព្រៃឈើទាំង នេះស្ថិតក្នុងតំបន់ព្រៃ សម្បទានអាចចាត់ទុកថាជា-តំបន់មិនអាចយកទៅប្រើប្រាស់បាន-ដែលមានចែង ក្នុងអនុក្រិត្យស្តីអំពីការគ្រប់គ្រងតំបន់ព្រៃ សម្បទាន ( មាត្រាទី៦-២(ខ)) . អនុក្រិត្យកំណត់យ៉ាងច្បាស់ពីដំណើរការ អាស្រ័យលើការវាយតំលៃដោយមានការចូល រួមនិង ការធ្វើផែនទី សំរាប់ការគូរព្រាង( កំណត់ព្រំដែន) លើតំបន់ទាំងនេះ . បន្ទាប់ពីគូរព្រាង ជំហានបន្ទាប់មកទៀត សំរាប់ការកំណត់តំបន់ជាសហគមន៍ព្រៃឈើ មានដូចខាងក្រោម :

- រៀបចំពាក្យសុំសំរាប់សហគមន៍ព្រៃឈើ រួមមានទាំង
- ការពិពណ៌នាអំពីសហគមន៍
- ការប្រើប្រាស់ព្រៃឈើ/ការអាស្រ័យរបស់សហគមន៍
- គណៈកម្មការព្រៃឈើភូមិ/សមាគមន៍ព្រៃឈើ និងគណៈកម្មការពិគ្រោះយោបល់សហគមន៍ព្រៃឈើ .
- ការគូរព្រាងតំបន់ព្រៃសម្បទានដែលមិនអនុញ្ញាតិអោយប្រើប្រាស់ ដែលមានការចុះហត្ថលេខាដោយសមាជិកគណៈកម្មការ ពិគ្រោះយោបល់សហគមន៍ព្រៃឈើ.
- កំណត់( ទីតាំង/តំបន់ គោលបំណង) របស់សហគមន៍ព្រៃឈើ .
- ពិភាក្សា/មើលផ្ទៀងផ្ទាត់ឡើងវិញជាមួយសហគមន៍ .
- ដាក់ពាក្យសុំទៅអាជ្ញាធរពាក់ពន្ធ័ .
- នៅពេលធ្វើគំរោងជាបណ្តោះអាសន្នអំពីសហគមន៍ព្រៃឈើ ធ្វើផែនការសំរាប់ជំហានទៅមុខទៀត .

*ធ្វើផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ:*

- ត្រួតពិនិត្យឡើងវិញលើផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ ជាបន្តបន្ទាប់ដើម្បីធានាថាគ្រប់អ្នកដែលពាក់ពន្ធ័ទាំងអស់ ត្រូវបានកំណត់ឡើងយ៉ាងច្បាស់និងមានការពាក់ពន្ធ័ក្នុងការគ្រប់គ្រងដោយមានភាពសមរម្យបំផុត .
- ត្រួតពិនិត្យឡើងវិញលើបញ្ហានិងពង្រឹងគោលបំណងរបស់សហគមន៍ព្រៃឈើ .

- ប្រមូលពតិមានមួយចំនួនឬការរៀបរាប់អំពីធនធានព្រៃឈើ រួមទាំងសារពើភណ្ឌដែលក្រុមហ៊ុនព្រៃសម្បទាន ដំណើរការ . ក្នុងករណីខ្លះ វាអាចសមស្របក្នុងការដំណើរការបញ្ជីសារពើភណ្ឌ ដោយទុកចិត្តថាលទ្ធផលដែលទទួលបាន អាចបកស្រាយអោយអ្នកភូមិងាយស្រួលយល់ .
- វិភាគជំរើសការគ្រប់គ្រងព្រៃឈើ រួមមានទាំងតម្រូវការដែលសង្ឃឹមទុកសំរាប់ការគ្រប់គ្រងលទ្ធផលធនធានដែលសង្ឃឹមទុកនិងការចែករំលែកការចំណាយនិងផលប្រយោជន៏ .
- ពិភាក្សានិងវិភាគលើជំរើសនៃការគ្រប់គ្រងព្រៃឈើសំរាប់សហគមន៏ ជ្រើសរើសមធ្យោបាយគ្រប់គ្រងដែលចូលចិត្ត .
- តាមរយះការពិភាក្សា បង្កើតលក្ខន្តិកៈសមស្របដែលត្រូវតាមដានអង្កេតមើលដោយអ្នកដែលពាក់ពន្ធ័ទាំងអស់ .
- រៀបចំផែនការគ្រប់គ្រងសហគមន៏ព្រៃឈើ រួមមានទាំងបទបញ្ញាតិផ្ទៃក្នុងនៃការប្រើប្រាស់និងគោលការណ៏បែងចែក ផលនិងគណកម្មការព្រៃឈើភូមិ/សមាគមន៏ព្រៃឈើស្របច្បាប់ .
- របាយការណ៏ផ្តល់លទ្ធផលដល់សហគមន៏ ការផ្ទៀងផ្ទាត់អោយបានច្បាស់ .
- ដាក់ជូនផែនការគ្រប់គ្រងសហគមន៏ព្រៃឈើនិង គណកម្មការព្រៃឈើភូមិ/សមាគមន៏ព្រៃឈើស្របច្បាប់ទៅអាជ្ញាធ័រ ដែលពាក់ពន្ធ័ .

<u>ការចែកចាយផល</u>

1. ស្តីអំពីការចែកចាយផលពីតំបន់ព្រៃសម្បទាន អ្នកចូលរួមសិក្ខាសាលាព្រមព្រៀងថា សហគមន៏ មូលដ្ឋានមានសិទ្ធិចូលទៅប្រមូលអនុផលព្រៃឈើពីតំបន់ព្រៃសម្បទាន ដោយមិនចាំបាច់ សុំការអនុញ្ញាតិ ពីម្ចាស់ព្រៃសម្បទានជាមុនឡើយ . សិក្ខសាលាក៏បានយល់ស្របថាសហគមន៏មូលដ្ឋានមានសិទ្ធិទទួលបានផល មួយចំណែកពីតំបន់ព្រៃសម្បទាន ដែលគួរតែផ្តល់ដោយអោយនិងសំរាប់ទ្រទ្រង់ជីវភាព ប្រកបដោយនិរន្តរភាព និងសុខមាលភាព សិក្ខាសាលាមិនទាន់បានព្រមព្រៀងគ្នាលើចំនួនសមរម្យក្នុងការបែងចែកផល ប្រយោជន៏នៅ ឡើយ . ហេតុដូច្នេះហើយ សិក្ខាសាលាបានអោយយោបល់អោយមានការបង្កើតជាគណកម្មការថ្នាក់ជាតិ ដើម្បីវិភាគនិងអោយយោបល់ស្តីអំពីវិធីបែងចែកផលប្រយោជន៏អោយបានសមស្រប ចំពោះផលដែលទទួលបានពីតំបន់ព្រៃសម្បទាន . ជាពិសេស ត្រូវពិភាក្សាអំពីជំរើសនៃការសងការខូតខាត (ដល់សហគមន៏និងម្ចាស់ព្រៃសម្បទាន) និងចាំបាច់ត្រូវបង្កើតក៏រិតបទដ្ឋាន លក្ខណៈវិនិច្ឆ័យ និងម៉ែត្រសំរាប់ វាស់ជាមួយមូលដ្ឋានគ្រឹះដើម្បីសំរេចចិត្ត និងវាយតំលៃតម្រូវការរបស់សហគមន៏ .

## ៦-៤ សហគមន៏ព្រៃឈើក្នុងតំបន់ការពារ

ទិដ្ឋភាពទូទៅ

1. រាជរដ្ឋាភិបាលបានចាប់ផ្តើមគាំទ្រចំពោះការចូលរួមរបស់សហគមន៏ក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព នៅក្នុងព្រំដែនដាច់ដោយឡែករបស់តំបន់ព្រៃការពារ . ក្រសួងបរិស្ថានបានអះអាងថាសហគមន៏មូលដ្ឋានមានការយល់ដឹងអំពីការគ្រប់គ្រងធនធាន ហើយពង្រាង" អនុក្រិត្យស្តីអំពីការគ្រប់គ្រងតំបន់ព្រៃការពារ" អាចអោយសហគមន៏មូលដ្ឋានប្រើប្រាស់ធនធានធម្មជាតិនៅក្នុងតំបន់ព្រៃការពារ បើសិនជាការប្រើប្រាស់មិនមានផលប៉ះពាល់ជាអវិជ្ជមានដល់គ្រឹះធនធានធម្មជាតិរបស់តំបន់ព្រៃការពារ . ពង្រាងអនុក្រិត្យក៏អនុញ្ញាតិចំពោះសកម្មភាព

អភិវឌ្ឍន៍សហគមន៍ នៅតំបន់ទ្រនាប់នៃតំបន់ព្រៃការពារ និងបានចែងថាគោលបំណងនៃការបង្កើតតំបន់ទ្រនាប់ ដោយឡែកគឺ ដើម្បីផ្តល់ដល់តម្រូវការចិញ្ចឹមជីវិតជាប្រពៃណីលើធនធានធម្មជាតិជាមូលដ្ឋានតាមតម្រូវការ . ដូចនេះ វាជាការសំខាន់ក្នុង ការអោយសហគមន៍មូលដ្ឋានចូលរួមក្នុងការកំណត់អោយបានច្បាស់លាស់អំពីដែនព្រៃក្នុងតំបន់ព្រៃការពារ ផ្អែកលើ គោលការណ៍ប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍ មិនមែនអាស្រ័យលើគោលការណ៍របស់ លក្ខណៈ វិនិច្ឆ័យដែលបានបង្កើត ឡើងនិងមិនមែនយកពីតំបន់ក្រៅឡើយ .

2. យោងលើពង្រាងអនុក្រិត្យស្តីអំពីការគ្រប់គ្រងតំបន់ព្រៃការពារ សកម្មភាពនានាដូចជា ការប្រមូលផល ការកំណត់ ព្រំដែន ការសាងសង់ សម្ភារៈនិងការប្រើប្រាស់សម្ភារៈគឺត្រូវទទួលការអនុញ្ញាតិនៅក្នុងតំបន់ទ្រនាប់ ដោយមានការអនុញ្ញាតិពី ក្រសួងបរិស្ថាន . ជំហានពិស្តារខាងក្រោមគឺជាដំណើរការដែលក្រសួងបរិស្ថានអាចផ្តល់ការអនុញ្ញាតិដល់សហគមន៍មូលដ្ឋាន ដើម្បីចូលរួមក្នុងសកម្មភាពសហគមន៍ព្រៃឈើនៅក្នុងតំបន់ទ្រនាប់នៃតំបន់ព្រៃការពារ . ទោះបីជាយ៉ាងណាក៏ដោយ អាស្រ័យលើបរិស្ថានតែមួយនៅក្នុងតំបន់ព្រៃការពារនីមួយៗ សកម្មភាពខ្លះមិនត្រូវបានអនុញ្ញាតិឡើយ ទោះបីជានៅក្នុងតំបន់ ទ្រនាប់ក៏ដោយ . សកម្មភាពទាំងនេះ រួមមានទាំងការប្រើប្រាស់ដើមឈើឬប្រភេទសត្វដែលមានកំរ ថ្នាំបំពុលនិងថ្នាំសំលាប់ សត្វល្អិត .
3. សហគមន៍ព្រៃឈើក្នុងតំបន់ព្រៃការពារត្រូវអនុវត្តតាមជំហានដែលគ្រោងឡើងនៅក្នុងផ្នែក" ជំហានក្នុងការធ្វើ ផែនការកំរិតមូលដ្ឋាន " . ឯកសារយោងត្រូវបានគេធ្វើឡើងស្តីអំពីសិទ្ធិនិងការទទួលខុសត្រូវរបស់អ្នកដែលពាក់ពន្ធ័សំខាន់ៗ ដែលមាននៅក្នុងឧបសម្ពន្ធ័ទី១ .
4. ស្តីអំពីការចែកចាយផលពីសកម្មភាពសហគមន៍ព្រៃឈើនៅក្នុងតំបន់ព្រៃការពារ សិក្ខាសាលាបានអោយយោបល់ ថាបញ្ហានេះទាក់ទងនិងការព្រមព្រៀងនៅក្នុងសហគមន៍នីមួយៗ មិនមែនដើម្បីតែបង្កើតវិធីកំរិតបទដ្ឋានឬការព្រមព្រៀង ជាមួយនិងគោលការណ៍ឡើយ .
5. ទាក់ទងនិងដំណោះស្រាយបញ្ហាទំនាស់ក្នុងតំបន់ព្រៃការពារ សិក្ខាសាលាបានអោយយោបល់ថាការបង្កើត គណកម្មការថ្នាក់មូលដ្ឋាន ថ្នាក់ខេត្តនិងថ្នាក់ជាតិ ដើម្បីដោះស្រាយទំនាស់ . អ្នកចូលរួមយល់ព្រមថា គណកម្មការនេះគួរតែ សំរបសំរួលដោះស្រាយទំនាស់រវាងស្ថាប័ននិងសហគមន៍ រវាងសហគមន៍និងសហគមន៍ ប៉ុន្តែការពិភាក្សាបន្ថែមតម្រូវអោយ បង្កើតដំណើរការយន្តការ ដើម្បីធ្វើជាអាជ្ញាកណ្តាលអំពាវនាវនិងពិភាក្សាបន្ថែមទាក់ទងនិងដំណើរការបង្កើតនិងរំសាយ គណកម្មការនេះ .

៧-ការដោះស្រាយទំនាស់

6. ទំនាស់កើតមានគ្រប់បរិបទទាំងអស់ ចំពោះសហគមន៍ព្រៃឈើ ទំនាស់អាចកើតឡើងក្នុងពេលផែនការ និងពេល អនុវត្តន៍. ក្នុងផ្នែកនេះបានលើកឡើងនូវគោលការណ៍ចំបងៗ និងយន្តការសំរាប់ពិចារណា ពេលទំនាស់កើតឡើង.

៧។ ទំនាស់អាចកើតមានឡើងក្នុងស្ថានភាពខុសៗគ្នា:

- ទំនាស់កើតឡើងក្នុងភូមិតែមួយ
- ទំនាស់កើតឡើងរវាងភូមិនិងភូមិ
- ទំនាស់រវាងសហគមន៍ស្ថាប័ន

- ទំនាស់រវាងស្ថាប័ន និងស្ថាប័ន

1. ទំនាស់អាចស្ថិតក្នុងរយៈពេលវែង វាអាចកើតឡើងកំឡុងពេលធ្វើផែនការ ហើយជាញឹកញាប់វាមាន ការលំបាក ពេលការទាមទារជាន់គ្នាលើកន្លែងតែមួយ ហើយអាចកើតឡើងនៅពេលកិច្ចព្រមព្រាង សហគមន៍ ព្រៃឈើបាននឹងកំពុងអនុវត្តន៍. វាមានលក្ខណៈខុសប្លែកគ្នាពីការទាមទារជាន់គ្នាលើកន្លែងតែមួយ កិច្ចព្រមព្រាងដំបូងមិនបានជួប ប្រទះ ហើយមានយន្តការដើម្បីសំរួលអោយឈានទៅការព្រមព្រាង ឬម្យ៉ាងទៀតស្ថានភាពដោះស្រាយទំនាស់ ឡើងវិញត្រូវបានគេរកឃើញ.
2. ទំនាស់គួរដោះស្រាយជាដំបូងទៅតាមកំរិតដែលបានជួបប្រទះ. ប្រសិនបើការដោះស្រាយទំនាស់ទទួលបរាជ័យ នៅកំរិតនោះ ទំនាស់គួរតែបញ្ជូនទៅកំរិតខ្ពស់ជាង គិតទាំងគណៈកម្មការចំរុះដោះស្រាយទំនាស់ដីធ្លីនៅតាមខេត្ត. ទំនាស់ដែលមិនអាចដោះស្រាយបានតាមរយៈការពិគ្រោះពិភាក្សានិងត្រូវបញ្ជូនទៅតុលាការ.

**តារាង ៧.១ ការដោះស្រាយទំនាស់**

| **ភាគីក្នុងទំនាស់** | **kMritTI1** | **kMritTI2** | **kMritTI3** | **kMritTI4** |
|---|---|---|---|---|
| kÐúgPUmiEtmYy | KNŸkmÌaFikar éRB eQIPUmi | GaCJaFrXMu nigRsuk | sßabÓnman smtßkicø tamextÊ | |
| rvagPUminananigsmaKm<br><br>shKmn_éRBeQI | smaKm<br><br>shKmn_éRBeQI | GaCJaFrXMu nigRsuk | sßabÓnmansmtßkicø<br><br>tamextÊ | KNŸkmÌkarGPiv Dḍn_CnbTextÊ |
| rvagPUminana b:EnÊminEmn CamYysmaKm<br><br>shKmn_éRBeQI | KNŸkmÌkarBie RKaH<br><br>eyabl;shKmn_é RBeQI | sßabÓnmansmtßkicø<br><br>tamextÊ | KNŸkmÌkarGPiv Dḍn_CnbTextÊ | GaCJFrextÊ |
| rvagPUminigRkumh‘un<br><br>éRBsm,Tan | GaCJaFrXMu nigRsuk | sßabÓnmansmtßkicø<br><br>tamextÊ | KNŸkmÌkarGPiv Dḍn_CnbTextÊ | |
| rvagPUminananigGaCJaFrextÊ | KNŸkmÌkarRbt ÊibtishKmn_ éRBeQIextÊ | KNŸkmÌkarGPiv Dḍn_CnbTextÊ | GaCJFrextÊ | |

កំណត់សំគាល់: អាជ្ញាធរថ្នាក់ជាតិត្រូវចូលរួមតាមរយៈអាជ្ញធរខេត្ត

1. ជ្ញាធរខេត្តគួរមានសម្ព័ន្ធភាពជាមួយតំណាងអាជ្ញាធរថ្នាក់ជាតិ តាមលក្ខណៈសមស្របនិង តំរូវតាមច្បាប់និង វចនាសម្ព័ន្ធនិងទំរង់ការរបស់រាជរដ្ឋាភិបាលកម្ពុជា។

២។ ទំនាស់ដែលកើតមានឡើងពីការទាមទារ លើដីព្រៃឈើគួរតែការសំរេចចិត្តផ្អែកលើអាទិភាពដូចខាងក្រោមៈ

- សហគមន៏ដែលស្ថិតនៅជិតតំបន់ព្រៃឈើ មានអាទិភាព
- សហគមន៏ដែលមានប្រវត្តិយូរ ឬ ពឹងពាក់លើព្រៃឈើយ៉ាងខ្លាំង មានអាទិភាព
- សហគមន៏ពុំមានមុខរបរផ្សេងៗ មានអាទិភាព
- តំរូវការរបស់សហគមន៏មានកំរិតខ្ពស់ជាងតំរូវការខាងពាណិជ្ជកម្ម

# ឧបសម្ព័ន្ធ

## សិទ្ធិនិងការទទួលខុសត្រូវ

**សេចក្តីផ្តើម**

1. នៅកម្ពុជា ប្រជាជនជាច្រើនក្រុមប្រើប្រាស់ធនធានដូចគ្នា (ព្រៃឈើ ជលផល ដីកសិកម្ម) ក្នុងពេលតែមួយ. ជាក់ស្តែង ព្រៃឈើដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុនព្រៃសម្បទាន និងព្រៃឈើក្នុងតំបន់ ការពារ. ពេលខ្លះក្រុមមនុស្សផ្សេងគ្នា ប្រើប្រាស់ធនធានក្នុងគោលបំណងផ្សេងគ្នា ដូច្នេះការចែករំលែក ធនធានគួរតែអាចធ្វើទៅបាន. ប៉ុន្តែ បើធនធានណាមួយកំពុងត្រូវបានចែករំលែក នោះរាល់ក្រុមដែលបាន ចូលរួម តំរូវអោយទទួលស្គាល់ថាក្រុមដ៏ទៃឬក្រុមខ្លះ មានសិទ្ធិស្របច្បាប់ក្នុងការប្រើប្រាស់ធនធានដូចគ្នា ហើយក្រុមនិមួយៗត្រូវទទួលខុសត្រូវ ក្នុងការគោរពសិទ្ធិនេះ.
2. សហគមន៏ព្រៃឈើស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុនព្រៃសម្បទាន ឬតំបន់ការពារ ចាប់ផ្តើមធ្វើកិច្ច ព្រមព្រាង រវាងអ្នកពាក់ព័ន្ធសំខាន់ៗ ដោយមានបញ្ជាក់ពីសិទ្ធិនិងការទទួលខុសត្រូវរៀងៗខ្លួន. វាជា ការចាំបាច់ណាស់ដែលអ្នកពាក់ព័ន្ធទាំងអស់បានចូលរួម ក្នុងការកំណត់នូវសិទ្ធិនិងការទទួលខុសត្រូវ ដូច្នេះ នេះការព្រមព្រាង. សិក្ខាសាលាចំនួន៣ ដែលបានរៀបចំឡើងដោយអង្គការខុនសឺននិងគំរោងគ្រប់គ្រង ព្រៃឈើក្របដោយនិរន្តភាពក្នុងឆ្នាំ១៩៩៩ ជាការព្យាយាមដំបូង ដើម្បីកំណត់បញ្ហានេះ. ឧបសម្ព័ន្ធនេះ បង្ហាញអំពីសិទ្ធិនិងការទទួលខុស ដែលបានកំណត់ដោយតំណាងពីអ្នកពាក់ព័ន្ធនានា ក្នុងព្រៃសម្បទាននិង ព្រៃឈើក្នុងតំបន់ព្រៃការពារ.
3. សិទ្ធិនិងការទទួលខុសត្រូវ(និងកាតព្វកិច្ច) បានលើកឡើងនេះត្រូវបានពិចារណា នៅក្នុងការ"ព្យាយាមដំបូង" ទាក់ទងទៅនឹងបញ្ហាសំខាន់នេះ. ទោះយ៉ាងណាក៏ដោយ សិក្ខាសាលាដែលបានរៀបចំហើយ មានតែតំណាង ខ្លះនៃអ្នកពាក់ព័ន្ធមានវត្តមានប៉ុណ្ណោះ. វាជាការសំខាន់ ដែលការងារនេះឈានទៅរកភាពរីកចំរើននា ពេលខាងមុខដើម្បីធ្វើអោយប្រាកដថាមានការឯកភាពគ្នាលើចំណុចនេះ.

## សិទ្ធិនិងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនានាក្នុងតំបន់ព្រៃសម្បទាននិងព្រៃការពារ

**សិទ្ធិរបស់សហគមន៏**

១។ សហគមន៏រស់នៅក្នុងឬក្បែរតំបន់ព្រៃសម្បទានមានសិទ្ធិដូចខាងក្រោមៈ

- ចូលរួមក្នុងការសិក្សាទាំងឡាយ ទាក់ទងទៅនឹងការបង្កើតនិងកំណត់ដែនព្រៃសម្បទាន។ សិទ្ធិនេះមានរួមមាន ការសិក្សាកំណត់ព្រំប្រទល់ព្រៃសម្បទាន និងការសិក្សាក្នុងការបង្កើតសហគមន៏ប្រើប្រាស់ធនធានធម្មជាតិក្នុង តំបន់ព្រៃការពារ ប៉ុន្តែមិនបានដាក់ក៏រិតកំណត់ថាត្រូវតែធ្វើនោះទេ។
- សិទ្ធិរបស់សហគមន៏ត្រូវបានទទួលស្គាល់ក្នុងកិច្ចព្រមព្រាងព្រៃសម្បទាន និងគោរពតាមពាក្យសុំនៃកិច្ចព្រមព្រាង នោះ។

- ទទួលបាននូវពេលវេលាគ្រប់គ្រាន់ ដើម្បីធ្វើការពិភាក្សាក្នុងចំណោមសមាជិកសហគមន៍ មុនពេលធ្វើកិច្ចព្រមព្រាងរវាងម្ចាស់ព្រៃសម្បទាននិងរាជរដ្ឋាភិបាល ។
- ទទួលពត៌មានគ្រប់គ្រាន់ ប៉ុន្តែមិនកំណត់ទេ រួមមានពត៌មានស្តីពីសិទ្ធិនិងកាតព្វកិច្ចរបស់សហគមន៍ ម្ចាស់ព្រៃ សម្បទាននិងរដ្ឋ។ ពត៌មានស្តីពីសក្តានុពលភាពព្រៃសម្បទាននានា និងពត៌មានស្តីពីកិច្ចសន្យាដែលបានចុះ ហត្ថលេខា ដោយមានបទដ្ឋានបច្ចេកទេសនៃព្រៃសម្បទាន ទិន្នន័យធនធានធម្មជាតិ ក្របដណ្តប់ក្នុងព្រៃ សម្បទាន និងផែនការគ្រប់គ្រងព្រៃសម្បទាន ។
- ទទួលបាននូវការបណ្តុះបណ្តាលតាមការស្នើសុំ សំរាប់សមាជិកសហគមន៍ ដើម្បីអោយយល់ ហើយចេះប្រើប្រាស់ពត៌មានដែលផ្តល់អោយដូចបានរៀបរាប់ខាងលើ ( ឧទាហរណ៍ បណ្តុះបណ្តាលអោយចេះប្រើប្រាស់ផែនទី) ។
- ចូលរួមធ្វើផែនការគ្រប់គ្រង និងអនុវត្តន៍ផែនការគ្រប់គ្រងព្រៃឈើ ហើយផែនការនោះទាក់ទងទៅនិងសហគមន៍ដោយផ្ទាល់ឬប្រយោល ។
- ប្រាស្រ័យទាក់ទង ពិភាក្សានិងសំរបសំរួលជាមួយម្ចាស់ព្រៃសម្បទាន ។
- ធ្វើផែនការគ្រប់គ្រងព្រៃសំរាប់សហគមន៍មូលដ្ឋានគ្រប់គ្រងខ្លួនឯង នៅលើដីព្រៃក្នុងតំបន់ព្រៃសម្បទាន ដែល មានការទទួលស្គាល់ដោយកិច្ចព្រមព្រាងរវាងសហគមន៍និងម្ចាស់ព្រៃសម្បទាន ។
- ប្រឆាំងនឹងការរំលោភបំពានដោយខុសច្បាប់លើដីព្រៃ ក្នុងព្រៃសម្បទាន ដែលមានការទទួលស្គាល់ជាតំបន់ ព្រៃឈើសហគមន៍តាមកិច្ចព្រមព្រាងរវាងសហគមន៍និងម្ចាស់ព្រៃសម្បទាន ។
- កំណត់តំបន់ព្រៃឈើប្រើប្រាស់និងសំរុះសំរួលតំបន់ទាំងនោះ ។
- រកប្រាក់ចំណូល ពីការគ្រប់គ្រងព្រៃលើដីព្រៃក្នុងព្រៃសម្បទាន តាមតំបន់ព្រៃសហគមន៍ ដែលមានការព្រមព្រាងគ្នារវាងសហគមន៍និងម្ចាស់ព្រៃសម្បទាន ។
- ថែរក្សាវប្បធម៌និងទំនៀមទំលាប់របស់ខ្លួន ។
- ត្រួតពិនិត្យ វាយតំលៃ ហើយរាយការណ៍ពីសកម្មភាពក្នុងតំបន់ព្រៃសម្បទាន ( ឧទាហរណ៍ ការគ្រប់គ្រង ព្រៃសម្បទាន បញ្ហារបស់សហគមន៍ ឬ សហគមន៍ព្រៃឈើ) ។
- តំបន់ព្រៃសម្បទានប្រជាជនមានសិទ្ធិមានចំណែកទទួលផលពីធនធានព្រៃឈើរបស់រដ្ឋ សំរាប់ទ្រទ្រង់សកម្មភាពអភិវឌ្ឍន៍សហគមន៍ ដែលផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនភាគច្រើនក្នុងសហគមន៍ ។
- ទទួលបានចំណូលពីពន្ធ ដែលបង់ដោយម្ចាស់ព្រៃសម្បទានអោយរដ្ឋាភិបាល ទុកមួយផ្នែកសំរាប់ទ្រទ្រង់ជីវិតប្រចាំថ្ងៃនិងគំរោងសុខមាលភាពសហគមន៍មូលដ្ឋាន ។
- គោរពនិងអនុវត្តតាមកិច្ចសន្យាព្រៃសម្បទានដែលក្រុមហ៊ុនធ្វើឡើងជាមួយរាជរដ្ឋាភិបាល
- ជ្រើសរើសតំណាងរបស់ខ្លួនផ្ទាល់ ដើម្បីសំរុះសំរួលលើផលប្រយោជន៍របស់ពួកគេ
- មានសិទ្ធិសេរីភាពរួចផុតពីការគំរាមកំហែងទាំងឡាយ
- ជួយដល់ក្រុមហ៊ុនព្រៃសម្បទានក្នុងការការពារតំបន់គ្រប់គ្រងរួមគ្នា ពីអំពើល្មើសច្បាប់ទាំងអស់
- លើកបង្ហាញពីក្រុមហ៊ុនព្រៃសម្បទាន និងការគ្រប់គ្រងព្រៃសម្បទានអំពីការរំលោភលើសិទ្ធិរបស់សហគមន៍ ឬកិច្ចព្រមព្រាងដែលបានបង្កើតឡើង ។

**កាតព្វកិច្ចរបស់សហគមន៍**

១។ សហគមន៍ព្រៃឈើដែលរស់នៅក្នុងឬក្បែរតំបន់ព្រៃសម្បទាន មានកាតព្វកិច្ចដូចខាងក្រោម:

- ចូលរួមនិងសហការក្នុងការកំណត់ព្រំប្រទល់បង្កើតតំបន់ព្រមព្រាងរវាងសហគមន៍និងម្ចាស់ព្រៃសម្បទាន ដូចជាតំបន់ដែលមិនចុះសំរុងគ្នាក្នុងការប្រើប្រាស់សំរាប់អភិវឌ្ឍន៏សហគមន៍ព្រៃឈើ និងបង្កើតសហគមន៍ប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់ទាំងនោះ។
- ផ្តល់ទិន្នន័យនិងពតិមានអំពីការប្រើប្រាស់ព្រៃឈើរបស់សហគមន៍មូលដ្ឋានដល់ម្ចាស់ព្រៃសម្បទាន ឬស្ថាប័នរដ្ឋទាក់ទងនឹងវិស័យព្រៃឈើ តាមការស្នើសុំ។
- ជួយនិងសំរួលក្នុងការអនុវត្តន៏ផែនការគ្រប់គ្រងព្រៃសម្បទាន។
- ធ្វើនិងអនុវត្តន៏ផែនការគ្រប់គ្រងសំរាប់សហគមន៍គ្រប់គ្រងក្នុងតំបន់សម្បទាន ដែលបានយល់ព្រមលើតំបន់ដែលមិនចុះសំរុងគ្នាក្នុងការប្រើប្រាស់សំរាប់អភិវឌ្ឍន៏សហគមន៍ព្រៃឈើ។ នេះរួមទាំងកាតព្វកិច្ចឆ្ពោះទៅរកផែនការគ្រប់គ្រងដែលទាក់ទងទៅនឹងស្ថាប័នរដ្ឋនិងម្ចាស់ព្រៃសម្បទាន។
- ឆ្លើយតបទៅនឹងសិទ្ធិថែរក្សាវប្បធម៌និងទំលៀមទំលាប់របស់ខ្លួន សហគមន៍មានកាតព្វកិច្ចកំណត់"វប្បធម៌" និង"ទំលៀមទំលាប់" របស់ខ្លួនអោយបានច្បាស់លាស់ ហើយមិនយកទំលៀមទំលាប់ណាផ្សេងក្រៅពីរបស់ខ្លួនមក សំអាងដើម្បីទាមទារផ្ទៃដីព្រៃឈើបន្ថែមពីម្ចាស់ព្រៃសម្បទាន។
- រៀបចំដំណើការត្រួតពិនិត្យ វាយតំលៃ ហើយរាយការណ៏ពីសកម្មភាពក្នុងតំបន់ព្រៃសម្បទាន។
- ផ្តល់វិភាគទានខ្លះតាមតម្រូវការ ដើម្បីការងារអភិវឌ្ឍន៍សហគមន៍ព្រៃឈើ ដូចជា កំលាំងពលកម្ម សំភារៈ។
- ជួយដល់រដ្ឋាភិបាលនិងក្រុមហ៊ុនព្រៃសម្បទាន ក្នុងការការពារ មិនអោយមានអំពើល្មើសច្បាប់ ក្នុងតំបន់ព្រៃ សម្បទាន។

គោរពកិច្ចសន្យាព្រៃសម្បទានដែលបានព្រមព្រាងរវាងក្រុមហ៊ុនព្រៃសម្បទាន និងរដ្ឋាភិបាល.

**សិទ្ធិក្រុមហ៊ុនព្រៃសម្បទាន**

១។ ក្រុមហ៊ុនព្រៃសម្បទានធ្វើអាជីវកម្មនៅកម្ពុជាមានសិទ្ធិដូចខាងក្រោម:

- ការពារចំពោះរំលោភចូលដោយល្មើសច្បាប់ពីភាគីណាមួយក្នុងព្រៃសម្បទាន។
- ការពារសិទ្ធិដែលមានចែងក្នុងកិច្ចសន្យា និងទទួលអត្ថប្រយោជន៍តាមកិច្ចសន្យាវិនិយោគទុន កិច្ចព្រមព្រាង ព្រៃសម្បទាន និងផែនការគ្រប់គ្រង។
- សិទ្ធិជាអាទិភាពក្នុងការធ្វើអាជីវកម្មឈើ ដែលមានតំលៃសេដ្ឋកិច្ចក្នុងព្រៃសម្បទាន។
- រកប្រាក់ចំណូលពីការគ្រប់គ្រងព្រៃឈើ
- កំណត់តំបន់ព្រៃឈើសំរាប់ប្រើប្រាស់និងសំរុះសំរួលតំបន់ទាំងនោះ។

**កាតព្វកិច្ចរបស់ក្រុមហ៊ុនព្រៃសម្បទាន**

១។ ក្រុមហ៊ុនព្រៃសម្បទានធ្វើអាជីវកម្មនៅកម្ពុជាមានកាតព្វកិច្ចដូចខាងក្រោមៈ

- បង់ពន្ធតាមតារាងពន្ធឈើ ក្នុងនោះមួយចំណែកសមស្រប គួរតែផ្តល់សំរាប់ទ្រទ្រង់សុខមាលភាពរបស់ សហគមន៏.
- អនុវត្តតាមបទដ្ឋានបរិស្ថាននិងបទបញ្ញតិដែលអាចអនុវត្តន៏បានដើម្បីគ្រប់គ្រងព្រៃឈើប្រកបដោយការរក្សាប្រព័ន្ធ័អេកូឡូស៊ីនិងគុណភាពបរិស្ថាន.
- ផ្តល់ឱកាសជាអាទិភាពសំរាប់ចូលបំរើការងារនិងបណ្តុះបណ្តាលជំនាញ សំរាប់បំពេញការងារដល់សមាជិក សហគមន៏មូលដ្ឋាន.
- ការពារនិងស្តារព្រៃឈើឡើងវិញ ក្នុងតំបន់ដែលក្រុមហ៊ុនព្រៃសម្បទានធ្វើអាជីវកម្ម.
- គោរពនិងប្រតិបត្តិតាមសិទ្ធិ ទំលាមទំលាប់ និងជំនឿផ្សេង១របស់សហគមន៏.
- ប្រត្តិបត្តិតាមសហគមន៏ចំពោះតំបន់មិនទាន់ចុះសំរុងក្នុងការប្រើប្រាស់ ដែលត្រូវបានកំណត់ព្រំប្រទល់ដោយ កិច្ចព្រមព្រាងរវាងម្ចាស់ព្រៃសម្បទាន រដ្ឋាភិបាល និងសហគមន៏មូលដ្ឋាន.
- គាំទ្រដល់សកម្មភាពទ្រទ្រង់សុខមាលភាពសហគមន៏ ស្របតាមទំហឹសកម្មភាពនិងលទ្ធភាពរបស់ ព្រៃសម្បទាន.
- គាំទ្រដល់ការគ្រប់គ្រងព្រៃឈើអោយមាននិរន្តរភាព ដែលនាំអោយបរិយាកាសសង្គមនិងរូបសាស្រ្ត អាចទ្រទ្រង់ដល់ការថែរក្សាភាពរឹងមាំនិងភាពត្រឹមត្រូវ សំរាប់បំរើផលប្រយោជន៏សហគមន៏មូលដ្ឋាន.
- អនុញ្ញាត្តិអោយចេញចូលនិងប្រើប្រាស់ ដោយគ្មានចំណាយលើផ្លូវព្រៃសម្បទានទាំងឡាយក្នុងគោលដៅ ស្របច្បាប់.
- អនុវត្តន៏តាមបទដ្ឋាននិងបញ្ញាតិទាំងឡាយដែលមានចែងក្នុងច្បាប់នានានៃប្រទេសកម្ពុជា កិច្ចសន្យាវិនិយោគ ទុនការគ្រប់គ្រងព្រៃសម្បទាន ផែនការគ្រប់គ្រង និងកិច្ចព្រមព្រាងរួមគ្នាជាមួយសហគមន៏មូលដ្ឋាន.
- សហករក្នុងការសិក្សានិងទទួលស្គាល់នូវលទ្ធផលនិងយោបល់កែលំអរក្រោយបានចុះសិក្សា.
- គាំទ្រដល់ការផ្លាស់ប្តូររបៀបរបស់សហគមន៏ ដើម្បីលើកទឹកចិត្តការរស់នៅ ដែលមិនធ្វើអោយខូចខាតប្រព័ន្ធ អេកូឡូស៊ីព្រៃឈើ.

១។ សិទ្ធិរបស់រដ្ឋាភិបាល

ទាក់ទងទៅនឹងព្រៃសម្បទាន រដ្ឋាភិបាលកម្ពុជាមានសិទ្ធិដូចខាងក្រោមៈ

- ប្រគល់ធនធានព្រៃឈើទៅអោយក្រុមហ៊ុនព្រៃសម្បទាន ឬ ដីព្រៃឈើ អោយទៅអោយសហគមន៏មូលដ្ឋាន ក្នុងគោលដៅគ្រប់គ្រងព្រៃឈើអោយមាននិរន្តភាព.
- ប្រគល់សិទ្ធិអោយសហគមន៏ក្នុងការប្រើប្រាស់ គ្រប់គ្រង និង ទទួលបាននូវប្រយោជន៏ ពីការគ្រប់គ្រងព្រៃឈើ សហគមន៏.
- ពិន័យនិងផ្តន្ទាទោសដល់ក្រុមហ៊ុនព្រៃសម្បទាននិងសហគមន៏មូលដ្ឋាន ស្របតាមច្បាប់និងគោលការណ៏គលិយុត្តិ នៅពេលដែលប្រព្រឹត្តិផ្ទុយពីកិច្ចព្រមព្រាងនានា ឬលក្ខន្តិកៈគ្រប់គ្រង.
- ដកហូតព្រៃសម្បទានវិញ ករណីមិនគោរពតាមកិច្ចព្រមព្រាងព្រៃសម្បទាន ហើយដកហូតព្រៃសហគមន៏វិញ បើមិន គោរពលក្ខន្តិកៈនៃការគ្រប់គ្រង.

**កាតព្វកិច្ចរបស់រដ្ឋាភិបាល**

១១ ទាក់ទងទៅនឹងព្រៃសម្បទាន រដ្ឋាភិបាលកម្ពុជាមានកាតព្វកិច្ចដូចខាងក្រោមៈ

- បង្កើតឡើងនូវច្បាប់និងគោលនយោបាយព្រៃឈើ រួមមាន អនុក្រិត្យស្តីពីការបង្កើតសហគមន៍ព្រៃឈើ អនុក្រិត្យស្តីពីផែនការ និងគ្រប់គ្រងព្រៃសម្បទាន គោលការណ៏ណែនាំសំរាប់អភិវឌ្ឍន៏សហគមន៏ព្រៃឈើ និង ការគ្រប់គ្រងព្រៃសម្បទាន និងច្បាប់ទាក់ទងនានា និងគោលនយោបាយគាំទ្រដល់ការគ្រប់គ្រងព្រៃឈើអោយ មាននិរន្តភាព.
- ជំរុញអោយមានអភិបាលកិច្ចល្អ ក្នុងការអនុវត្តកិច្ចព្រមព្រាងនិងលក្ខន្តិកៈនៃព្រៃសម្បទាន និងការគាំទ្រដល់ សហគមន៏ ព្រៃឈើ.
- ការពារសិទ្ធិនិងផលប្រយោជន៏របស់សហគមន៏មូលដ្ឋាននិងក្រុមហ៊ុនព្រៃសម្បទាន.
- អប់រំនិងធ្វើអោយមានការយល់ដឹងទាក់ទងនឹងច្បាប់និងគោលនយោបាយព្រៃឈើ រួមទាំងសិទ្ធិនិងកាតព្វកិច្ច របស់ភាគីនិមួយៗ.
- ធ្វើអោយមានទំនាក់ទំនងល្អជាមួយសហគមន៏និងក្រុមហ៊ុនព្រៃសម្បទាន.
- ជួយសំរួលដល់កិច្ចសហការនិងទំនាក់ទំនងជិតសិទ្ធិរវាងសហគមន៏មូលដ្ឋាននិងក្រុមហ៊ុនព្រៃសម្បទាន.
- បង្កើតយន្តការប្រកបដោយវិជ្ជាជីវៈនិងប្រសិទ្ធិភាពដើម្បី អង្កេត ត្រួតពិនិត្យ និង វាយតំលៃលើការអនុវត្តន៏

យុទ្ធសាស្រ្តក្នុងការគ្រប់គ្រងព្រៃឈើ និងការបែងចែកផលប្រយោជនធនធានព្រៃឈើនិង ដោះស្រាយទំនាស់ ទាក់ទងទៅនិងធនធានព្រៃឈើ.

- យកពន្ធសមស្របលើផលព្រៃឈើពីព្រៃសម្បទានហើយធ្វើអោយប្រាកដថា មួយចំណែកនៃពន្ធនេះនឹងត្រូវបាន ផ្តល់ដល់សហគមន៏ ដើម្បីគាំទ្រដល់សកម្មភាពអភិវឌ្ឍន៏សហគមន៏ ក្នុងតំបន់ជិតខាងព្រៃសម្បទាន.
- ជំរុញអោយមានការអនុវត្តន៏ច្បាប់នានានៅក្នុងប្រទេស.

**សិទ្ធិនិងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធក្នុងតំបន់ព្រៃការពារ**

1. អ្នកពាក់ព័ន្ធសំខាន់ៗនៅក្នុងក្នុងតំបន់ព្រៃការពារ បានត្រូវកំណត់ដោយរួមមានសហគមន៏ជនជាតិ ដែលតាំងលំនៅអចិន្ត្រៃយ៏និងពនេរចរ បុគ្គលិកឧស្សាហ (ការពិភាក្សាផ្តោតទៅលើអ្នកភិរក្សឧស្សាហ) រដ្ឋាភិបាល ទាំងថ្នាក់ខេត្តនិងជាតិ. ភាពខុសប្លែកគ្នាត្រូវបានបង្កើតឡើងរវាសហគមន៏ជនជាតិ ដែលតាំងលំនៅ អចិន្ត្រៃយ៏និងពនេរចរ ព្រោះក្រុមដែលតាំងលំនៅអចិន្ត្រៃយ៏រស់នៅក្នុងតំបន់ព្រៃការពាររហូត ហើយទាមទារ អោយមានការយកចិត្តទុកដាក់ទៅលើពួកគេ . ម្យ៉ាងទៀត ត្រូវផ្តល់សិទ្ធិអោយពួកគេច្រើនក្នុងការចេញចូល និងប្រើប្រាស់តំបន់ព្រៃការពារ ហើយអោយពួកគេទទួលខុសត្រូវជាចំបងក្នុងការគ្រប់គ្រង ជាងអ្នកពនេចរ ឬធ្វើតាមរដូវ . សហគមន៏តាមរដូវកាលមានសិទ្ធិក្នុងកំរិតកំណត់មួយលើការចេញចូល និងប្រើប្រាស់ធនធាន ធម្មជាតិ ហើយការទទួលខុសត្រូវក្នុងការគ្រប់គ្រងក៏តិចជាងដែរ.
2. សិទ្ធិនិងការទទួលខុសត្រូវខាងក្រោម ផ្តោតទៅការបង្កើតអោយមានការអភិវឌ្ឍន៏សហគមន៏ ដែលមាន និរន្តរភាព រួមមានសហគមន៏ព្រៃឈើ ក្នុងតំបន់ព្រៃសម្បទានផងដែរ.

**សិទ្ធិរបស់ជនជាតិឬសហគមន៍អចិន្ត្រៃយ៍**

- ចូលរួមក្នុងការធ្វើផែនការ កំណត់តំបន់គ្រប់គ្រង ត្រួតពិនិត្យ ធ្វើសេចក្តីរាយការណ៍ ការពារនិងអនុវត្តន៍ផែនការគ្រប់គ្រងតំបន់ព្រៃការពារ.
- ប្រើប្រាស់ធនធានធម្មជាតិតាមប្រពៃណី បញ្ចូលទាំងសិទ្ធិក្នុងការបន្តប្រើប្រាស់ដីជាប្រពៃណីប្រកបដោយ និរន្តរភាពនិងចិញ្ចឹមជីវិតជាលក្ខណៈប្រពៃណី.
- ទទួលបានពត៌មាននិងទទួលបានការអប់រំ
- តវ៉ាការពារខ្លួន និង និយាយដោយចំហរដោយគ្មានការភ័យខ្លាច
- ទទួលផលប្រយោជន៍ដោយផ្ទាល់ និងដោយប្រយោលពីតំបន់ព្រៃការពារ និងសិទ្ធិចិញ្ចឹមជីវិត
- រក្សាវប្បធម៌ទំនៀមទំលាប់និងជំនឿផ្សេងៗ
- ចូលរួមក្នុងការអភិរក្សធម្មជាតិដែលកំណត់ដោយបទដ្ឋានច្បាប់
- សហការជាមួយស្ថាប័នរដ្ឋ អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ
- ចូលរួមក្នុងការកំណត់ទីតាំងនិងព្រំប្រទល់ដី.

**សិទ្ធិសហគមន៍រស់នៅអចិន្ត្រៃយ៍ ឬសហគមន៍រស់នៅតាមរដូវកាល**

- ត្រួតពិនិត្យនិងរាយការណ៍អំពីសកម្មភាពនៅក្នុងឬក្បែរតំបន់ព្រៃការពារ
- ទទួលការពត៌មាននិងទទួលបានការអប់រំ
- ចូលរួមក្នុងការការពារព្រៃឈើនិងធនធានធម្មជាតិដ៏ទៃទៀត
- សហការជាមួយស្ថាប័នរដ្ឋ អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ.

**កាតព្វកិច្ចរបស់សហគមន៍ ( សហគមន៍ជនជាតិ ឬអចិន្ត្រៃយ៍និងសហគមន៍ពនេចរ ឬសហគមន៍រស់នៅតាមរដូវកាល )**

- ប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់ព្រៃការពារអោយនិរន្តរភាព
- ចូលរួមបញ្ចេញគំនិត និងចូលរួមក្នុងការធ្វើសេចក្តីសំរេចចិត្តនានា
- គោរពច្បាប់ បទបញ្ជា និងបទបញ្ញតិនានា
- ប្រើប្រាស់និងគ្រប់គ្រងធនធានអោយមាននិរន្តរភាព ហើយអភិរក្សធនធានធម្មជាតិ
- គោរពសិទ្ធិរបស់អ្នកដទៃ
- មិនបំផ្លាញធនធានធម្មជាតិ
- ចូលរួមក្នុងសកម្មភាពគ្រប់គ្រង
- ចូលរួមការពារព្រៃឈើនិងធនធានធម្មជាតិដ៏ទៃទៀត
- ចូលរួមការពារនិងអភិរក្សប្រភេទពូជឈើ និងសត្វព្រៃដែលកំពុងរងការគំរាមនិងបាត់បង់
- ទទួលស្គាល់តម្រូវការនៃរាល់ក្រុមចាប់អារម្មណ៍ទាំងអស់

- ចូលរួមយ៉ាងសកម្មក្នុងក្នុងការគ្រប់គ្រងតំបន់ព្រៃការពារ
- ធ្វើអោយប្រាកថាតម្រូវការផ្សេងៗនៃក្រុមសហគន៏និមួយៗ ត្រូវបានយល់ដឹងនិងធ្វើសេចក្តីសំរេចចិត្ត
- សហការជាមួយស្ថាប័នរដ្ឋ អង្គការអន្តជាតិនិងអង្គការក្រៅរដ្ឋាភិបាល
- រក្សាទំនាក់ទំនងល្អជាមួយរដ្ឋាភិបាល.

**កាតព្វកិច្ចរបស់សហគមន៏រស់តាមរដូវកាលឬនៅពនេចរ**

ជាបន្ថែមកាតព្វកិច្ចដែលបានរៀវាប់ខាងលើ សហគមន៏រស់តាមរដូវកាលឬនៅពនេចរត្រូវមានកាតព្វកិច្ច ស្របតាម

តម្រូវការរបស់ជនជាតិនិងសហគមន៏អចិន្ត្រៃយ៍ពីព្រោះពួកគាត់មានការចាប់អារម្មណ៏ក្នុងការគ្រប់គ្រងធនធានព្រៃ អោយមាននិរន្តរភាព ដែលជាការចាំបាច់សំរាប់ចិញ្ចឹមជីវិតពួកគាត់.

**សិទ្ធិរបស់អ្នកអភិរក្សតំបន់ការពារ**

- ត្រួតពិនិត្យការប្រើប្រាស់និងគ្រប់គ្រងធនធានព្រៃឈើរបស់សហគមន៏ក្នុងតំបន់ព្រៃការពារនិងតំបន់ដែលមាន ឥទ្ធិពលលើតំបន់ព្រៃការពារ.
- បញ្ឈប់រាល់សកម្មភាពល្មើសទាំងឡាយដែលផ្ទុយទៅនឹងបទបញ្ញត្តិក្នុងតំបន់ព្រៃការពារ.
- ផ្តល់ជាអនុសាសន៏ដល់អាជ្ញធរមានសមត្ថកិច្ច ដើម្បីលប់ចោលដីព្រៃពីសហគន៏ក្នុងករណី អនុវត្តន៏មិនបាន ត្រឹមត្រូវតាមកិច្ចព្រមព្រាងសហគមន៏.
- ប្តឹងទៅតុលាការ ចំពោះសហគមន៏ ឬបុគ្គលណាដែលមិនគោរពតាមបទបញ្ញតិតំបន់ព្រៃការពារ.
- ជួយសហគមន៏ក្នុងការអនុវត្តន៏វិធានការស្របច្បាប់ ចំពោះបុគ្គលណាដែលរំលោភលើកិច្ចព្រមព្រាង សហគមន៏.
- ជួយសហគមន៏មូលដ្ឋានក្នុងការបង្កើតគោលការណ៏ណែនាំ សំរាប់គ្រប់គ្រងតំបន់ដែលសហគន៏ប្រើប្រាស់ ក្នុងតំបន់ព្រៃការពារ តាមការស្នើសុំពីសហគមន៏.
- កំណត់ដែនព្រៃក្នុងតំបន់ព្រៃការពារដោយមានការពិគ្រោះយោបល់និងគិតគូរដល់ការប្រើប្រាស់ជាប្រពៃណី ក្នុងតំបន់ទាំងនោះ.
- ផ្តល់នូវអនុសាសន៏ ទាក់ទងទៅនឹងសំណើរគំរោងអភិវឌ្ឍន៏ រួមទាំង សិទ្ធិផ្តល់យោបល់ច្រានចោលគំរោង ទាំងនោះដែលអាចមានផលប៉ះពាល់ជាអវិជ្ជមានដល់តំបន់ព្រៃការពារធនធានធម្មជាតិឬសហគមន៏មូលដ្ឋាន.
- បង្កើតនិងផ្ញើសំណើរទៅអាជ្ញាធ័រមានសមត្ថកិច្ចដែលទទួលសំណើរ ដើម្បីគ្រប់គ្រងតំបន់ការពារ.
- សហការជាមួយជំនាញពាក់ពន្ធ័ និងអាជ្ញាធរដែនដីដើម្បីអភិរក្សនិងគ្រប់គ្រងធនធានធម្មជាតិក្នុងតំបន់ការពារ

ឬតំបន់ដែលមាឥទ្ធិពលលើព្រៃការពារ.

- ចូលរួមយ៉ាងសកម្មក្នុងការគ្រប់គ្រងតំបន់ព្រៃការពារ.

- ណែនាំ អប់រំ និង ផ្សព្វផ្សាយដល់សហគមន៍មូលដ្ឋានពីច្បាប់បទបញ្ញត្តិ និងគោលការណែនាំនានាទាក់ទងនឹងការគ្រប់គ្រងតំបន់ព្រៃការពារ.
- រៀបចំអោយមានសកម្មភាព ដើម្បីស្តារឡើងវិញនូវធនធានធម្មជាតិនៅក្នុងសហគមន៍និងក្នុងតំបន់ គ្រប់គ្រង.

**កាតព្វកិច្ចរបស់អ្នកអភិរក្សឧស្យាន**

- អនុវត្តន៍តាមគោលការណ៍ណែនាំ បទបញ្ញត្តិ ប្រកាស ច្បាប់ និង លិខិតបទដ្ឋាននានា ដែលបានបង្កើតឡើងដោយក្រសួងបរិស្ថាននិងរាជរដ្ឋាភិបាលកម្ពុជា.
- ដឹកនាំ បង្កើតអោយមាននិងសំរួលសហគមន៍មូលដ្ឋាន ក្នុងការប្រើប្រាស់និងគ្រប់គ្រងធនធានធម្មជាតិក្នុងតំបន់ព្រៃការពារប្រកបដោយនិរន្តភាព.
- ធ្វើផែនការគ្រប់គ្រងសំរាប់តំបន់ការពារ
- ការពារធនធានធម្មជាតិក្នុងតំបន់ការពារ
- បង្កើតនិងរក្សាទំនាក់ទំនងល្អ ហើយជិតស្និទ្ធិជាមួយអាជ្ញាធរមូលដ្ឋាននិងស្ថាប័នពាក់ពន្ធ័នានា
- ចូលរួមក្នុងការសិក្សាស្រាវជ្រាវផ្សេងៗទាក់ទងនិងតំបន់ការពារ
- ការពារសិទ្ធិសហគមន៍មូលដ្ឋាន
- សំរួលដល់ការទំនាក់ទំនងរវាងសហគមន៍និងរដ្ឋាភិបាលថ្នាក់ជាតិ
- ផ្តល់សេវាផ្សព្វផ្សាយដល់សហគមន៍មូលដ្ឋាន.

**សិទ្ធិរបស់បុគ្គលិករដ្ឋដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងតំបន់ព្រៃការពារ កំរិតថ្នាក់ខេត្ត**

- សំរបសំរួលគ្រប់គ្រងតំបន់ការពារឧស្យានជាតិ ជាមួយស្ថាប័នពាក់ព័ន្ធនានានៅថ្នាក់ខេត្ត
- បង្កើតនិងចូលរួមក្នុងក្រុមការងារដោះស្រាយទំនាស់ ដែលកើតមាននៅថ្នាក់ខេត្ត
- ចូលរួមក្នុងផែនការប្រើប្រាស់ដីដោយមានការចូលរួមកំរិតថ្នាក់ខេត្ត ដើម្បីធ្វើអោយប្រាកដថា រាល់ការពិចារណាទៅលើបរិស្ថានបានគិតគូរដល់ផែនការប្រើប្រាស់ដី.
- សំរួលដល់ការបង្កើតដែនព្រៃការពារ
- ធ្វើអធិការកិច្ច ត្រួតពិនិត្យ និងវាយតំលៃសហគមន៍ព្រៃឈើនិងឥទ្ធិពលតំបន់ការពារ.

**កាតព្វកិច្ចរបស់បុគ្គលិករដ្ឋដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងតំបន់ព្រៃការពារ កំរិតថ្នាក់ខេត្ត**

- អនុវត្តន៍គោលនយោបាយជាតិ ច្បាប់ និងគោលការណ៍ណែនាំនានា
- ផ្តល់របាយការណ៍ទៅថ្នាក់ជាតិនិងមូលដ្ឋាន ទាក់ទងនឹងលក្ខន្តិកៈនៃតំបន់ការពារក្នុងខេត្ត ផែនការគ្រប់គ្រងការពិចារណារបស់សហគមន៍ក្នុងការបង្កើតនិងអនុវត្តន៍ផែនការគ្រប់គ្រង.
- បណ្តុះបណ្តាលបច្ចេកទេសដល់បុគ្គលិកក្នុងខេត្ត

- អនុលោមតាមសិទ្ធិនៃសហគមន៍ក្នុងនិងនៅក្បែរតំបន់ការពារ ក្នុងខេត្ត
- "កសាងផែនការ" និង ឬ គាំទ្រ " និងគំរោងថវិកាសំរាប់អភិវឌ្ឍន៍សហគមន៍ព្រៃឈើក្នុងតំបន់ការពារក្នុងខេត្ត ដោយពិគ្រោះយោបល់និងសំរបសំរួលជាមួយសហគមន៍មូលដ្ឋាននិងអ្នកអភិរក្សឧស្សានថ្នាក់មូលដ្ឋាន.

**សិទ្ធិរបស់បុគ្គលិករដ្ឋដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងតំបន់ព្រៃការពារ កំរិតថ្នាក់ជាតិ**

- សំរបសំរួលរវាងអ្នកគ្រប់គ្រងតំបន់ការពារឧស្សានជាតិនិងស្ថាប័នរដ្ឋដែលពាក់ព័ន្ធនៅថ្នាក់ខេត្ត ជាតិនិងអន្តជាតិ.
- លើកទឹកចិត្តអោយមានការចូលរួមក្នុងការប្រើប្រាស់ព្រៃឈើអោយមាននិរន្តភាព និងគ្រប់គ្រងធនធានធម្មជាតិ ក្នុងតំបន់ព្រៃការពារនិងតំបន់ដែលមានឥទ្ធិពលលើតំបន់ព្រៃការពារ.
- អន្តរាគមន៍រាល់ការស្នើសុំដែលមានឥទ្ធិពលលើតំបន់ព្រៃការពារ ប្រសិនបើមានភស្តុតាងដែលបញ្ជាក់ថារាល់ សំណើទាំងនោះអាចជះឥទ្ធិពលទៅលើសហគមន៍ ឬធនធានធម្មជាតិក្នុងតំបន់ព្រៃការពារ.

**សិទ្ធិរបស់បុគ្គលិករដ្ឋដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងតំបន់ព្រៃការពារ កំរិតថ្នាក់ជាតិ**

- រៀបចំនិងបង្កើតនូវវិធានការស្របច្បាប់នានា ដើម្បីចូលរួមគ្រប់គ្រងសហគមន៍ព្រៃឈើក្នុងតំបន់ព្រៃការពារ អោយមាននិរន្តរភាព.
- ស្រាវជ្រាវនិងប្រមូលពត៌មានទាក់ទងនឹងទិដ្ឋភាពសង្គមក្នុងតំបន់ព្រៃការពារ
- បង្កើតគោលការណ៍ណែនាំដើម្បីគ្រប់គ្រងតំបន់ព្រៃការពារ
- បង្កើតគោលការណ៍ណែនាំបច្ចេកទេសដើម្បីអភិវឌ្ឍន៍សហគន៍ព្រៃឈើនៅកំរិតថ្នាក់ខេត្ត
- ផ្តល់ពត៌មានស្តីពីគោលនយោបាយរបស់រដ្ឋ ការគ្រប់គ្រងក្នុងតំបន់ព្រៃការពារនិងពត៌មានផ្សេងទៀត ដែល ទាក់ទងទៅនឹងសហគមន៍មូលដ្ឋានរស់នៅក្នុងនិងក្បែរតំបន់ព្រៃការពារ.
- អប់រំបុគ្គលិកថ្នាក់ខេត្តនិងថ្នាក់មូលដ្ឋានអំពីដំណើការនិងទំរង់ការនៃការអភិវឌ្ឍន៍សហគមន៍ព្រៃឈើ.
- កំណត់ទំរង់ការសំរាប់កំណត់ដែនព្រៃ ដើម្បីធ្វើអោយប្រាកដថាការប្រើប្រាស់ និងគ្រប់គ្រងធនធានធម្មជាតិមាន និរន្តរភាពក្នុងតំបន់ព្រៃការពារ និងធ្វើអោយប្រាកដថាការរស់នៅរបស់សហគមន៍ត្រូវបានគេយកចិត្តទុកដាក់.
- បង្កើតអោយមាននិងអនុវត្តន៍តាមដំណើការនិងទំរងការដើម្បីកំណត់ព្រំប្រទល់តំបន់ព្រៃការពារ.
- កសាងផែនការការងារនិងផ្តល់ធនធានថវិកា ដើម្បីអភិវឌ្ឍន៍សហគមន៍ព្រៃឈើទាក់ទងនឹងការគ្រប់គ្រងតំបន់ ព្រៃការពារ.
- ផ្តល់បច្ចេកទេសដើម្បីអភិវឌ្ឍន៍សហគមន៍ព្រៃឈើ តំបន់ព្រៃការពារ រួមទាំងត្រួតពិនិត្យនិងវាយតំលៃនិងសំរួល ក្នុងការដោះស្រាយទំនាស់ និងជួយដល់ការត្រួតពិនិត្យអំពើល្មើសនានា ដែលមានឥទ្ធិពលអវិជ្ជមានដល់តំបន់ ព្រៃការពារនិងសហគមន៍មូលដ្ឋាន.